សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ច

# របស់អាជ្ញាធរព្រះវិហារ

ស្រាវជ្រាវដោយៈ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ **ពិច ចរិយា** | **បណ្ឌិត អ៊ុន សកក្កដា**

**ហួរ ហន់ឡឺ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១២

ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ពិច ចរិយា** និងនាងខ្ញុំឈ្មោះ **ហួរ ហាខ្យឹ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី១៦ផ្នែកនីតិសាស្ត្រ នៃសាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៥-២០១៦។ កូនសូមថ្លែងអំណរគុណចំពោះ៖

- **លោកឪពុក ពេញ សុខុម**
- **លោកឪពុក ហួរ ចំរើន**
- **អ្នកម្តាយ ម៉ួយ ស្រី**
- **អ្នកម្តាយ អ៊ុក សុភិន**

កូនសូមសម្តែងនូវមហាកតញ្ញូតាធមិជាអនេកប្បការចំពោះលោក អ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត និងខិតខំបីបាច់ ថែរក្សាកូនឲ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាបវរនេះគឺធ្វើឲ្យកូនចងចាំ និងគ្មានអ្វីអាចបំភ្លេចបានឡើយ។ កូនសូមហាត្ថប្រណម្យគោរពប្រណិបតន៍ផ្ញើស្នាដៃនេះជូនចំពោះលោកទាំងពីរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់។

ថ្វីត្បិតការចងក្រងកិច្ចការស្រាវជ្រាវនេះគ្រាន់តែជាស្នាដៃតូចមួយពិតមែន តែវាជាសក្ខីភាពមួយបញ្ជាក់ថា កូនមិនបណ្តោយឲ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍នោះឡើយ។ កូនសូមបួងសួងរាល់អស់ទេវតា និងវត្ថុស័ក្តសិទ្ធិទាំងឡាយសូមតាមថែរក្សា និងការពារលោកអ្នកមានគុណទាំងពីរគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ កូនសូមបួងសួងដល់សក្កទេវរាជគ្រប់ទិសទីឲ្យ ថែរក្សាលោកមានគុណទាំងពីរប្រកបដោយជន្មាយុយឺនយូហើយបានឃើញអនាគតភ្លឺស្វាងរបស់កូន។

សូមគោរពចំពោះ **ឯកឧត្តម លុច ចណ្ណា** សាកលវិទ្យធិការ ព្រមទាំងសាកលវិទ្យាធិការរងព្រឹទ្ធបុរស អស់លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពស់ និងជួយតម្រង់ទិសដល់យើងខ្ញុំ តាំងពិឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

លោកសាស្ត្រាចារ្យ បណ្ឌិត **អ៊ុន សកក្កដា** ដែលបានដឹកនាំបង្ហាញពីគំនិត និងវិធី សាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកតាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវមួយនេះ។ វាពិតជាមិនមានអត្ថិភាព ឡើយបើគ្មានការជួជ្រោមជ្រែងពីសំណាក់លោកសាស្ត្រាចារ្យ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរលោកអ្នកមានគុណ ដែលបានរៀបរាប់ខាងលើ សូមឲ្យជួបប្រទះនូវពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងប្រព័ន្ធសិក្សាធិការ ថ្នាក់សាកលវិទ្យាល័យ មិនថានៅប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ឡើយនៅមុនពេលទទួលសញ្ញាប័ត្រដើម្បីបញ្ចប់ការសិក្សាត្រូវធ្វើសារ ឬនិក្ខេបបទដើម្បីបញ្ជាក់នូវការយល់ដឹងរបស់ខ្លួន ដែលបានឆ្លងកាត់រយៈពេលសិក្សា និងការធ្វើកម្មសិក្សាកន្លងមក និងដើម្បីទុកដាក់ជាឯកសារដល់អ្នកសិក្សា និងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត។

ដោយអនុវត្តន៍តាមគោលការណ៍ក្រសួងអប់រំ យុវជន និងកីឡា និងសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានទទួលការអនុញ្ញាតពីសាកលវិទ្យាល័យ ក្នុងការសរសេរសារណាមួយក្រោមប្រធានបទ តួនាទី និងភារកិច្ចរបស់អាជ្ញាធរព្រះវិហារដែលកើតពីការខិតខំប្រឹងប្រែង និងការស្រលាញ់ចេញពីឆន្ទៈពិតប្រាកដក្នុងការសរសេរទៅលើប្រធានបទនេះ។ ឆ្លងកាត់តាមការអប់រំពីសំណាក់ លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យជាច្រើន គឺពិតជាធ្វើឲ្យយើងខ្ញុំស្រលាញ់នូវការសិក្សានិងមានស្មារតីក្រេបយកពុទ្ធិល្អៗជាច្រើនដើម្បីមកអភិវឌ្ឍខ្លួនជាងនេះទៅទៀតគឺយើងខ្ញុំពិតជាចង់បញ្ចេញនូវ ការចែករំលែកចំណេះដឹងតាមរយៈការស្រាវជ្រាវ ក៏ដូចជាមានបំណងចង់ទុកនូវស្នាដៃដល់អ្នកសិក្សា ស្រាវជ្រាវជំនាន់ក្រោយ ដើម្បីចូលរួមចំណែកជាប្រទីបបំភ្លឺនូវការស្រពិចស្រពិល និងការងឿងឆ្ងល់ដែលទាក់ទងទៅនឹងប្រធានបទខាងលើនេះ។ ក្នុងន័យដើម្បីបំពេញសារណា ដែលមានលក្ខខណ្ឌពេញលេញ ប្រកបដោយខ្លឹមសារ និងអត្ថន័យសមស្របតាមច្បាប់នោះ តម្រូវឲ្យយើងខ្ញុំខិតខំប្រឹងប្រែងព្យាយាម និងយកចិត្តទុកដាក់ ក្នុងការស្រាវជ្រាវនូវ បណ្តាអត្ថបទជាច្រើន លើសពីនេះ ទៅទៀតជាការឆ្លើយតបទៅ នឹងសន្តានចិត្តដ៏ល្អប្រពៃពីសំណាក់លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ក្នុងការចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍សម្រាប់ជាមូលដ្ឋានចំណេះដល់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថា ស្នាដៃនេះប្រាកដជាមានការខុសឆ្គងដោយប្រការណាមួយជាក់ជាពុំខានទាំងអក្ខាវិរុទ្ធ ទាំងអត្ថន័យក្នុងវិស័យច្បាប់ ព្រោះថានេះជាស្នាដៃដំបូងរបស់យើងខ្ញុំដែលទទួលបានក្រោយពីការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាស្ត្រសេដ្ឋកិច្ច។ ជាថ្មីម្តងទៀតក្នុងនាមយើងជាអ្នករៀបរៀងផ្ទាល់ក្នុងសារណានេះរង់ចាំទទួលនូវការរិះគន់ កែលម្អក្នុងន័យអភិវឌ្ឍនូវបណ្តាការខ្វះខាត និងកំហុសខុសឆ្គងទាំងអស់ ដើម្បីឲ្យស្នាដៃនេះក្លាយជាចំណែកមួយជាជំនួយស្មារតី និងចំណេះដឹងសម្រាប់និស្សិតជំនាន់ក្រោយៗទៀត។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ក៏សូមជូនពរដល់អស់លោកលោកស្រីដែលកំពុងអានសៀវភៅនេះសូមទទួលបាន ជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការ គឺអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម**.......................................................................................................................១

## ជំពូកទី១ ទិដ្ឋភាពទូទៅ

១.១ កត្តាជំរុញឲ្យមានការបង្កើតអាជ្ញាធរជាតិព្រះវិហារ ...........................................................៥

១.១.១. ប្រវត្តិប្រាសាទព្រះវិហារ .......................................................................................៦

១.១.២. ប្រវត្តិនៃវិវាទប្រាសាទព្រះវិហារ ................................................................................៧

១.២ការបង្កើតអាជ្ញាធរព្រះវិហារ ......................................................................................២២

១.២.១. គោលបំណងនៃការបង្កើតអាជ្ញាធរជាតិព្រះវិហារ ...........................................................២៣

១.២.២. ដំណើរការប្រព្រឹត្តទៅរបស់អាជ្ញាធរព្រះវិហារព្រមទាំងសិទ្ធិនិងសមត្ថកិច្ចដែនដី......២៣

ក. ដំណើរការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ.................................................២៣

ខ. សិទ្ធិ និងសមត្ថកិច្ចដែនដីរបស់អាជ្ញាធរជាតិព្រះវិហារ.........................................២៤

## ជំពូកទី២

## តួនាទីនិងបេសកកម្មរបស់អាជ្ញាធរជាតិព្រះវិហារ

២.១ តួនាទីនិងបេសកកម្មទូទៅរបស់អាជ្ញាធរជាតិព្រះវិហារ.........................................................២៧

២.១.១ តួនាទីនិងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាលនិងប្រធានអាជ្ញាធរជាតិព្រះវិហារ ........២៧

ក. តួនាទីនិងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាល .............................................................២៧

ខ. តួនាទី និងបេសកកម្មប្រធានអាជ្ញាធរជាតិព្រះវិហារ.......................................................២៧

២.១. ២តួនាទីនិងបេសកកម្មរបស់នាយកដ្ឋាននានា ................................................................៣១

ក. នាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុទំនាក់ទំនងសាធារណៈ ផែនការនីតិកម្ម ................៣១

ខ. នាយកដ្ឋានរមណីយដ្ឋាននិងបុរាណវិទ្យា ...............................................................៣៣

គ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ តំបន់ប្រាសាទព្រះវិហារ ..............................................៣៤

ឃ. នាយកដ្ឋាននគរូបនីយកម្មអភិវឌ្ឍន៍តំបន់ប្រាសាទព្រះវិហារនិងប្រជារាស្ត្រ........៣៤

ង.នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក ...................................................................៣៥

ច. នាយកដ្ឋានសណ្ដាប់ធ្នាប់និងសហប្រតិបត្តិការ ...........................................................៣៦

២.២ ធនធាននិងសមិទ្ធិផលរបស់អាជ្ញាធរជាតិព្រះវិហារ ..................................................៣៧

២.២.១ ធនធាន .................................................................................................៣៧

ក. ការរៀបចំថវិកា .........................................................................................៣៧

ខ.  ការអនុវត្តថវិកា ............................................................................................ ៣៨
២.២.២ សមិទ្ធផល ............................................................................................ ៣៩
ក. ការរៀបចំរបាយការណ៍ជឿនលឿន ........................................................ ៤១
ខ.ការងារដែលបំពេញក្នុងដំណាក់ការរៀបចំរបាយការណ៍ជឿនលឿន.................... ៤១
គ. សកម្មភាពការងារ.................................................................................... ៤៣
**សេចក្តីសន្និដ្ឋាន**.............................................................................................. ៤៨
**អនុសាសន៍**...................................................................................................... ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

"មហាវិមានលើកំពូលភ្នំខ្ពស់ឆ្ងាយសន្លឹមប្រៀបស្ថានសួគ៌ា មតករកដូនតាប្រាសាទព្រះវិហារ សម្រស់គ្មានពីរនៅលើសកល ទោះក្តៅរងារ ឬភ្លៀងរលឹម អ្នកនៅញញឹមគន់មិនចេះណាយ អន្ទងអារម្មណ៍ជាតិសាសន៍ទាំងឡាយមកណែបណិតកាយក្នុងដែនបុរី ប្រាសាទព្រះវិហារវប្បធម៌បុរាណ បវរថ្កើងថ្កាននៅលើលោកកីយ៍ បង្ហាញសម្រស់ក្បែរទល់ដែនថៃមានឫទ្ធិបារមីស្ថិតស្ថេរនិរន្តពយលោកតាឪសូមធ្វើសាក្សី ខ្ញុំនិងស្ម័គ្រក្ស័យថៃព្រះវិហារ ឱ្យនៅគង់វង្សស្រស់ស្អាតកើនទ្វេ ហើយគ្មានម្ចាស់ផ្សេងក្រៅពីខ្មែរឡើយ"[1]។

ជាទូទៅយើងដឹងហើយថា ប្រាសាទព្រះវិហារត្រូវបានសាធារណៈជនស្គាល់តាមរយៈស្នាដៃនានារបស់កវីអ្នកនិពន្ធដូចជា បទចម្រៀង កំណាព្យ កាព្យ និងរឿងប្រលោមលោក ឬតាមរយៈរឿងប្រវត្តិសាស្ត្រ និងមានសាធារណៈជនមួយចំនួនបានស្គាល់ប្រាសាទនេះដោយបានចំណាយថវិកាផ្ទាល់ខ្លួនក្នុងការទៅទស្សនា។ យ៉ាងណាមិញនៅក្នុងប្រវត្តិសាស្ត្រនៃសង្គមកម្ពុជាមានប្រាង្គប្រាសាទខ្មែរជាច្រើន ត្រូវបានកសាងឡើងដោយបុព្វបុរសខ្មែរកាលពីសម័យបុរាណ ដែលប្រាសាទទាំងនោះកសាងឡើងក្នុងគោលបំណងគោរពបូជាក្នុងលទ្ធិសាសនា និងបានស្តែងឱ្យឃើញពីអត្តសញ្ញាណជាតិ វប្បធម៌ និងអរិយធម៌ ក៏ដូចជាបានឆ្លុះបញ្ចាំងនូវភាពរីកចំរើន នៃសង្គមខ្មែរក្នុងសម័យកាលនោះ។ នៅក្នុងចំណោមប្រាង្គប្រាសាទ ដ៏ល្អប្រណីតជាច្រើនរបស់បុព្វបុរសខ្មែរយើងក្នុងនោះ ប្រាសាទព្រះវិហារក៏ជាប្រាសាទមួយដែលត្រូវបានពិភពលោកទទួលស្គាល់ថាជាកន្លែង វប្បធម៌ និងប្រវត្តិសាស្ត្រដ៏ល្បីផងដែរ មិនតែប៉ុណ្ណោះប្រាសាទនេះត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដើម្បីធ្វើការអភិរក្ស ក៏ដូចជាចង់សបញ្ជាក់ឱ្យឃើញថាប្រាសាទនេះជាសម្បត្តិបេតិកភណ្ឌរបស់ខ្មែរ និងមានដើមកំណើតចេញពីស្នាដៃរបស់បុព្វបុរសខ្មែរពិតៗ។

ទន្ទឹមនឹងនេះប្រាសាទព្រះវិហារធ្លាប់មានបញ្ហាវិវាទ ជាប្រវត្តិស្រាស្រ្តដ៏ល្បីល្បាយរវាងប្រទេសជិតខាងយើងផងដែរនោះគឺប្រទេសថៃ ដោយប្រទេសនេះបានរំលោភបំពានមកលើបូរណភាពដែនដីរបស់ប្រទេសកម្ពុជា និងបានអះអាងថាប្រាសាទព្រះវិហារជាប្រាសាទរបស់ខ្លួន និងស្ថិតនៅលើទឹកដីរបស់ខ្លួនផងដែរ។ ជុំវិញបញ្ហានេះរាជរដ្ឋាភិបាលកម្ពុជាក៏បានប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice ហៅកាត់ថា ICJ ) ដើម្បីធ្វើការដោះស្រាយ។ នៅក្នុងការដោះស្រាយវិវាទដ៏ចម្រូងចម្រាស់នេះទីបំផុត តុលាការយុត្តិធម៌អន្តរជាតិ ( ICJ ) បានសម្រេចឱ្យប្រាសាទព្រះវិហារ

---

[1] នេះគឺជាទំនុកច្រៀងដ៏មានអត្ថន័យ និងអត្ថរសដែលត្រូវបានដកស្រង់ចេញពីបទ "ប្រាសាទព្រះវិហារ" ច្រៀងដោយ ដា សកក្កដា(ជាកូនខ្មែរមួយរូបដែលបានតាក់តែង និពន្ធចម្រៀងនេះឡើងមក)

ត្រូវស្ថិតនៅក្រោម អធិបតេយ្យរបស់កម្ពុជា មិនតែប៉ុណ្ណោះប្រទេសថៃត្រូវដកកងទ័ពនិងកម្លាំងផ្សេងៗទៀតចេញពីតំបន់ប្រាសាទព្រះវិហារ។

ដោយយោងទៅតាមប្រវត្តិសាស្ត្រ និងការអភិវឌ្ឍន៍ឥតឈប់ឈររបស់ប្រទេសជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយតំបន់ព្រំដែនឱ្យក្លាយជាតំបន់សេដ្ឋកិច្ច វប្បធម៌ សន្តិភាព សហប្រតិបត្តិការជាមួយប្រទេសជិតខាងប្រកបដោយភាពរីកចំរើន និងអភិវឌ្ឍ ហេតុនេះហើយបានជារាជរដ្ឋាភិបាលបង្កើតអាជ្ញាធរមួយដែលមានឈ្មោះថា អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ និងត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/១២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅពេលដែលអាជ្ញាធរព្រះវិហារបានបង្កើតឡើង យើងឃើញថាអាជ្ញាធរនេះបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងម៉ត់ចត់ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់លើកិច្ចការរបស់ខ្លួន ប៉ុន្តែយើងមិនបានដឹងច្បាស់ទេថាតើអាជ្ញាធរនេះបង្កើតឡើងក្នុងគោលបំណងអ្វី និងមានតួនាទី ព្រមទាំងមានភារកិច្ចអ្វីខ្លះនោះទេ ហើយអាជ្ញាធរនេះពុំសូវមានអ្នកស្គាល់ដូចអាជ្ញាធរផ្សេងៗទៀតឡើយ។ ដូចច្នេះហើយ ចំនុចទាំងអស់នេះបានក្លាយជាដើមចមនៃការស្រាវជ្រាវប្រធានបទនេះឡើងគឺក្នុងគោលបំណងចង់បំភ្លឺការយល់ដឹងបន្ថែមរបស់សិស្ស និស្សិត អ្នកស្រាវជ្រាវ រួមទាំងសាធារណៈជនទាំងអស់ឱ្យបានជាពុទ្ធិ។ ដើម្បីជាមាគ៌ានាំទៅកាន់ការបកស្រាយ យើងបានលើកយកបញ្ហាគតិយុត្តមួយចំនួនផងដែលក្នុង យើងបានចោទឡើងថា **តើអាជ្ញាធរជាតិព្រះវិហារបង្កើតឡើងក្នុងគោលបំណងអ្វី? ព្រមទាំងមានតួនាទី និងភារកិច្ចអ្វីខ្លះ?**

ដើម្បីជាគន្លឹះសម្រាប់ឱ្យអ្នកអានងាយយល់នូវខ្លឹមសារនៃអត្ថបទស្រាវជ្រាវនេះ យើងគួរគប្បីយល់ន័យនៃពាក្យគន្លឹះមួយចំនួនសិន។ ដោយយោងទៅតាមវចនានុក្រមខ្មែរ **សម្តេចសង្ឃរាជ ជួន ណាត** ចំពោះពាក្យថា " ភារកិច្ច " គឺកិច្ចជាភារៈដែលខ្លួនទទួលរ៉ាប់រង។ ចំនែកឯពាក្យ " តួនាទី " វិញគឺមានន័យថាជាកិច្ចការដែលបុគ្គលត្រូវរ៉ាប់រងភារៈរបស់ខ្លួន ម្យ៉ាងវិញទៀតចំពោះពាក្យ "អាជ្ញាធរជាតិ" វិញ គឺជាអ្នកទ្រទ្រង់នូវអាជ្ញា ជាអ្នកកាន់អំណាច តាមសិទ្ធិដែលខ្លួនបានទទួលពេញលក្ខណៈ។

ជាការពិតណាស់គ្រប់អត្ថបទសិក្សាស្រាវជ្រាវ និងការបកស្រាយតែងតែបានភ្ជាប់មកនូវគោលបំណងជាក់លាក់មួយ ហើយអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវនេះក៏បានផ្តល់ឱ្យអ្នកអាននូវពុទ្ធិក្នុងការសិក្សាបន្ថែមទៀត។ ជាងនេះទៅទៀតស្នាដៃស្រាវជ្រាវមួយនេះនិងជួយដល់អ្នកអានក្នុងការយល់ដឹងអំពីអ្វីខ្លះ ដែលជាតួនាទី និងភារកិច្ចនៃអាជ្ញាធរជាតិព្រះវិហារ ព្រមទាំងឆ្លុះបញ្ចាំងពីគោលបំណងនៅក្នុងការបង្កើតឱ្យមានអាជ្ញាធរនេះឡើង។ លើសពីនេះទៅទៀត អ្នកអានអាចយល់ដឹងបានកាន់តែច្បាស់នូវរាល់មន្ទិលសង្ស័យដែលទាក់ទងនឹងតួនាទី និងភារកិច្ចរបស់អាជ្ញាធរព្រះវិហារ។

### ៣.គោលបំណងនៃការស្រាវជ្រាវ

សម្រាប់ការសិក្សាស្រាវជ្រាវនីមួយៗតែងតែមានគោលដៅ និងទិសដៅនៅក្នុងការស្រាវជ្រាវយ៉ាងពិតប្រាកដ និងជាក់លាក់មួយ។ មិនតែប៉ុណ្ណោះ ក៏អាចជាជំនួយដល់អ្នកអាននៅក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៀតផងដែរ។ ម្យ៉ាងវិញទៀត ដោយសារតែអាជ្ញាធរជាតិព្រះវិហារជាអាជ្ញាធរមួយដែលដើរតួយ៉ាង សំខាន់ក្នុងការការពារ ថែរក្សា និងអភិវឌ្ឍន៍ប្រាសាទព្រះវិហារដែលជាសម្បត្តិបេតិកភណ្ឌជាតិ ហើយយើងសង្កេតឃើញថា ការយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិព្រះវិហាររបស់សិស្ស-និស្សិត ក៏ដូចជាសាធារណៈជននៅមានកម្រិតនៅឡើយ។ មូលហេតុទាំងអស់នេះហើយដែលជាកត្តាជម្រុញ នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ ព្រមទាំងគោលបំណងដ៏ចម្បងនៃការស្រាវជ្រាវគឺ ចង់ពង្រីកការយល់ដឹងរបស់សិស្ស និស្សិត និងធ្វើឱ្យការយល់ដឹងអំពីអាជ្ញាធរនេះកាន់តែទូលំទូលាយឡើងទាំងអស់គ្នា ។

### ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការកម្រិតនូវទំហំ និងដែនកំណត់នៃការបកស្រាយ ជាកត្តាសំខាន់ណាស់ដើម្បីចាកផុតពីការបកស្រាយហួស ឬចាកប្រធានបទ។ ជាការពិតការកំណត់ពីទំហំ និងដែនកំណត់នៃការស្រាវជ្រាវ យើងបានកំណត់យកចាប់ពីប្រវិត្តិនៃវិវាទរបស់ប្រាសាទព្រះវិហារដែលជាមូលហេតុក្នុងការបង្កើតអាជ្ញាធរជាតិព្រះវិហារ និងដំណើរការនៃការប្រព្រឹត្តទៅនៃតួនាទី ព្រមទាំងភារកិច្ចនៃអាជ្ញាធរជាតិព្រះវិហារតែប៉ុណ្ណោះ។

### ៥. សារៈសំខាន់នៃការស្រាវជ្រាវ

អត្ថបទស្រាវជ្រាវមួយនេះនឹងជួយដល់អ្នកអានអោយយល់ដឹងនូវតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិព្រះវិហារ។ បន្ទាប់ពីទទួលបានចំណេះដឹងជាមូលដ្ឋានគ្រឹះនៃអត្ថបទស្រាវជ្រាវនេះហើយ អ្នកអាននឹងអាចបង្កើនការយល់ដឹងកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត ជាពិសេសនិងអាចសហការគ្នាជាមួយអាជ្ញាធរជាតិព្រះវិហារ ក្នុងការអភិរក្ស ថែរក្សា និងការពារសម្បត្តិបេតិកភណ្ឌមួយនេះឱ្យបានស្ថិតស្ថេរគង់វង្ស លើសពីនេះទៅទៀត អ្នកអានក៏អាចចូលរួមក្នុងការផ្សព្វផ្សាយអំពីតួនាទី និង ភារកិច្ចរបស់អាជ្ញាធរនេះផងដែរ ជាពិសេសចំពោះប្រជាជនដែលស្ថិតនៅតំបន់នោះផ្ទាល់តែម្តង គាត់គួរតែយល់ដឹងពីអាជ្ញាធរនេះ ដើម្បីចៀសវៀងការប៉ះទង្គិចគ្នាជារឿយៗនៅពេលដែ អាជ្ញាធរជាតិព្រះវិហារចុះអនុវត្តការងាររបស់គាត់។

### ៦. វិធីសាស្ត្រស្រាវជ្រាវ

ជាក់ស្តែង នៅក្នុងការស្រាវជ្រាវមានឯកសារនានាពាក់ព័ន្ធជាច្រើនដែលបកស្រាយពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិព្រះវិហារ ព្រមទាំងលិខិតគតិយុត្តនានា។ ជាការពិតណាស់ ការវិភាគ

និងការស្រាយបំភ្លឺគឺ យោងទៅលើអនុក្រឹត្យដែលទាក់ទងនឹងអាជ្ញាធរនេះ ក៏ដូចជាគេហទំព័រផ្សេងៗ ដែលពិពណ៌នាអំពីតួនាទី និងភារកិច្ច ព្រមទាំងសមិទ្ធិផលដែលទទួលបានពីការខិតខំប្រឹងប្រែង របស់អាជ្ញាធរជាតិព្រះវិហារ។ មិនតែប៉ុណ្ណោះ ការស្រាវជ្រាវក៏បានប្រមូលពត៌មានពីការសិក្សាលើមេរៀន នៅក្នុងនីតិនគរូបនីយកម្ម ដែលបានកំណត់ពីអាជ្ញាធរជាតិព្រះវិហារ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងខាងលើនេះ អត្ថបទស្រាវជ្រាវនេះបានតាក់តែងឡើងក្រោមរូបភាពជា ២ ជំពូក។ ដែល **ជំពូក១** បង្ហាញពីទិដ្ឋភាពទូទៅនៃអាជ្ញាធរជាតិព្រះវិហារ។ នៅក្នុងជំពូក១នេះក្រុមយើងបានបកស្រាយអំពី ប្រវិត្តិនិងគោលបំណងដែលនាំឱ្យមានការកកើតអាជ្ញាធរជាតិព្រះវិហារ។ ចំណែកឯ **ជំពូក២** បានសរបញ្ជាក់ឱ្យឃើញពីតួនាទី និងបេសកកម្មរបស់អាជ្ញាធរជាតិព្រះវិហារ ដែលក្នុងនោះផងដែរបានបកស្រាយពីតួនាទី និងបេសកកម្មទូទៅនៅក្នុងស្ថាប័នអាជ្ញាធរជាតិព្រះវិហារ ព្រមទាំង តួនាទី និងបេសកកម្មរបស់អគ្គនាយកដ្ឋាននានាដែលពាក់ព័ន្ធនឹងអាជ្ញាធរជាតិជាតិព្រះវិហារ រួមបញ្ចូលទាំងសមិទ្ធិផលនានាដែលអាជ្ញានេះសម្រេចបាន។

# ជំពូកទី១

# និដ្ឋភាពទូទៅ

អាជ្ញាធរជាតិព្រះវិហារ (អ ជ ព វ) ជាពាក្យកាត់មួយដែលបានមកពីពាក្យពេញថាអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ។ អាជ្ញាធរនេះត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងដោយអនុក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្ដីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ។ ម្យ៉ាងវិញទៀត អាជ្ញាធរនេះមានតួនាទីយ៉ាងសំខាន់ក្នុងការការពារ និងថែរក្សាមរតកបេតិកភណ្ឌជាតិឱ្យបានគង់វង្សយូរអង្វែង មិនតែប៉ុណ្ណោះត្រូវអភិវឌ្ឍរមណីយដ្ឋាននៅតំបន់ប្រាសាទព្រះវិហារឱ្យមានការរីកចំរើន និងប្រកបដោយប្រសិទ្ធិភាពផងដែរ។ អាជ្ញាធរជាតិនេះ ត្រូវបានទទួលការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតពីរាជរដ្ឋាភិបាលជាពិសេសពីសំណាក់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងពីឯកឧត្ដមឧបនាយករដ្ឋមន្ត្រី សុខ អាន។ លើសពីនេះទៀតក៏មានការគាំទ្រពីសហគមន៍អន្តរជាតិ និងមានការជួយឧបត្ថម្ភពីសំណាក់អ្នកបច្ចេកទេសអង្គការយូណេស្កូទៀតផង។

## ១.១ កត្តាជម្រុញឱ្យមានការបង្កើតអាជ្ញាធរជាតិព្រះវិហារ

ការបង្កើតអាជ្ញាធរជាតិព្រះវិហារ ត្រូវបានបង្កើតឡើងដោយសារមានមូលហេតុជាច្រើន ដែលជាកត្តាជំរុញក្នុងការបង្កើតអាជ្ញាធរនេះឡើងមក។ កត្តាដែលចម្បងជាងគេក្នុងការជំរុញឱ្យបង្កើតអាជ្ញាធរនេះ គឺទាក់ទងនឹងប្រាសាទព្រះវិហារ ។ ហើយអ្វីដែលសំខាន់ជាងនេះទៅទៀតនោះ ប្រាសាទព្រះវិហារយើងមានវិវាទជាច្រើនលើកច្រើនសារតាំងពីសម័យបុព្វបុរសមកម្លេះ ប៉ុន្តែនៅតែបន្តមកដល់បច្ចុប្បន្ននេះ។ រឿងក្ដីជម្លោះប្រាសាទដ៏ល្បីល្បាយមួយដែលពិភពលោកទាំងអស់បានដឹង និងបានស្គាល់ពីប្រាសាទព្រះវិហារកាន់តែច្បាស់នោះគឺជម្លោះរវាងប្រទេសកម្ពុជាយើង និងប្រទេសថៃដែលប្រទេសនេះបានឈ្លានពានចូលបូរណភាពដែនដីរបស់យើងនឹងបានអះអាងថា ប្រាសាទព្រះវិហារជាប្រាសាទរបស់ខ្លួន ហើយស្ថិតនៅលើទឹកដីរបស់ខ្លួន។ ជម្លោះនេះបានចោទជាចម្ងល់ថា មូលហេតុអ្វីបានជារឿងក្ដីប្រាសាទព្រះវិហារជាកត្តាដ៏ចម្បងក្នុងការបង្កើតអាជ្ញាធរនេះ? ហើយចុះវិវាទរបស់ប្រាសាទព្រះវិហារ ជាមួយប្រទេសថៃនោះ តើទាក់ទងអ្វីនិងការបង្កើតអាជ្ញាធរព្រះវិហារ។ ដូចនេះដើម្បីឱ្យកាន់តែច្បាស់ពីបញ្ហាដែលចោទឡើងទាំងអស់នេះ ជាដំបូងយើងត្រូវយល់ដឹងពីប្រវិត្តិប្រាសាទព្រះវិហារជាមុនសិន ដែលយើងនឹងសិក្សានៅចំណុច (១.១.១) ហើយជំហានបន្ទាប់យើង និងសិក្សាឱ្យកាន់តែស៊ីជម្រៅទៀត ទៅលើប្រវិត្តនៃវិវាទប្រាសាទព្រះវិហារដែលមានក្នុងចំនុច(១.១.២)។

### ១.១.១ ប្រវត្តិប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារ មានទីតាំងស្ថិតនៅភូមិស្វាយជ្រុំ ឃុំកន្ទួត ស្រុកជាំក្សាន្តនៅលើជួរភ្នំដងរែក (ភ្នំព្រះវិហារ) ជាប់ព្រំប្រទល់ប្រទេសថៃ មានចម្ងាយ ១០៨គីឡូម៉ែត្រ ពីទីរួមខេត្តព្រះវិហារ (ស្រុកត្បែងមានជ័យ) តាមផ្លូវលេខ២១១។ ខេត្តព្រះវិហារបានបង្កើតឡើងនៅឆ្នាំ១៩៦៤ ដោយកាត់ដីពីខេត្តស្ទឹងត្រែង កំពង់ធំ និង សៀមរាប។ ខេត្តនេះគឺ នៅភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា និងជាខ្ពង់រាបដែលសំបូរទៅដោយព្រៃឈើ ភ្នំ ស្ទឹង ដងអូរ ហើយប្រាសាទព្រះវិហារមានទំហំ ៨០០ម គុណនឹង៥០០ម ស្ថិតនៅលើកំពូលភ្នំព្រះវិហារដែលមានកំពស់ ៦២៥ម នៅតាមជួរភ្នំដងរែកដោយមានចំណោទខ្លាំងពីផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងពីប្រទេសថៃ[2]។ ប្រាសាទព្រះវិហារមានច្រកចូល ៣ ទៅកាន់ប្រាសាទ៖

ច្រកទី១ ច្រកតាមប្រទេសយើង គឺចូលតាមស្វាយជ្រុំ ដែលផ្លូវចាស់មានកាំ ជណ្ដើរឡើងទៅកាន់កំពូលភ្នំដងរែក។

ច្រកទី២ ច្រកតាមប្រទេសយើងដដែលគឺតាមផ្លូវគ១ដែលជាផ្លូវជួសជុលចាក់បេតុងសម្រាប់ឡើងទៅកាន់ប្រាសាទព្រះវិហារ ។ បច្ចុប្បនេះ ប្រជាពលរដ្ឋនៅក្នុងខេត្ត ក៏ដូចជាអ្នករកស៊ីលក់ដូរនៅទីនោះភាគច្រើននាំគ្នាឡើងតាមផ្លូវនេះ ព្រោះងាយស្រួលក្នុងការធ្វើដំណើរឡើង។

ច្រកទី៣ ច្រកចូលតាមប្រទេសថៃ ដែលភ្ញៀវទេសចរណ៍អន្តរជាតិចូលចិត្តធ្វើដំណើរតាមច្រកនេះ។

ប្រាសាទព្រះវិហារ ជាប្រភេទរមណីយដ្ឋានប្រវិត្តិសាស្ត្រ ដែលពីដើមមានឈ្មោះថា ស្រីសិខរិស្វារៈ ប្រែថាបារមីភ្នំ។ ប្រាសាទនេះកសាងឡើងអស់រយៈពេល ៣០០ ឆ្នាំ ដោយចាប់ផ្ដើមកសាងនៅចុងសតវត្សទី ០៩ និងបញ្ចប់រួចរាល់ជាស្ថាពរនៅសតវត្សទី១២។ ប្រាសាទនេះកសាងឡើងដោយស្ដេច ៤ អង្គ៖

ព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០) ព្រះអង្គ បានកសាងប្រាសាទកណ្ដាល។ ព្រះបាទយសោវរ្ម័នទី១ បានបង្កើតរាជធានីយសោធរបុរៈ និងជាក្សត្រដែលចូលចិត្តសាងសង់ ប្រាសាទលើកំពូលភ្នំធម្មជាតិ។

ព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) ព្រះអង្គ បានសាងសង់អគារដ៏វែងនៅជិតប្រាសាទ កំពែងព័ទ្ធជុំវិញ និងគោបុរៈ។ យោងទៅតាមសិលាចារិករបស់ប្រាសាទ ព្រះបាទណសូរ្យវរ្ម័ន បានរៀបចំពិធីដើម្បីអញ្ជើញទេវភទ្រស្វរៈ ដែលគង់នៅវត្តភូ (ប្រទេសឡាវបច្ចុប្បន្ន) មកគង់នៅជាមួយ នឹងទេវស្រីសខរីស្វារៈដើម្បីជួយការពារ និងថែរក្សាអាណាចក្រខ្មែរ និងប្រជារាស្ត្រ។

[2] សៀវភៅនីតិនគរូបនីវិទ្យា បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១១៩ ស្ដីពីគ្រឹះស្ថានសាធារណៈរដ្ឋបាល អាជ្ញាធរព្រះវិហារ

ព្រះបាទជ័យវរ្ម័នទី៦ (គ.ស.១០៨០-១១០៩) ព្រះអង្គបាន សាងសង់ បណ្ណាល័យពីរ និង ជួសជុលផ្នែកមួយចំនួននៃប្រាសាទ។

ព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០) ព្រះអង្គបានសាងសង់ព្រះលាន ដែលមាន នាគក្បាលពីរ រូបតោតាមផ្លូវ និងនាគជាច្រើនទៀតតាមជណ្តើរឡើង។ ព្រះអង្គក៏បានរៀបចំពិធី សម្ពោធប្រាសាទនិងចាត់ទុកជាកន្លែងគោរពសម្រាប់ព្រះមហាក្សត្រគ្រប់អង្គ។

អំពីរបៀបសំណង់វិញ លក្ខណៈគ្រប់បែបទាំងអស់នៃប្រាសាទ ដូចជាទម្រង់ផែនការ របៀប សំណង់ ដំណើរតាក់តែង លំអរូបផ្សេងៗ គឺជាសិល្បៈរបស់ខ្មែរទាំងស្រុង ឥតមានខ្ចីពីសិល្បៈ បរទេស យកមកបញ្ចូលលាយឡំឡើយ។

ចំពោះទីតាំងភូមិសាស្ត្រប្រាសាទនេះ សង់ឆ្ពោះទៅទិសខាងជើងហើយតួប្រាសាទកណ្តាល ដែលសង់នៅត្រង់គែមខ្ពស់រាប មានកំផែងព័ទ្ធជុំវិញតែមួយជាន់។ ប៉ុន្តែទោះបីឥតមានកំផែងដ៏ទៃក៏ ដោយ ប្រាសាទនេះគង់មានគោបុរៈ ៥ ដែរ[3]។

គោបុរៈទី១ គឺជាគោបុរៈនៃកំផែងទី១ ដែលភ្ជាប់ទៅ នឹងទីព្រះលានតាំងនៅពីខាងមុខ ឆ្ពោះ ទៅទិសខាងជើង។

គោបុរៈទី២ សំរាប់បើកឱ្យចេញពីទីលាន ហើយទៅដល់ជណ្តើរមួយតាំងនៅខាងជើង រួច មានតួផ្ទៃថ្នល់មួយ មាននាគនៅសងខាង។

នៅទីបំផុតនៃថ្នល់នេះ គេឃើញមានគោបុរៈទី៣ រួចមានជណ្តើរថ្មីមួយ ហើយនិងថ្នល់ មួយ ទៅដល់គោបុរៈទី៤ គឺឆ្ពោះទៅទិសខាងជើងជាធម្មតា។ ពីគោបុរៈទី៤ទៅ មានថ្នល់មួយ យ៉ាងវែងឆ្ពោះទៅគោបុរៈទី៥ ដែលមានជណ្តើរមួយពីខាងមុខ។

ពីខាងកើតនិងពីខាងលិចនៃកំផែងទី១ មានសង់អាគារពីរខ្នងភ្ជាប់នៅនោះ។ ក្នុងទីលាន ខាងមុខកំផែងទី១ មានបណ្ណាល័យពីរខាងមុខគោបុរៈទី១។ មានសាលវែងពីរសន្ធឹងពីខាងជើងទៅ ខាងលិច ត្រង់គោបុរៈទី៣។

### ១.១.២. ប្រវត្តិនៃវិវាទប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារគឺជាកន្លែងវប្បធម៌ និងប្រវត្តិសាស្ត្រមួយ ហើយបារាំងបានកាត់ ប្រាសាទ ព្រះវិហារទៅឱ្យថៃក្នុងឆ្នាំ១៩៥៤។ ប្រាសាទនេះត្រូវបានយកត្រឡប់មកឱ្យប្រទេសកម្ពុជាវិញ នៅ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្នុងការវិនិច្ឆ័យប្រគល់ឱ្យដោយតុលាការអន្តរជាតិនៅទីក្រុង ឡាអេ

[3]សៀវភៅស្តីពីការកំណត់អំពីបញ្ហាព្រះវិហារ រៀបរៀងដោយគណៈបេសកកម្មអចិន្ត្រៃនៃប្រទេសកម្ពុជាប្រចាំនៅអង្គការ សហប្រជាជាតិ ទំព័រទី២៥

ប្រទេសហូឡង់[4]។ មិនតែប៉ុណ្ណោះសាលដីកានេះគឺជាសេចក្តីសម្រេចនៅក្នុងការកាត់ក្តីរឿងប្រាសាទព្រះវិហារ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅពេលដែលថៃ បានធ្វើការចូលឈ្លានពានកាន់កាប់ប្រាសាទព្រះវិហារនៅក្នុងកំឡុងទសវត្សឆ្នាំ១៩៥០ ។ ប៉ុន្តែមុននិងទទួលបានជោគជ័យក៏មានឧបសគ្គជាច្រើនក្នុងការទាមទារប្រាសាទព្រះវិហារត្រលប់មកវិញ។ មូលហេតុដែលនាំឱ្យទទួលបានជោគជ័យ ក្នុងការទាមទាររបស់បារាំងយកទឹកដីខ្មែរត្រលប់មកវិញបានអាចបណ្តាលមកពីការដាក់សម្ពាធរបស់ប្រទេសមហាអំណាចមួយចំនួនផងដែលទៅលើប្រទេសថៃ ជាពិសេសគឺសហរដ្ឋអាមេរិកតែម្តង។ សន្ធិសញ្ញាក្រុងវ៉ាស៊ីនតោនចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៦ ជាកត្តាសំខាន់ដែលតម្រូវឱ្យប្រទេសថៃប្រគល់ទឹកដី ដែលខ្លួនវាយដណ្តើមកាន់កាប់ពីឆ្នាំ១៩៤១ ទៅប្រទេសជិតខាងវិញ។ សន្ធិសញ្ញានេះបានកំណត់ព្រំប្រទល់រវាងប្រទេសកម្ពុជាជាមួយនិងប្រទេសថៃ។ យើងដឹងហើយថាព្រំដែនរវាងប្រទេសកម្ពុជា ជាមួយប្រទេសថៃ ត្រូវបានកំណត់ដោយ កិច្ចព្រមព្រៀងពីរះ ១- អនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ,២- សន្ធិសញ្ញាចុះទី២៣ ខែមីនា ឆ្នាំ១៩០៧ ហើយកិច្ចព្រមព្រៀងទាំងពីរនេះក៏ត្រូវបានបញ្ជាក់បន្ថែមដោយសន្ធិសញ្ញាមិត្តភាពខាងពាណិជ្ជកម្ម និងនាវាចរណ៍ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩២៥ និងសន្ធិសញ្ញាមិត្តភាពខាងពាណិជ្ជកម្ម និងនាវាចរណ៍ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៣៧។

កិច្ចព្រមព្រៀងក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី១៧ ខែវិច្ឆិការ ឆ្នាំ១៩៤៦ បានចាត់ទុកអនុសញ្ញាឆ្នាំ១៩៤១ រវាងរដ្ឋាភិបាលបារាំង និងប្រទេសថៃជាមោឃៈ និងតម្រូវឱ្យរក្សាស្ថានភាពព្រំដែនដូចមុនឆ្នាំ១៩៤១។ ប៉ុន្តែប្រទេសថៃមិនព្រមប្រគល់ប្រាសាទព្រះវិហារឱ្យប្រទេសកម្ពុជាវិញឡើយ។

ការតម្រូវឱ្យរក្សាស្ថានភាពព្រំដែនដូចមុនឆ្នាំ១៩៤១ នេះគឺតម្រូវឱ្យប្រទេសថៃគោរពទៅលើព្រហ្មដែនចាស់ ដែលកំណត់តាមអនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នា១៩០៤ និងសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ ដែលកំណត់ព្រហ្មដែនជាក់លាក់មួយរវាងឥណ្ឌូចិនជាមួយនិងប្រទេសសៀម ក្នុងនោះមានបង្ហាញយ៉ាងច្បាស់ពីព្រំដែននៃប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត កិច្ចព្រមព្រៀងស្តីពីការកំណត់ព្រំដែនខាងលើនេះ ក៏ត្រូវបានបញ្ជក់បន្ថែមឡើងផងដែរ ដោយសន្ធិសញ្ញាឆ្នាំ១៩២៥ និងសន្ធិសញ្ញាឆ្នាំ១៩៣៧ ផងដែរ។

ដូចនេះហើយទើបប្រការ២ នៃកិច្ចព្រមព្រៀងបារាំង-សៀម ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤៦ បញ្ជាក់ថា ដែនដីឥណ្ឌូចិន ជាកម្មវត្ថុនៃអនុសញ្ញាត្រូវផ្ទេរមកឱ្យរាជការបារាំងវិញ ហើយកិច្ចប្រាស្រ័យ

[4] សៀវភៅស្តីពី ឯកសារសង្ខេបស្តីពីប្រាសាទព្រះវិហារ របស់លោក ស៊ន សំណាង និងលោក រស់ ចន្ទ្រាបុត្រ ទំព័រ៨ និងមាននៅក្នុងសាលដីការបស់តុលាការអន្តរជាតិឆ្នាំ១៩៦២

ទាក់ទងខាងការទូត បានត្រូវស្ថាបនាឡើងវិញ ចំណែកការទាក់ទងរវាងប្រទេសបារាំង និងប្រទេសសៀមតម្រូវឱ្យ មានឡើងវិញដែរដោយអនុវត្តទៅតាមសន្ធិសញ្ញាចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៣៧។

តំបន់ប្រាសាទព្រះវិហារបន្ទាត់ព្រំដែនបានសម្រេចតាមអនុសញ្ញាឆ្នាំ១៩០៤ ហើយបន្ទាត់ព្រំដែននោះបានទទួលការបញ្ជាក់បន្ថែមពីសន្ធិសញ្ញាឆ្នាំ១៩០៧ ដែលក្នុងនោះមានពិធីការមួយដាក់ភ្ជាប់មកជាមួយចាប់តាំងពីចំណុចមួយ ដែលស្ថិតនៅលើជួរភ្នំដងរែក (ចំណុចនេះស្ថិតនៅផ្នែកខាងលិចប្រាសាទព្រះវិហារនោះ) ព្រំដែនដែលគណៈកម្មការកំណត់ព្រំប្រទល់ដែនលើកមុនបានកំណត់ហើយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩០៧។

តាមប្រការ៣ នៃអនុសញ្ញាបារាំង-សៀមចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងប្រទេសសៀមត្រូវធ្វើឡើង ដោយគណៈកម្មាការចម្រុះមួយ ដែលតែងតាំងដោយប្រទេសបារាំង និងសៀម រយៈពេល ៤ខែក្រោយ សន្ធិសញ្ញាឱ្យសច្ចានុមតិការងារនេះបានតាំងនៅជាច្រើនឆ្នាំ ហើយបើកការប្រជុំជាច្រើនលើក។ ការងារទាំងឡាយ ដែលគណៈកម្មាការបានសម្រេចការងាររបស់ខ្លួនមានពោល ដោយសង្ខេបក្នុងសេចក្តីកត់ហេតុទាំងឡាយជាអាទិ៍មានដូចជា សេចក្តីកត់ហេតុចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩០៤ សេចក្តីកត់ហេតុចុះថ្ងៃទី០៣ ខែមករា ឆ្នាំ១៩០៧ សេចក្តីកត់ហេតុចុះថ្ងៃទី១៨និង១៩ ខែមករា ឆ្នាំ១៩០៧ និងសេចក្តីកត់ហេតុចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩០៧។

នៅក្នុងសេចក្តីកត់ហេតុទាំងនេះបានចង្អុលប្រាប់ថា ក្នុងតំបន់ភ្នំដងរែកបន្ទាត់ព្រំដែនរលាយចូលជាមួយបន្ទាត់បែងចែកទឹក។ សូមបញ្ជាក់ថាផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិន និងប្រទេសសៀមបានស្ថាបនាឡើងជាពីរពេល ផែនទីលើកដំបូង បានស្ថាបនាឡើងដោយអនុវត្តន៍ទៅតាមអនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ស្ថិតនៅក្រោមការដឹកនាំរបស់លោក លីយ៉ឺតឺណង់ កូឡូណែល ប៉ែរណា។ ផែនទីនេះបង្ហាញពីព្រំប្រទល់ថ្មីទាំងអស់ដែលមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣នៃអនុសញ្ញា។ ផែនទីលើកទីពីរ ត្រូវបានស្ថាបនាឡើងដោយគណៈបេសកកម្មលោក ម៉ុងហ្គ័រ តាមសន្ធិសញ្ញាចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧។ ផែនទីនេះត្រូវចប់ត្រឹមជួរភ្នំដងរែក គ្រង់តម្រាយថ្មី (នៅឆ្នាំ១៩០៧) យកតាមព្រំប្រទល់ដែនចាស់ឆ្នាំ១៩០៤ ឥតមានកែប្រែអ្វីឡើយ។

ដូច្នេះដើម្បីរកទីតាំងតំបន់ព្រះវិហារ (ប្រាសាទព្រះវិហារ) ត្រូវផ្អែកលើផែនទីដំបូងពិសេសនៅក្នុងសន្លឹកសរសេរថា ដងរែក។ ការពិនិត្យការបង្ហាញភស្តុតាង យ៉ាងជាក់ច្បាស់ថាប្រាសាទព្រះវិហារនៅក្នុងដែនដីខ្មែរ។ ម្យ៉ាងទៀតក៏មានផែនទីសៀមមួយ (ខ្នាត១/២០០០០០) ដែលត្រូវក្រុមភូមិសាស្ត្រសៀមបានស្ថាបនាឡើងគ្រប់សន្លឹកលេខ៤៩ នៃផែនទីនេះបានចុះនិទ្ទេសដ៏ពិតប្រាកដថា ទីកន្លែងប្រាសាទព្រះវិហារនៅខាងក្នុងដែនដីខ្មែរ។ ផែនទីសៀមនេះផ្សាយចេញពីការងារនៃគណៈកម្មការ

ខាងកំណត់ព្រំដែន បង្ហាញភស្តុតាងឱ្យឃើញថា រាជការសៀម បានទទួលស្គាល់ជាផ្លូវការនូវតំបន់ព្រះវិហារជាទឹកដីរបស់ខ្មែរ។ ផ្នែកនៃផែនទីបារាំងទាំងពីរ និងផែនទីសៀមពិតជាមិនសមស្របគ្នានូវចំនុចមួយចំនួនមែន ប៉ុន្តែវាបានបង្ហាញឱ្យឃើញថាមានការប្រហាក់ប្រហែលគ្នាជាច្រើន ព្រោះប្រាសាទព្រះវិហារមានដែនកំណត់ជាក់ច្បាស់ក្នុងផែនទីទាំងពីរនេះថា " ព្រំប្រទល់នៅខាងជើងដាច់ណាត់ពីប្រាសាទព្រះវិហារចម្ងាយប្រហែល៥០០ម៉ែត្រ "[5]។

ចំនុចដែលបានលើកឡើងខាងលើនេះ ជាការបង្ហាញពីការព្រមព្រៀងគ្នារវាងប្រទេសបារាំង និងប្រទេសសៀមដោយទទួលស្គាល់តំបន់ប្រាសាទព្រះវិហារមានលក្ខណៈជាខ្មែរយ៉ាងពិតប្រាកដ។

ប៉ុន្តែទោះបីជាមានបទបញ្ញត្តិយ៉ាងច្បាស់លាស់ តាមរយៈកិច្ចព្រមព្រៀងផ្សេងៗ និងមានសំណៅផែនទីស្ថាបនាឡើងដោយអនុវត្ត ទៅតាមកិច្ចព្រមព្រៀងទាំងឡាយនោះ យ៉ាងណាក្តីក៏ប្រទេសថៃក្រោយមកហាក់ដូចជាបានបំភ្លេចចោលនូវបញ្ហាទាំងនេះ ហើយតាំងខ្លួនជាម្ចាស់លើប្រាសាទព្រះវិហារទៅវិញ។ ចំពោះមូលហេតុដែលនាំឱ្យប្រទេសថៃគិតដូច្នេះអាចបណ្តាលមកពី ៖

- ប្រាសាទព្រះវិហារជាស្នាដៃសិល្បៈមួយយ៉ាងល្អឥតខ្ចោះ។
- ក្រោយចប់សង្គ្រាមភ្លាមអាណានិគមបារាំងមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការការពារដែនដីអាណានិគមរបស់ខ្លួន ជាពិសេសមិនទាន់អាចកំណត់ព្រំដែន ឬពិនិត្យព្រំដែនឱ្យបានល្អឡើយ។ ម្យ៉ាងវិញទៀត សៀមមិនដែលទទួលស្គាល់ថាខ្លួនមានប្រភពមកពីសុខោទ័យ និងមិនដែលទទួលស្គាល់ស្នាដៃស្ថាបត្យកម្មខ្មែរម្តងណាឡើយ។

ដូច្នេះហើយបានជាប្រទេសថៃបានឆក់យកឱកាសនេះ ដោយធ្វើព្រងើយកន្តើយមិនព្រមប្រាសាទព្រះវិហារមកឱ្យខ្មែរវិញ ដូចកិច្ចព្រមព្រៀងចុះថ្ងៃទី១៧ ខែវិច្ឆការ ឆ្នាំ១៩៤៦ បានចែងឡើយ។ នៅពេលនោះហើយ រឿងវិវាទក៏លេចចេញជារូបរាងឡើង។ ទាក់ទងនឹងរឿងនេះ យើងសង្កេតឃើញមានការប្តូរគ្នាខាងលិខិតការទូតធំៗក៏កើតឡើងដែរ៖

នៅមុនពេលដែលប្រទេសកម្ពុជាបានឯករាជ្យឯកអគ្គរាជទូតនៃប្រទេសបារាំងប្រចាំទីក្រុងបាងកក បានតវ៉ាជាច្រើនលើកប្រឆាំងនឹងការប្រព្រឹត្តរបស់រាជការថៃ៖

-លិខិតកត់ហេតុលេខ ២៩/៤៩/c.ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៤៩តវ៉ាប្រឆាំងនឹងហេតុការណ៍ដែលរាជការប្រទេសថៃបានបញ្ជូនឆ្មាំម្នាក់ និងគូលីបីនាក់ឱ្យទៅកាប់ឆ្កាព្រៃចេញពីប្រាសាទព្រះវិហារ លិខិតកត់ហេតុប្រឆាំងនឹងការឈ្លានពានទឹកដីខុសច្បាប់នេះហើយដែលបញ្ជាក់ថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរទេ។

[5] គណៈបេសសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំនៅសហប្រជាជាតិ : កំណត់អំពីបញ្ហាព្រះវិហារ ដ,ឯ,ម ទំព័រ ១៩-២០

-លិខិតកត់ហេតុលេខ ៩៦/៤៩/c. ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៤៩ បញ្ជាក់បន្ថែមលើសេចក្តីតវ៉ាលើកមុនហើយស្នើសុំចំពោះ រដ្ឋមន្ត្រីក្រសួងការបរទេសថៃបំបាត់កុំឱ្យមានស្ថានការណ៍ប្រកប ដោយភាពសង្ស័យ ជាពិសេសសុំឱ្យឆ្មាំថៃដែលតាំងនៅក្បែរប្រាសាទនោះ ដកថយចេញពីប្រាសាទ។

-កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៤៩ តាមលិខិតលេខ១៩៧ លោក ឡេអុង ម៉ាសាល់ ជាឯកអគ្គរាជទូតនៃប្រទេសបារាំងប្រចាំក្រុងបាងកក បានជូនដំណឹងដល់ស្នងការជាន់ខ្ពស់ប្រទេសបារាំងប្រចាំប្រទេសឥណ្ឌូចិនថា ភ្នាក់ងាររាជការម្នាក់នៃស្ថានទូតរបស់លោក បានបង្ហាញផែនទីកំណត់ព្រំប្រទល់ដែន ១/២០០.០០០ ចំពោះអគ្គនាយកនៃមន្ទីរខាងទិសបូព៌ា នៅមន្ទីររដ្ឋមន្ត្រីថៃខាងក្រសួងការបរទេស។ ភ្នាក់ងាររាជការនេះទទួលស្គាល់ទុកការតវ៉ាទាមទារនៃប្រទេសកម្ពុជាថាពិតជាមានភាពត្រឹមត្រូវ និងបានបញ្ជាក់ថាផែនទីទាំងឡាយ ដែលបានផ្ញើរមកត្រូវបានគេដាក់ឱ្យគណៈរដ្ឋមន្ត្រីហើយ និងបានបញ្ជាក់ថា ស្ថានទូតនៃប្រទេសបារាំងនឹងទទួលបាននូវសេចក្តីពេញចិត្តនៅពេលក្រោយជាមិនខាន។

-លិខិតកត់ហេតុលេខ ១១៨០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៥០ របស់ស្ថានទូតប្រទេសបារាំងប្រចាំក្រុងបាងកក បានផ្ញើរជូនរដ្ឋាភិបាលថៃដើម្បីរំលឹកអំពីលិខិតដែលខ្លួនបានផ្ញើរទៅក្នុងពេលមុន[6]។

សេចក្តីតវ៉ាចំពោះរាជការថៃនេះ ពុំបានលេចចេញជាលទ្ធផលវិជ្ជមានបន្តិចណាសោះឡើយ រាជការថៃហាក់ដូចជាមិនអើពើចំពោះការស្នើសុំ និងការជូនដំណឹងរបស់ភាគីបារាំងទេ។ ម៉្យាងវិញទៀតរឿងប្រាសាទព្រះវិហារក៏ត្រូវបានគិតគូឡើងវិញដោយរាជរដ្ឋាភិបាលកម្ពុជាក្រោយពេលដែលប្រទេសកម្ពុជាបានឯករាជពីប្រទេសបារាំង។ ជាងនេះទៅទៀត ការតវ៉ាធ្វើដូចគ្នាទៅនឹងសេចក្តីតវ៉ាដែលអ្នកតំណាងទាំងឡាយរបស់រដ្ឋាភិបាលបារាំងផ្ញើរជូនរដ្ឋាភិបាលថៃ ដោយខិតខំអះអាងចំពោះសិទ្ធិចង់គ្រប់គ្រងលើប្រាសាទព្រះវិហារ ហើយថៃមទាំងបានបង្គាប់ឱ្យបញ្ជូនឆ្មាំគូលី ឬទាហ៊ានថៃមកត្រួតត្រាលើប្រាសាទ ព្រមទាំងធ្វើការហាមប្រាមឆ្មាំខ្មែរ ឬជនជាតិខ្មែរមិនឱ្យទៅកាន់កាប់ប្រាសាទនេះទៀតផង ជាក់ស្តែងយើងមើលឃើញតាមរយៈឯកសារខាងក្រោមនេះ៖

-លិខិតកត់ហេតុលេខ ១៤-DGP-X ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៥៥

-លិខិតកត់ហេតុលេខ ៣២៤៩/២៤៩៧ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៥៥

-លិខិតចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៥៥ លើកឯកអគ្គរាជទូតនៃប្រទេសកម្ពុជាប្រចាំក្រុមបាងកកផ្ញើរទៅមន្ទីររដ្ឋមន្ត្រីក្រសួងការបរទេសថៃ សុំឱ្យធ្វើអន្តរាគមន៍ដើម្បីឱ្យទាហ៊ានថៃដកថយពីតំបន់ព្រះវិហារដែលខ្លួនបានកាន់កាប់[7]។

[6] គណៈបេសសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំនៅសហប្រជាជាតិ៖ កំណត់អំពីបញ្ហាព្រះវិហារ ដ.ឯ.ម ទំព័រ ២៥-២៧។

ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជានៅតែពុំអាចបញ្ចប់ និងបញ្ឈប់ការប៉ុនប៉ងរបស់រដ្ឋាភិបាលថៃក្នុងការទទួលស្គាល់តំបន់ប្រាសាទព្រះវិហារជារបស់ខ្មែរនោះទេ។ ផ្ទុយទៅវិញផែនការរបស់ថៃកំណត់កន្លែងព្រំប្រទល់ដែនដីម្នាក់ឯង ហើយអភិរក្សព្រំដែននេះទុកយ៉ាងម៉ឺងម៉ាត់។ ចំណែកឯរាជការខ្មែរវិញក៏មិនបណ្តោយឱ្យរឿងនេះសាបរលាបឡើយហើយព្រមទាំងសម្តែងចេញឱ្យឃើញពីការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលខ្មែរក៏បានគិតឱ្យមនុស្សទៅកាន់កាប់តំបន់ប្រាសាទព្រះវិហារដើម្បីឱ្យសិទ្ធិរបស់ខ្លួនមានជារូបរាងឡើងដែរ ក្រោយពេលដែលទទួលបានឯករាជ្យពីបារាំងមកនោះ។ ដោយហេតុមានការពិបាកនឹងចូលទៅដល់តំបន់នេះរដ្ឋាភិបាលក៏ឈប់បង្អង់សិន និងដោយហេតុថាជួនពេលនោះប្រទេសថៃបានតាំងខ្លួនចង់គ្រប់គ្រងតំបន់នេះយ៉ាងពិតប្រាកដ។ ដូច្នេះដើម្បីរួចផុតពីឧបទ្ទវហេតុខ្លះដែលនឹងធ្វើឱ្យខូចការប្រាស្រ័យទាក់ទងគ្នារវាងប្រទេសទាំងពីរ រដ្ឋាភិបាលខ្មែរមិនប៉ុនប៉ងទៅកាន់កាប់ប្រាសាទព្រះវិហារទេ ហើយយករឿងនេះដាក់ធ្វើការចរចារទ្វេភាគីវិញ។ បើកាលណាមិនទទួលបានជោគជ័យទេនោះ យើងនឹងត្រូវធ្វើពាក្យមួយប្តឹងទៅតុលាការអន្តរជាតិ។ តួយ៉ាងការខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា បានធ្វើឱ្យរដ្ឋាភិបាលថៃមានបំណងសម្រុះសម្រួលពីបញ្ហាព្រំដែនរបស់ថៃធ្វើឡើងដោយសង្ឃឹមថាខ្លួននឹងទទួលបានផលខ្លះពីកិច្ចសម្រុះសម្រួលនេះ ជាពិសេសសិទ្ធិលើតំបន់ប្រាសាទព្រះវិហារនេះឯង។ ប៉ុន្តែដោយ រដ្ឋាភិបាលកម្ពុជាយល់ព្រមពិភាក្សា បញ្ហាព្រំដែនអនុលោមតាមច្បាប់អន្តរជាតិ គឺព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃត្រូវតែគោរពទៅតាមអនុសញ្ញា និងសន្ធិសញ្ញានានាព្រមទាំងពិធីការផ្សេងៗ ដែលថៃបានចុះហត្ថលេខាយល់ព្រមជាមួយរដ្ឋាភិបាលបារាំងកន្លងមក។ ចម្លើយខាងលើនេះបានធ្វើឱ្យប្រទេសថៃប្រែស្ងាត់ទៅវិញ ព្រោះបើគោរពកិច្ចព្រមព្រៀងទាំងនោះប្រាកដជាប្រទេសខ្លួនមិនអាចគ្រប់គ្រងលើតំបន់ប្រាសាទព្រះវិហារនោះឡើយ។ រហូតដល់ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៥៧ រដ្ឋាភិបាលថៃបានយល់ព្រមធ្វើកិច្ចពិភាក្សាអំពីបញ្ហាព្រំប្រទល់នៃប្រទេសទាំងពីរ និងបានស្នើសុំបង្កើតគណៈកម្មការចម្រុះមួយសម្រាប់កំណត់ព្រំប្រទល់នេះ។ ហើយការទទួលយកសំណើនេះ បើពិនិត្យមើលទៅហាក់ដូចជាដំណឹងល្អមួយ ព្រោះអាចដោះស្រាយបញ្ហាចំពោះមុខបាន។ តែលទ្ធផលនៅតែមិនអាចដោះស្រាយបាន ហើយពេលពិភាក្សា ( ខែសីហា ឆ្នាំ១៩៥៨ ) រវាងប្រទេសទាំងពីរនៅទីក្រុងបាងកក អាជ្ញាធរថៃបានចាប់ផ្តើមយុទ្ធនាការសម្លុតបំភ័យ ដោយធ្វើការប្រមូលផ្តុំទាហ៊ាននៅតាមព្រំដែនកម្ពុជាធ្វើបាតុកម្មតវ៉ាប្រឆាំងយ៉ាងខ្លាំងក្លា និងការគំរាមគំហែងនៅស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ហើយរដ្ឋាភិបាលថៃក៏បញ្ជាក់ថា នឹងចាត់វិធានការយ៉ាងឃោឃៅប្រឆាំងប្រទេសកម្ពុជា។ យ៉ាងណាមិញការបរាជ័យផ្ទួនៗនេះ រដ្ឋាភិបាលកម្ពុជាបានសម្លឹងទៅដល់គោការណ៍

[7] គណៈបេសសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំសហប្រជាជាតិះ កំណត់អំពីបញ្ហាប្រាសាទព្រះវិហារ ទំព័រ ២៧-២៨។

គតិយុត្តវិញគឺ សម្រេចចិត្តថានឹងដាក់ពាក្យបណ្ដឹងទៅតុលាការអន្តរជាតិឱ្យវិនិច្ឆ័យ។ នៅជុំវិញបញ្ហានេះ យើងឃើញតាមរយៈដំណើរទស្សនកិច្ចជាផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសថៃ លោក ថាណាត់ ខូម៉ាន់ មកកាន់ប្រទេសកម្ពុជា នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៩ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូននូវជំនួយសារណាមួយ ដោយជម្រុញឱ្យមានដំណោះស្រាយទាក់ទងនឹងជម្លោះប្រាសាទព្រះវិហារ៖

១. រឿងក្ដីនឹងត្រូវដាក់ជូនទៅឱ្យតុលាការយុត្តិធម៌អន្តរជាតិវិនិច្ឆ័យ ហើយប្រទេសទាំងពីរនឹងព្រមទទួលយកសាលក្រមរបស់តុលាការ។

២. ប្រទេសថៃត្រូវដកកងទ័ពចេញពីប្រាសាទព្រះវិហារ តំបន់គ្មានយោធានឹងត្រូវបង្កើតនៅក្នុងតំបន់ប្រាសាទដែលមានអង្កត់ផ្ចិត៥គីឡូម៉ែត។ ប្រទេសកម្ពុជានឹងរក្សាសិទ្ធិអធិបតេយ្យរបស់ខ្លួនលើប្រាសាទ និងរក្សាសេរីភាពក្នុងការធ្វើទេសចរណ៍ផងដែរ។

សេចក្ដីស្នើសុំនេះមិនត្រូវបានរដ្ឋាភិបាលថៃឆ្លើយតបឡើយ អាស្រ័យហេតុនេះហើយ រដ្ឋាភិបាលកម្ពុជាដាក់ពាក្យបណ្ដឹងទៅតុលាការអន្តរជាតិ ICJ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៩[8]។ ដំណើរការសចវនាការពាក្យបណ្ដឹងនេះទំនងជាតុលាការមិនទាន់ធ្វើការវិនិច្ឆ័យបានភ្លាមទេ ជាងនេះទៅទៀត រដ្ឋាភិបាលថៃក៏បានធ្វើការប្ដឹងទាស់មិនទទួលស្គាល់ពីសមត្ថកិច្ចរបស់តុលាការដែលត្រូវបានបញ្ជូនមកក្រឡាបញ្ជីនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦០[9]។ ដោយហេតុថាមានការជំទាស់ការជំនុំជំម្រះមានការផ្អាកទៅវិញ ហើយនៅអំឡុងពេលនោះ រដ្ឋាភិបាលប្រទេសកម្ពុជាក៏បានប្ដឹងជំទាស់នឹងរដ្ឋាភិបាលថៃដែរ ចំណែកឯសវនការវិញបានបន្តរហូតដល់ឆ្នាំ១៩៦១ និងបញ្ចប់នៅឆ្នាំ១៩៦២។

សូមបញ្ជាក់ថា គណៈប្រតិភូខាងភាគីកម្ពុជាដឹកនាំដោយឯកឧត្តម ទ្រឿង កាង (សមាជិកឧត្តមក្រុមប្រឹក្សារាជបល្ល័ង្ក ) និងមានមេធាវីការពារក្ដី៣រូបគឺ៖

-លោក ឌិន អាជេហ្សិន ( Dean Acheson ) ជាមេធាវីនៃតុលាការកំពូលសហរដ្ឋអាមេរិក និងជាអ្នកជំនាញអំពីច្បាប់អន្តរជាតិ។

-លោក រ៉ូហ្សេ ពិនតូ ( Roger Pinto ) សាស្ត្រាចារ្យមហាវិទ្យាល័យ នីតិសាស្ត្រក្រុងប៉ារីស។

-លោក ប៉ូល រើទែរ ( Paul Reuter ) សាស្ត្រាចារ្យមហាវិទ្យាល័យ នីតិសាស្ត្រក្រុងប៉ារីស។

-លោក សួន បុន អតីតអភិបាលខេត្តកំពង់ធំ ពីឆ្នាំ១៩៤៨-១៩៥៤ ជាសាក្សី។

---

[8] គណៈបេសសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំនៅសហប្រជាជាតិ៖ កំណត់អំពីបញ្ហាព្រះវិហារ ដ.ឯ.ម ទំព័រ ៦៩-៧០។

[9] ការសែតកម្ពុជា ឆ្នាំទី២០ លេខ៩៣៣១ ចុះថ្ងៃទី២៧ ឧសភា ១៩៦០ រឿងប្រាសាទព្រះវិហារ នៅចំពោះមុខតុលាការអន្តរជាតិ បណ្ណារដ្ឋានជាតិ ប្រអប់លេខ៣៧។

ចំណែកឯខាងភាគីថៃវិញ មានការចូលរួមដោយ មុំសេនី ប្រាមោជ ជាមេធាវីការពារក្តីរបស់ប្រទេសថៃ និងមានមេធាវីដូចជា៖

-លោក ហ្វ្រែង សុសឃីស អតីតជាប្រធានមេធាវីអង់គ្លេស រួមជាមួយលោកសាស្ត្រាចារ្យ រ៉ូលីន ដែលជាសាស្ត្រាចារ្យផ្នែកច្បាប់នៃតុលាការឧទ្ធរណ៍ក្រុងប្រ៊ុសសែល ( Brussels )

ការជំនុំជំម្រះក្នុងរឿងក្តីនេះ តុលាការពេញចិត្តនឹងជំនុំជំម្រះតាមរយៈផែនទីព្រំប្រទល់ដែលមានចំណងជើងថា "ដងរែក" ត្រូវបានបោះពុម្ពក្នុងឆ្នាំ១៩០៨។ ទាក់ទងនឹងផែនទីនេះ រដ្ឋាភិបាលក្រុងបាងកកបានចោទប្រកាន់ថា ខ្សែបន្ទាត់បែងចែកទឹកដីមានភាពមិនប្រក្រតី ដោយយោងតាមការអង្កេតឯករាជ្យមួយនៅឆ្នាំ១៩៣៤ និងឆ្នាំ១៩៣៥។ ទស្សនៈដែលបានបង្កើតឡើងនេះគ្រាន់តែជាលេសបង្កើននូវបញ្ហាយ៉ាងពិតប្រាកដ[10]។ ជាក់ស្តែងនៅថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៦២ មេធាវីរបស់ប្រទេសថៃបានបន្ថែមនូវបញ្ហាលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ហើយទាក់ទងនឹងភូមិពីរទៀតគឺ ភូមិដីក្រហម និងភូមិគល់ ដែលភូមិទាំងពីរនេះបានលេចចេញយ៉ាងច្បាស់ថា ស្ថិតនៅក្នុងទឹកដីប្រទេសកម្ពុជាគ្រប់ផែនទីផ្លូវការទាំងអស់។ ការបន្ថែមបញ្ហានេះ គ្រាន់តែជាលេសចង់បញ្ជាក់ឱ្យឃើញថាផែនទីដែលបានប្រើប្រាស់មកនេះប្រាកដជាមានបញ្ហាពិតប្រាកដមែន ហើយយ៉ាងណាតំបន់ព្រះវិហារក៏ដូចគ្នាដែរ។ ប៉ុន្តែដោយហេតុថា ផែនទីនេះបានប្រើប្រាស់អស់រយៈពេលជាង៥០ឆ្នាំមកហើយ ដូច្នេះរដ្ឋាភិបាលក្រុងបាងកកមិនអាចធ្វើការទាមទារ និងបន្តការទាមទារទៀតទេ។

ដោយមើលឃើញពីទង្វើឈ្លានពានរបស់ថៃ មកលើព្រះរាជាណាចក្រកម្ពុជាបែបនេះ ទើបសម្តេចព្រះនរោត្តម សីហនុ បានដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌ អន្តរជាតិបានចេញសាលដីកាមួយក្នុងឆ្នាំ១៩៦២។ សាលដីកានេះគឺជាលិខិតគតិយុត្តិមួយដែលបានបង្ហាញពីភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់របស់កម្ពុជាលើប្រាសាទព្រះវិហារ។ លើសពីនេះទៅទៀតនៅក្នុងសាលដីកានេះបានសម្រេចនៅចំនុចពីរសំខាន់ៗគឺ៖

### ១. ប្រាសាទព្រះវិហារត្រូវស្ថិតនៅក្រោមអធិបតេយ្យរបស់កម្ពុជា

ដោយយោងទៅលើសេចក្តីសម្រេចរបស់តុលាការដោយសម្លេងចំនួន៩ទល់នឹង៣ (ចៅក្រមទាំងអស់មានចំនួន ១៥រូប ក្នុងនោះមាន៣រូបអនុបវាទ) តុលាការបានសម្រេចថា ប្រាសាទព្រះវិហារស្ថិតក្នុងទឹកដីក្រោមអធិបតេយ្យរបស់ប្រទេសកម្ពុជា[11]។ ពាក្យថាស្ថិតក្នុងទឹកដីក្រោមអធិបតេយ្យ របស់កម្ពុជា គឺជាការបញ្ជាក់យ៉ាងច្បាស់ថាទាំងប្រាសាទ ទាំងទឹកដីនៅតំបន់ប្រាសាទព្រះវិហារគឺជារបស់កម្ពុជា ហើយប្រទេសថៃគ្មានសិទ្ធិណាមួយលើទឹកដីនោះទេ។ ការកាត់ក្តីរបស់តុលាការ គឺផ្អែកទៅ

[10] Cambodia Commentary,/ Preah Vihear Case, Vol 11, No.2 (March-April 1962),Phnom Penh,p.22,NA,Box 353

[11] សាលដីការរបស់តុលាការអន្តរជាតិឆ្នាំ១៩៦២

លើផែនទីឧបសម្ព័ន្ធ១ ដែលបានគូសវាសឡើងនៅក្នុងឆ្នាំ១៩០៨ តាមរយៈអនុសញ្ញា១៩០៤ និង សន្ធិសញ្ញាឆ្នាំ១៩០៧ ដែលជាផែនទីកំណត់ខ្សែព្រំដែនរវាងប្រទេសទាំងពីរ។ ហេតុនេះព្រំដែនរវាង កម្ពុជា និងថៃដែលបានកំណត់ដូចនៅក្នុងផែនទីឆ្នាំ១៩០៨ គឺជាព្រំដែនស្របច្បាប់និងមានការទទួល ស្គាល់ជាលក្ខណៈអន្តរជាតិ។ តាមរយៈផែនទីឧបសម្ព័ន្ធ១ គ្មានបានកំណត់ពីតំបន់ ៤.៦គីឡូម៉ែត្រ ក្រឡា (តំបន់ ៤.៦គីឡូម៉ែត្រក្រឡា រួមមានវត្តកែវសិក្ខាគីរីស្វារៈ ភ្នំទ្រព្យ សំបុកឃ្មុំ និងវាលឥន្ទ្រីយ៍) ឬ តំបន់ត្រួតស៊ីគ្នានោះទេ នេះអាចបញ្ជាក់បានថាគ្មានតំបន់ត្រួតស៊ីគ្នា ដូចដែលប្រទេសថៃធ្វើការ អះអាងនោះទេ។ ការដែលថៃបានអះអាងថា ដីនៅតំបន់ប្រាសាទព្រះវិហារជាដី ស្ថិតនៅក្រោម អធិបតេយ្យរបស់ប្រទេសថៃនោះ គឺដោយផ្អែកទៅលើផែនទីដែលត្រូវបានគូសឡើងជាឯកតោភាគី ដោយប្រទេសថៃ។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសថៃថែមទាំងបានអះអាងថាប្រទេសកម្ពុជាបាន រំលោភលើអធិបតេយ្យរបស់ប្រទេសថៃថែមទៀតផង។

### ២.ប្រទេសថៃត្រូវដកកងទ័ពនិងកម្លាំងផ្សេងៗទៀតចេញពីតំបន់ប្រាសាទព្រះវិហារ

ដោយមានសម្លេង៩ ទល់នឹង៣ (ក្នុង៣រូបអនុបវាទ) តុលាការបានសម្រេចទៀតថាប្រទេស ថៃមានកាតព្វកិច្ចដកកម្លាំងទ័ព ឬប៉ូលីស ឬអ្នកថៃរក្សា ឬឆ្មាំដទៃទៀតដែលថៃបានដាក់នៅក្នុង ប្រាសាទ ឬតំបន់ក្បែរប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា។[12] ហើយដោយបោះឆ្នោតសម្លេង ៧ ទល់ ៥ រកឃើញថា ប្រទេសថៃមានកាតព្វកិច្ចប្រគល់សងមកឱ្យកម្ពុជាវិញនូវរាល់វត្ថុបុរាណគ្រប់ប្រភេទ ដែលបានបញ្ជាក់ក្នុង ឯកសារស្នើទី៥ របស់កម្ពុជាដែលត្រូវបាន យកចេញពីប្រាសាទឬតំបន់ប្រាសាទ ដោយអាជ្ញាធរថៃ ចាប់តាំងពីថ្ងៃកាន់កាប់ប្រាសាទ របស់ថៃ (ក្នុងឆ្នាំ១៩៥៤ មក)[13]។នេះជាបញ្ជារបស់ តុលាការយុត្តិធម៌អន្តរជាតិឱ្យ ប្រទេសថៃដកកងកម្លាំងទាហានទាំងឡាយ ដែលបានបញ្ជូនមកឱ្យ ឈ្លានពានចូលក្នុងដែនអធិបតេយ្យ របស់កម្ពុជានៅតំបន់ប្រាសាទព្រះវិហារ។

ការសម្រេចចិត្តរបស់តុលាការនេះ ជាការផ្តល់យុត្តិធម៌យ៉ាងត្រឹមត្រូវបំផុតចំពោះប្រទេស កម្ពុជា ប៉ុន្តែសម្រាប់ប្រទេសថៃវិញយល់ថាវាជារឿងអយុត្តិធម៌បំផុត ហើយបានបដិសេធមិនព្រម ទទួលយកសាលក្រមរបស់តុលាការ និងមានប្រតិកម្មជំទាស់យ៉ាងខ្លាំង។ សូមរំលឹកដែលថា នៅថ្ងៃ ទី១៦ ខែមិថុនា ឆ្នាំ១៩៦២ វេលាម៉ោង ១២ និង១៥នាទី លោកសេនាប្រមុខ សារិត ថា ណារ័ត្ន (Sarit Thanarat) នាយករដ្ឋមន្ត្រីថៃបានធ្វើសារពត៌មាន នៅឯព្រលានយន្តហោះ ឈាងម៉ៃ បាន បញ្ជាក់ថា "លោកបានចេញបញ្ជាដល់កងកម្លាំងរបស់លោក ដែលនៅឯប្រាសាទឱ្យធ្វើការរើត

[12] សាលដីការរបស់តុលាការអន្តរជាតិឆ្នាំ១៩៦២ ទំព័រទី៥០

[13] Ministry of Foreign Affairs , Aide-Memoire on Khmero-Thai Relation , op.cit ទំព័រទី៧២ និងសាលដីការរបស់តុលាការ អន្តរជាតិឆ្នាំ១៩៦២ ទំព័រទី៥០

បន្តឹង...ប្រទេសថៃ នៅតែមានអធិបតេយ្យភាពលើប្រសាទព្រះវិហារដដែល" លោកក៏បានបន្ថែមថា "ខ្ញុំបានចេញបញ្ជារួចជាស្រេចហើយ ដល់កងទ័ពឱ្យត្រៀមប្រឆាំងដល់ការរំលោភលើអធិបតេយ្យភាពរបស់ថៃ"។ មន្ត្រីជាន់ខ្ពស់របស់ថៃទាំងអស់ ដូចជាលោកឧត្តមសេនីយ៍ ថាណុម គី ទីកាឆន (Thanom Kittikachorn) រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោក ថាណាត់ ខូម៉ាន់ (Thanat Khaoman) រដ្ឋមន្ត្រីក្រសួងការបរទេសថៃ បានបញ្ជាក់បន្ថែមទៅលើសាលក្រមរបស់តុលាការថា "ហាក់ដូចជាផ្ទុយ នឹងយុត្តិធម៌អន្តរជាតិ" និងបានគូសបញ្ជាក់ទៀតថា ការសម្រេចចិត្តរបស់តុលាការក្រុងឡាអេមិនសមស្រប ព្រោះចាប់តាំងពីប្រាសាទនេះ ស្ថិតនៅក្នុងទឹកដីថៃវាមិនដែលរបូតចេញទៅទឹកដីកម្ពុជាឡើយ។ ហើយបានគំរាមកំហែងថា "នឹងធ្វើការបាញ់ប្រហារ មកលើជនជាតិកម្ពុជាណាដែលព្យាយាមចូល ទៅទឹកដីនៃតំបន់ប្រាសាទព្រះវិហារ"។ ចំណែកនៅឯទីក្រុងបាងកកវិញ អាជ្ញាធរថៃបានរៀបចំឱ្យការធ្វើបាតុកម្មតវ៉ាដ៏ធំមួយ ដើម្បីជំទាស់ដល់ការសម្រេចចិត្តរបស់ តុលារការអន្តរជាតិ [14]។

មិនតែប៉ុណ្ណោះ អន្ទាក់គ្រាប់បែកត្រូវបានបង្កើតឡើង នៅក្បែរប្រាសាទក្នុងទឹកដីកម្ពុជា។ ហើយប្រទេសថៃ មេដឹកនាំថៃ និងសារពត៌មានថៃបានពង្រីកនូវអរិភាពទៅនឹងប្រជាជាតិណា ដែលបានកាត់ក្តីឱ្យប្រទេសកម្ពុជាឈ្នះក្តី។ ឯកអគ្គរាជទូតថៃ ប្រចាំនៅទីក្រុងប៉ារីសត្រូវបានបញ្ជាឱ្យវិលត្រលប់មកប្រទេសថៃវិញ និងលុបចោលការផ្លាស់ប្តូរពាណិជ្ជកម្មបារាំង-ថៃ។ ប្រទេសប៉ូឡូញក៏ត្រូវទទួលរងដូចគ្នា នាវារបស់ជនជាតិប៉ូឡូញមិនត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងកំពុងផែថៃឡើយ។ ហើយសូម្បីតែសហរដ្ឋអាមេរិកក៏ត្រូវទទួលរងការរិះគន់យ៉ាងខ្លាំងពីប្រភពផ្លូវការដោយសារតែលោក ឌិន អាឆេ ហ្សិន ជួយគ្រាំទ្រការពារក្តីឱ្យខ្មែរនៅចំពោះមុខតុលាការ[15]។

អាកប្បកិរិយារបស់ប្រទេសថៃត្រូវបានមតិសកលលោកស្តីបន្ទោស នៅចំពោះមុខការកាត់ទោសពីសីលធម៌ និងការអំពាវនាវរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្រុងបាងកកត្រូវបានគេជម្រុញឱ្យលះបង់ចោលនូវតួនាទីក្នុងពីរបីថ្ងៃក្រោយមក។ ប្រទេសថៃនិងត្រូវគេបញ្ឈប់តួនាទីជាសមាជិកអង្គការសហប្រជាជាតិ ប្រសិនបើប្រទេសថៃមិនព្រមទទួលយកនូវសាលក្រមរបស់តុលាការអន្តរជាតិ និងបើមិនព្រមលះបង់ចោលនូវប្រាសាទព្រះវិហារ និងទឹកដីកម្ពុជាមួយចំនួនដែលខ្លួនបានកាន់កាប់ដោយខុសច្បាប់នោះទេ។ ហេតុនេះហើយបានជានៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៦២ លោកសេនាប្រមុខ សារិត ថ្លែងថា ប្រទេសរបស់លោកលំឱនកាយទទួលយកសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ ដើម្បីគោរពទៅនឹងកិច្ចសន្យារបស់ខ្លួនចំពោះធម្មនុញ្ញអង្គការសហប្រជាជាតិ។ ហើយចុងបញ្ចប់ លោក ថាណាត់ ខូម៉ាន់ (Thanat Khoman) រដ្ឋមន្ត្រីក្រសួងការបរទេសថៃ

[14] Ministry of Foreign Affairs, Aide-Memoire on Khmero-Thai Relation, op.cit.,p. 72-73
[15] Cf.Cambodia Today, No. 45, Special, special No, May-June, 1962, p.5, NA, Box 351

ចេញលិខិតមួយច្បាប់ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៦២ ក្នុងនាមរដ្ឋាភិបាលថៃទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីបញ្ជាក់ពីការទទួលស្គាល់ជាផ្លូវការរបស់ថៃនូវសាលក្រម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២[16]។ ដោយអនុលោមទៅតាមច្បាប់របស់តុលាការអន្តរជាតិ ត្រង់មាត្រា៦០ បញ្ជាក់ថាសាលក្រម សម្រេចជាស្ថាពរមិនអាចសើរើទេ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៦២ ឧត្តមសេនីយ៍ប្រាផាតចា រុសា ឌៀន (Praphat Charusathien) រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានធ្វើដំណើរ ដោយផ្ទាល់ទៅកាន់ប្រាសាទព្រះវិហារ ដើម្បីកំណត់តំបន់ប្រាសាទព្រះវិហារដោយចងខ្សែលួសបន្លា ដែលបង្ហាញឱ្យឃើញនូវភាពមិនស្របគ្នាយ៉ាងពិតប្រាកដ ទៅនឹងការសម្រេចចិត្តរបស់តុលាការដែលព្រំដែនពិតប្រាកដលេចឡើងតាមផែនទីឆ្នាំ១៩០៧។ ផែនទីថៃដាក់បង្ហាញនេះ ខ្សែបន្ទាន់ព្រំប្រទល់ដែនបានខិតជិតក្បែរនឹងតួប្រាសាទខុសគ្នាស្រឡះនឹងផែនទីបង្កើតឡើងដោយគណកម្មការចម្រុះបារាំង-សៀម ឆ្នាំ១៩០៤[17]។ នៅអំឡុងកើតវិវាទនឹងគ្នាទំនាក់ទំនងកាទូតត្រូវកាត់ផ្តាច់។ ចាប់ពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦១ ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៦២ គេសង្កេតឃើញថាការរំលោភលើអធិបតេយ្យភាពប្រទេសកម្ពុជាមាន៩២លើក ដែលចែកចេញជាច្រើនប្រភេទដូចជា ការរំលោភលើទឹកដីដោយកងទ័ពថៃ ដោយក្នុងនោះមានការសម្លាប់មកលើជនជាតិខ្មែរ ២ករណីចាប់ជម្រិត និងករណីប្លន់ និងប៉ុនប៉ងចាប់ជម្រិត ២ករណី។ ករណីរំលោភលើដែនដីប្រទេសកម្ពុជាដែលគួរអោយភ័យខ្លាចបំផុតគឺ ការជ្រៀតចូលទឹកដីខ្មែរ (តំបន់ជាំក្សាន្ត) រយៈពេល៦ ថ្ងៃ ចាប់ពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៦២ ដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៦២ នៅភ្នំអាចម៍កណ្តុរស្ថិត នៅភាគខាងកើតភ្នំព្រះវិហារ។ ទាហានខ្មែរជួបប្រយុទ្ធជាមួយទាហានថៃ នៅពេលនោះទាហានថៃដកថយទៅវិញបានបង្កើតអន្ទាក់គ្រាប់បែកធ្វើឱ្យគ្រាប់បែកផ្ទុះ នៅពេលទាហានខ្មែរ និងអ្នកស្រុកចូលទៅក្នុងតំបន់នោះវិញ។ ការរំលោភខាងដែនអាកាស ប្រទេសថៃតែងហេតុដើម្បីរលោភលើដែនអាកាសខ្មែរជាញឹកញាប់ពេលខ្លះយន្តហោះ ហោះលើដំបូលប៉ុស្ត៍រដ្ឋបាល និងបន្ទាយយោធាខ្មែរ។ ការរំលោភលើដែនអាកាសយើងសង្កេតឃើញមាន១២៦ ករណីនៅតំបន់ជាប់ព្រំដែន។ សកម្មភាពរំលោភមកលើដែនអាកាសខ្មែរកាន់តែមានភាពខ្លាំងក្លាឡើងៗ បន្ទាប់ពីប្រទេសថៃខ្លួនឯងបានទទួលស្គាល់សាលក្រមរបស់តុលាការ។ នៅខែកក្កដា ឆ្នាំ១៩៦២ ការរំលោភលើដែនអាកាសកើនឡើង ៦០ ដង ខែសីហាមានចំនួន៣៣ដង និងនៅខែកញ្ញា មានចំនួន២៥ដង[18]។

ចំពោះបញ្ហាប្រាសាទព្រះវិហារ ដែលប្រទេសយើងត្រូវតុលាការសម្រេចឱ្យឈ្នះក្តីរដ្ឋាភិបាលមិនទាន់បានឡើងទៅកាន់កាប់ភ្លាមនោះទេព្រោះ នៅខែនោះជារដូវវស្សាមិនងាយនិងចូលទៅតំបន់

[16] Ministry of Foreign Affairs, Aide-Memoire on Khmero-Thai Relation,op,cit., P74
[17] Misnistry of Foreign Affairs,Aide-Memoire on Khmero-Thai Relation,op.cit., P.75
[18] សៀវភៅ ទំនាស់ព្រំដែនរវាងប្រទេសថៃ និងប្រទេសជិតខាង ឆ្នាំ២០១០ ទំព័រ ២៦៨

នោះឡើយរហូតដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦៣ ទើបសម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ អមដំណើរដោយព្រះសង្ឃ និងឥស្សរជនខ្មែរជាច្រើនរូបទៀតឡើងទៅកាន់ប្រាសាទព្រះវិហារ ជាផ្លូវការដោយប្រារព្ធពិធីយ៉ាងឱឡារិក។ រឿងក្តីប្រាសាទព្រះវិហារត្រូវបានបញ្ចប់ផងដែរ។ ប៉ុន្តែនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ប្រទេសថៃបែរជាបានរំលោភទៅលើសាលដីការបស់តុលាការដោយបានបញ្ជូនកងកម្លាំងទាហានយ៉ាងច្រើនចូលមកក្នុងតំបន់ប្រាសាទព្រះវិហារ។ ទង្វើនេះបានបង្ហាញនូវការមិនគោរព សេចក្តីសម្រេចរបស់តុលាការអន្តរជាតិ និងមិនបានផ្តល់តម្លៃចំពោះតុលាការយុត្តិធម៌អន្តរជាតិ ដែលជាស្ថាប័នមួយរបស់អង្គការសហជាតិទាល់តែសោះ។

តាមប្រសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានថ្លែងនៅក្នុងសន្និសិទ្ធិកាសែត បន្ទាប់ពីបានដឹកនាំគណៈប្រតិភូវិលត្រលប់មកពីប្រទេសហូឡង់វិញបានលើកឡើងថា "ដោយសារតែប្រទេសថៃបានរំលោភទៅលើសាលដីការបស់តុលាការអន្តរជាតិឆ្នាំ១៩៦២ ទើបបានជាប្រទេសកម្ពុជាសម្រេចចិត្តប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីសុំឱ្យតុលាការនេះធ្វើការបកស្រាយនូវសាលដីកាឆ្នាំ១៩៦២ ឡើងវិញ[19]។ ការបកស្រាយសាលដីកានេះ គឺជាយុទ្ធសាស្ត្រមួយដែលអាចនាំទៅដល់ការបញ្ចប់នូវការឈ្លានពានរបស់ប្រទេសថៃ ចូលក្នុងដែនអធិបតេយ្យរបស់ប្រទេសកម្ពុជានៅតំបន់ប្រាសាទព្រះវិហារ ព្រោះថាប្រទេសថៃ និងយល់កាន់តែច្បាស់អំពីអត្ថន័យនៃសាលក្រមនេះ។ សន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលបានថ្លែងក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៨ ក៏បានបញ្ជាក់ថា "ការទទួលបាននូវការបកស្រាយសាលក្រមឆ្នាំ១៩៦២ របស់តុលាការយុត្តិធម៌អន្តរជាតិនេះ គឺជាការចាំបាច់ណាស់សម្រាប់ដោះស្រាយបញ្ហាព្រំដែនរបស់ប្រទេសទាំងពីរដោយសន្តិវិធី និងដោយឈរលើគោលការណ៍ច្បាប់ឱ្យបានចប់សព្វគ្រប់ និងច្បាស់លាស់ តទៅអនាគត ជាពិសេស គឺបញ្ហានៅតំបន់ផ្ទៃដី ៤.៦ គីឡូម៉ែត្រក្រឡា នៅតំបន់នៃប្រាសាទព្រះវិហារដែលភាគីថៃទាមទារដោយឈរលើផែនទីជាឯកតោភាគីរបស់ខ្លួននោះ"។

ជារួមមក ការឈ្លានពានរបស់ប្រទេសថៃចូលក្នុងតំបន់ប្រាសាទព្រះវិហារ គឺជាការរំលោភលើសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ១៩៦២។ ក្នុងនាមជាសមាជិក របស់អង្គការសហប្រជាជាតិប្រទេសថៃគួរតែឈរលើគោលការណ៍នៃការគោរពច្បាប់អន្តរជាតិ គោរពលើសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលជាស្ថាប័នមួយរបស់អង្គការសហប្រជាជាតិ។

បើយើងក្រលេកមកមើលការដាក់ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោកវិញពិតជាមានការលំបាកណាស់ក្នុងការបញ្ចូលប្រាសាទនេះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកគឺនៅថ្ងៃទី

[19] សន្និសិទ្ធិកាសែតដែលចាក់ផ្សាយតាមរយៈទូរស្សន៍បាយ័ន ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១

២១ ខែមករា ឆ្នាំ២០០៨ នៅទីក្រុងភ្នំពេញមានការប្រារព្ធអង្គប្រជុំមួយ របស់គណៈកម្មាធិការជាន់ខ្ពស់សម្រាប់ការតាមដានសំណុំឯកសារនៃការសុំចុះឈ្មោះរមណីដ្ឋានប្រាសាទព្រះវិហារជាផ្លូវការក្នុងបញ្ជីបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ។ គណៈកម្មាធិការនេះមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការបរទេស និងទំនាក់ទំនងអន្តរជាតិជាសហប្រធាន និងមានសមាជិកដែលជាសមាជិក នៃគណៈប្រតិភូតំណាងព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងសម័យប្រជុំលើកទី៣១ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅទីក្រុងគ្រៃ ឆឺត( Christchurch) ប្រទេសញូវហ្សេឡែន ពីថ្ងៃទី២៣ ខែមិថុនា ដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧។

នៅថ្ងៃទី២៤ ក្រសួងការពារជាតិសៀមបានប្រឆាំងនិងការប៉ុនប៉ង របស់ប្រទេសកម្ពុជាក្នុងការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ដោយមិនមានការឯកភាពពីប្រទេសថៃ។ នៅពេលនោះឧត្តមសេនីយ៍ឯក ប៊ុន រ៉ត សុំផាត់ រដ្ឋមន្ត្រីក្រសួងការពារជាតិថៃថ្លែងថា ការប៉ុនប៉ងរបស់ប្រទេសកម្ពុជាក្នុងការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ដោយឯកតោភាគីនោះនឹងធ្វើឱ្យថៃខូចប្រយោជន៍ រួមទាំងដីដែលមានជម្លោះក្បែរ ប្រាសាទនោះ[20]។ ហើយនៅខែមីនា ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានជូនដំណឹងដល់ប្រទេសថៃអំពីគម្រោងការក្នុងការដាក់ប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ នៅថ្ងៃទី០៣ ខែមីនា ក្នុងដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជានាយករដ្ឋមន្ត្រីថៃលោក សាម៉ាក់ ស៊ុនថរ៉ាវ៉េត បានព្រមព្រៀងជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃប្រទេសកម្ពុជាក្នុងកិច្ចសហការគាំទ្រការដាក់ប្រាសាទព្រះវិហារ ជាបេតិកភណ្ឌពិភពលោក។ នៅខែមេសា ឆ្នាំ២០០៨ នៅចុងខែមេសា ប្រទេសកម្ពុជាបានពិភាក្សាជាមួយប្រទេសថៃ ហើយប្រទេសថៃបានយល់ព្រមឱ្យដាក់ប្រាសាទព្រះវិហារនៅក្នុងបេតិកភណ្ឌពិភពលោក។

នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៨ ឯកឧត្តមសុខអាន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានជួបលោក វីរ៉ា សាក់ ឌីហ្វូត្រាគុល លេខាធិការអចិន្ត្រៃយ៍នៃក្រសួងការបរទេសថៃនៅភ្នំពេញភាគីទាំងពីរបានឯកភាពគ្នាដោយអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅក្នុងសម័យប្រជុំលើកទី៣១ ហើយនឹងព្រមព្រៀងគ្នាអនុវត្តអោយបានសម្រេចការចុះបញ្ជីជាផ្លូវការ របស់រមណីយដ្ឋានប្រាសាទព្រះវិហារដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូ ក្នុងសម័យប្រជុំលើកទី៣២ នាខែកក្កដា ឆ្នាំ ២០០៨។

[20] www.RFA.com 19.11.2008

នៅថ្ងៃទី២២ មានកិច្ចប្រជុំរវាងឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោក នុប ប៉ាឌន ផាតាម៉ា រដ្ឋមន្ត្រីក្រសួងការបរទេសថៃ នៅទីក្រុងប៉ារីសប្រទេសបារាំង ដើម្បីពិភាក្សាពីការដាក់បញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ កិច្ចប្រជុំនោះប្រទេសថៃបានគាំទ្រការបញ្ចូលប្រាសាទព្រះវិហារ នៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែលស្នើឡើងដោយប្រទេសកម្ពុជា។ ហើយនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨ ប្រទេសកម្ពុជានិងថៃបានធ្វើសេចក្តីថ្លែងការណ៍រួមមួយទាក់ទងនឹងការបញ្ចូលប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ គណៈកម្មាធិការព្រឹទ្ធសភាថៃជំទាស់នឹងការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយគណៈកម្មាធិការនេះបានដាក់សំណើទៅអង្គការយូណេស្កូ ដើម្បីពន្យល់ដល់ការដាក់ប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ក្នុងពេលជាមួយគ្នានោះដែរ រដ្ឋមន្ត្រីការបរទេសថៃ លោក ណុបផៈឌន ប៉ាតាម៉ា បដិសេដការលើកឡើងនោះ ដោយពន្យល់ថាតុលាការអន្តរជាតិទីក្រុងឡាអេ បានកាត់ក្តីប្រគល់ប្រាសាទព្រះវិហារឱ្យទៅប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៦២ មកនិងថាការសម្រេចឱ្យកម្ពុជាដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងការការពាររបស់អង្គការយូណេស្កូ នឹងមិនធ្វើអោយថៃបាត់បង់ទឹកដីនោះទេ។ មិនតែប៉ុណ្ណោះនៅថ្ងៃទី២១ ខែមិថុនា ឧត្តមសេនីយ៍ ប្រេម ទីនសូឡាណន់ ជាទីប្រឹក្សាស្តេចថៃបានបញ្ជាក់ជំហររបស់ខ្លួនគាំទ្របាតុករថៃ ដែលបានជំទាស់ការដាក់ប្រាសាទជាបេតិកភណ្ឌពិភពលោក។ ហើយនៅថ្ងៃអាទិត្យ ទី២២ ខែមិថុនា ប្រទេសកម្ពុជាបានបិទច្រកប្រាសាទព្រះវិហារ នៅពេលមានការតវ៉ាប្រឆាំងក្នុងប្រទេសថៃ នៅមាត់ច្រកព្រំដែន។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ រដ្ឋាភិបាលថៃបានដកការគាំទ្ររបស់ខ្លួន ដើម្បីចុះឈ្មោះប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងនៅថ្ងៃទី០៦ ខែកក្កដា នាយករដ្ឋមន្ត្រីថៃលោក សាម៉ាក់ ស៊ុនថរៈវេជ បានថ្លែងប្រាប់ប្រជាពលរដ្ឋរបស់ខ្លួនថា ការដាក់ប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនោះ គឺជាសិទ្ធិសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក រីឯការដាក់បញ្ចូលប្រាសាទព្រះវិហារ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនោះក៏មិនធ្វើឱ្យប្រទេសថៃបាត់បង់ទឹកដីដែរ។

ទីបំផុតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ នៅពេលដែលកិច្ចប្រជុំរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានប្រារព្ធធ្វើឡើងនៅទីក្រុងកេបិច (Quebec) ប្រទេសកាណាដា អង្គប្រជុំបានសម្រេចជាឯកច្ឆ័ន្ទដាក់បញ្ចូល ប្រាសាទព្រះវិហារ ដែលជាស្ថាបត្យកម្មរបស់ខ្មែរបានកសាងនៅសម័យអង្គរស្ថិតនៅចុងភាគខាងត្បូងនៃថ្មលយ មានកម្ពស់ ៦២៥ ម៉ែត្រ លើជួរភ្នំ ដងរែក ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែលមាន តម្លៃជាសកល ក្រោមសេចក្តីសម្រេច ៣២ COM .១០២ ទោះបីជាមានការជំទាស់យ៉ាងខ្លាំងពីភាគីថៃដើម្បីងាកចេញពីការសម្រេចដ៏ត្រឹមត្រូវនេះ យ៉ាងណាក៏ដោយ។

ការដាក់បញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌកាលពីឆ្នាំ ២០០១ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើដំណើរជាផ្លូវការដើម្បីចុះបញ្ជីប្រាសាទព្រះវិហារ។ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយពេលអស់៦ឆ្នាំមុននឹងឯកសារគាំទ្រការចុះបញ្ជីបានត្រូវបញ្ចប់ និងបញ្ជូន ទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ដើម្បីឱ្យអង្គការយូណេស្កូយល់ព្រម ដែលជាការបើកផ្លូវសម្រាប់ការចុះទីតាំងដ៏ជាទីសក្ការៈនេះ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក (WHC) ដែលមានប្រទេស ២១ ជាសមាជិក ជ្រើសរើសក្នុងចំណោមប្រទេសសមាជិក ១៨៦ នៃអនុសញ្ញាស្តីពីកិច្ចការពារ បេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោកទីក្រុងប៉ារីសឆ្នាំ ១៩៧២។

នៅពេលកម្ពុជាដាក់ប្រាសាទព្រះវិហារ សម្រាប់ការចុះបញ្ជីបេតិកភណ្ឌពិភពលោកនៅកិច្ចប្រជុំលើកទី៣១ របស់ WHC នៅគ្រែឆឺត ប្រទេសណូវែលហ្សេឡង់ នោះគណៈកម្មាធិការបានឯកភាពជាគោលការណ៍ថា ប្រាសាទព្រះវិហារគួរត្រូវចុះបញ្ជី។ ទោះជាយ៉ាងណាក្តី ការចុះបញ្ជីជាផ្លូវការត្រូវពន្យាពេលមួយឆ្នាំ ខណៈដែលត្រូវរៀបចំឯកសារបន្ថែមសម្រាប់គាំទ្រការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

ដោយបានបំពេញគ្រប់លក្ខខណ្ឌក្នុងការចុះបញ្ជីរួចរាល់ហើយនៅកិច្ចប្រជុំលើកទី៣១ របស់ WHC ខែ កក្កដា ឆ្នាំ ២០០៧ នៅគ្រែឆឺចរួចមកកិច្ចប្រជុំលើកទី៣២របស់ WHC នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨ នាទីក្រុងកេប៊ិច ប្រទេសកាណាដា បានសម្រេចជាឯកច្ឆន្ទចុះបញ្ជីប្រាសាទព្រះវិហារដ៏ល្បីល្បាញដែលជាតំណាង "ស្នាដៃឯកដ៏មហាស្ចារ្យរបស់ស្ថាបត្យកម្មខ្មែរ"។

ដោយឮព័ត៌មានពីការសម្រេចរបស់ WHC ពិធីអបអរសាទរបានកើតឡើងដោយឯកឯងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងទសវត្សរ៍ថ្មីនេះ ប្រជាជនកម្ពុជាកម្រមានឱកាស បានទទួលស្គាល់ពីអន្តរជាតិជាវិជ្ជមានបែបនេះណាស់ ហើយប្រជាជនកម្ពុជាបានអបអរសាទរអស់ពីដួងចិត្តចំពោះព្រឹត្តិការណ៍ដ៏សំខាន់បំផុតរបស់ប្រទេសជាតិ។

នៅថ្ងៃបន្ទាប់ គឺថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ ដោយបំពាននូវធម្មនុញ្ញអង្គការសហប្រជាជាតិ និងមូលដ្ឋានគតិយុត្តិអន្តរជាតិទាំងស្រុង ទាហានថៃបានឆ្លងព្រំដែនកម្ពុជាចូលមកយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា តម្រង់មកប្រាសាទព្រះវិហារដែលទើបបានចុះបញ្ជីបេតិកភណ្ឌ ពិភពលោកថ្មីៗនេះ ហើយកាន់កាប់ប្រាសាទ (ទីតាំងក្បែរប្រាសាទលើទឹកដីកម្ពុជា) រួមទាំង វត្តកែវសិក្ខាគិរីស្វារៈ និងតំបន់ជុំវិញវត្តទៀតផង។ បន្ទាប់ពីកងទ័ពសៀមបានឆ្លងដែនចូលក្នុងទឹកដីខ្មែរ និងរក្សាកម្លាំងនៅទីនោះពិសេសនៅតំបន់វត្តកែវសិក្ខាគិរីស្វារៈមកមេទ័ពសៀម និងនាយករដ្ឋមន្ត្រីសៀមបានប្រកាសថាដីតំបន់នោះគឺជាទឹកដីក្នុងជម្លោះដែលជារបស់សៀម។

នៅថ្ងៃទី១៦ ខែកក្កដា ទាហានសៀមបានបង្កើនកម្លាំងទ័ពថែមទៀតនៅក្បែរប្រាសាទព្រះវិហារ។

សង្គ្រាមមិនមែនជារឿងចម្លែកឡើយ ព្រោះប្រជាជនកម្ពុជាបានឆ្លងកាត់ជម្លោះប្រដាប់អាវុធជាច្រើនទសវត្សមកហើយ។ ប៉ុន្តែកម្ពុជាមានការភ្ញាក់ផ្អើល និងខកចិត្តនឹងអ្វីដែលថៃបានប្រតិកម្មចំពោះព្រឹត្តិការណ៍នៃសេចក្តីសម្រេចថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិច។ ការប្រើកម្លាំងយោធាដោយឥតវិចារណញ្ញាណរបស់រាជរដ្ឋាភិបាលថៃ ដើម្បីបង្ហាញអាកប្បកិរិយាជំទាស់ចំពោះបរាជ័យនៅក្នុងវេទិកាអន្តរជាតិនាទីក្រុង កេបិច ជាទង្វើពិបាកយល់ និងព្រៃផ្សៃគួរឱ្យស្អប់ខ្ពើមក្រៃលែង។ កម្ពុជាបានប្តេជ្ញាចិត្តការពារបូរណភាពទឹកដីទោះត្រូវលះបង់យ៉ាងណាក៏ដោយ ប៉ុន្តែជាតិទាំងមូលមានការអត់ធ្មត់ប្រកបដោយវិចារណញ្ញាណ។

### ១.២ ការកកើតអាជ្ញាធរជាតិព្រះវិហារ

ប្រទេសកម្ពុជា ពិតជាអាណាចក្រមួយដែលមានវ័យចំណាស់ជាងគេក្នុងចំណោមប្រទេសនានានៅតំបន់អាស៊ីអាគ្នេយ៍ ហើយក៏ធ្លាប់មានអរិយធម៌រុងរឿង ត្រចះត្រចង់ ខ្ពង់ខ្ពស់លើសគេ នាសម័យអង្គររហូតដល់ប្រទេសជាច្រើន លើពិភពលោកចាត់ទុកជាមហាអំណាចមានការកោតខ្លបខ្លាចមិនហ៊ានបៀតបៀនឡើយ។ ទាំងនេះក៏ដោយសារតែ បុព្វបុរសខ្មែរជាមនុស្សឧស្សាហ៍ព្យាយាមអត់ធ្មត់ចំពោះរាល់កិច្ចការងារ និងមានគំនិតច្នៃប្រឌិតខ្ពស់។ បើនិយាយពីស្នាដៃសិល្បៈស្ថាបត្យកម្មវិញបុព្វបុរសខ្មែរគឺ ជាវិស្វករល្អឯកគ្មានពីរដែលមាន សមត្ថភាពក្នុងការសាងសង់សំណង់ប្រាសាទបុរាណដ៏ធំស្កឹមស្កៃរាប់ពាន់ប្រាសាទ អាចឈរបង្អួតរាងយ៉ាងសង្ហារបានរាប់ពាន់ឆ្នាំ ដែលផ្គុំចេញពីដុំថ្មធំៗ មិនគួរឱ្យជឿថាមនុស្សជាអ្នកកសាងឡើយ រហូតដល់មានជនខ្លះយល់ថាអាទិទេពជាអ្នកនិម្មិតឡើងទៀតផង។ ក្នុងចំនោមប្រាសាទបុរាណទាំងនោះ ប្រាសាទមួយដែលមានកេរ្តិ៍ឈ្មោះល្បីសុះសាយដែរនោះគឺ ប្រាសាទព្រះវិហារ ដែលមានទីតាំងស្ថិតនៅលើជួរភ្នំដងរែកជាតំបន់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ។

ដោយសារតែសម្មិទ្ធិផលដ៏អស្ចារ្យនេះហើយទើបមានភ្ញៀវទេសចរជាតិ និងអន្តរជាតិបានចូលមកទស្សនាកំសាន្តប្រាសាទបុរាណនេះឥតដាច់ ហើយចំណូលដែលបានហូរចូលក្នុងថវិកាជាតិនោះក៏មានចំនួនច្រើនផងដែរ ដែលនេះជាកត្តាមួយនាំឱ្យសេដ្ឋកិច្ចជាតិមានការរីកចំរើនយ៉ាងខ្លាំងក្លា។ ម្យ៉ាងទៀត ភាពល្បីល្បាញរបស់ប្រាសាទព្រះវិហារ ក៏បានធ្វើឱ្យបរទេសកាន់តែស្គាល់កម្ពុជាកាន់តែច្បាស់ឡើងៗ។ ប៉ុន្តែដោយសារតែសម្លឹងមើលឃើញពីផលប្រយោជន៍ដ៏ធំធេងដែលបុព្វបុរសខ្មែរបន្សល់ទុកនេះ ទើបប្រទេសជិតខាងមានបំណងទន្ទ្រាន ឈ្លានពាន ចង់បានប្រាសាទនេះមកធ្វើជាកម្មសិទ្ធិរបស់គេដោយឥតកេរ្តិ៍ខ្មាស ទាំងបណ្តាមហាជនលើពិភពលោកបានទទួល

ស្គាល់ និងដឹងលឺគ្រប់ៗគ្នារួចហើយ ថាជាកម្មសិទ្ធិរបស់ខ្មែរនោះ។ ដើម្បីការពារសម្បត្តិវប្បធម៌ជាតិរបស់ខ្លួនឱ្យរួចផុតពីភាពមានះចង់បានយ៉ាងចចេសពីសំណាក់ចោរឈ្លានពានថៃ និងដើម្បីបង្ហាញពីភាពអស្ចារ្យ នៃសម្បត្តិមតិកវប្បធម៌ជាតិផងនោះ ប្រទេសកម្ពុជាបានបញ្ចូលប្រាសាទព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិច ប្រទេសកាណាដា។

ក្រោយពីមានការទទួលស្គាល់ ស្របតាមផ្លូវច្បាប់ហើយប្រទេសកម្ពុជា ក៏បានបង្កើតនូវគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយឡើងមានឈ្មោះថា ស្ថាប័នអាជ្ញាធរជាតិព្រះវិហារ ដែលមានតួនាទីជាអ្នកថែរក្សា ការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងនោះមានក្រុមប្រឹក្សាភិបាល និងអគ្គនាយកដ្ឋាននានាដែលមានភារកិច្ចទៅតាមការគ្រប់គ្រង និងចាត់តាំងតាមផ្នែកនិមួយៗ ដើម្បីការពារ និងថែរក្សាបរិស្ថានសម្បត្តិវប្បធម៌ វត្ថុបុរាណដ៏មានតម្លៃ និងរៀបចំចាត់ចែងអំពីបរិវេណដែលត្រូវហាមឃាត់ និងអនុញ្ញាតចំពោះការសាងសង់រាល់សំណង់នានាសម្រាប់ភ្ញៀវទេសចរ។ ពិសេសនោះគឺ ការអភិរក្ស និងជួសជុលឡើងវិញនូវកន្លែងដែលទទួលរងខូចខាតពីគ្រោះធម្មជាតិ និងបណ្តាលមកពីមូលហេតុផ្សេងៗទៀត។ ដូចនេះដើម្បីអោយដឹងថាអាជ្ញាធរនេះបង្កើតឡើងក្នុងគោលបំណងអ្វីឱ្យកាន់តែច្បាស់ ព្រមទាំងដំណើរការនៃការប្រព្រឹត្តទៅនៃអាជ្ញាធរនេះមានអ្វីខ្លះ ហើយថាតើអាជ្ញាធរនេះមានសិទ្ធិនិងសមត្ថកិច្ចដែនដីរបៀបណាខ្លះ យើងនិងសិក្សាទៅលើចំនុច (១.២.១) គោលបំណងនៃការបង្កើតអាជ្ញាធរព្រះវិហារ និងចំនុច (១.២.២) ដំណើរការប្រព្រឹត្តទៅ ព្រមទាំងសិទ្ធិនិងសមត្ថកិច្ចដែនដីរបស់អាជ្ញាធរព្រះវិហារដូចជា៖

### ១.២.១ គោលបំណងនៃការបង្កើតអាជ្ញាធរជាតិព្រះវិហារ

អាជ្ញាធរជាតិព្រះវិហារត្រូវបានបង្កើតឡើងដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ដែលជាគ្រឹះស្ថានសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្តស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ[21]។

### ១.២.២ ដំណើរការប្រព្រឹត្តទៅព្រមទាំងសិទ្ធិនិងសមត្ថកិច្ចដែនដីរបស់អាជ្ញាធរជាតិព្រះវិហារ

#### ក.ដំណើរការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ

អាជ្ញាធរជាតិព្រះវិហារ ជាគ្រឹះស្ថានសាធារណៈមួយដែលស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី[22]។ អាជ្ញាធរព្រះវិហារមានបេសកម្មគិតគូរ ដឹកនាំការងាររៀបចំ និងអភិវឌ្ឍន៍

[21] មាត្រា១ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៥៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

ទេសចរណ៍ នៃតំបន់ចំនួន៤ ដែលមានចែងនៅក្នុងមាត្រា ៤ នៃអនុក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ[23]។ អាជ្ញាធរជាតិព្រះវិហារដើម្បីការពារ និងអភិវឌ្ឍរមណីដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ព្រមជាមួយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថាន និងនាយកដ្ឋានទាំងឡាយដែលមានភារកិច្ចទទួលខុសត្រូវជាក់ស្តែងនៅក្នុងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ[24]។

អាជ្ញាធរនេះត្រូវកំណត់ឱ្យមាន សៀវភៅបន្ទុកសម្រាប់អង្គការនានាដែល ពាក់ព័ន្ធដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់ប្រាសាទព្រះវិហារ។ អាជ្ញាធរនេះអាចចុះកិច្ចសន្យាអំពីកម្មវិធីប្រចាំឆ្នាំជាមួយ អង្គការជាតិ និងអន្តរជាតិ ចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្តដែលមានបំណងចង់ធ្វើការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និងការផ្តល់សេវាកម្មជាយថាហេតុសហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសហគមន៍ និងអន្តរជាតិដែលដើរតាមទិសដៅឆ្លើយតបទៅនឹងសមត្ថកិច្ចអាជ្ញាធរជាតិ[25]។

អាជ្ញាធរព្រះវិហារដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋាន និងវប្បធម៌ជាតិ នៃប្រាសាទព្រះវិហារត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារវិនិយោគនិងសេចក្តីអនុញ្ញាតផ្សេងដែលត្រូវបានសម្រេចហើយជូនប្រមុខរដ្ឋាភិបាល[26]។

### ខ. សិទ្ធនិងសមត្ថកិច្ចដែនដីរបស់អាជ្ញាធរជាតិព្រះវិហារ

អាជ្ញាធរព្រះវិហារ គឺជាគ្រឹះស្ថានសារធារណៈតែមួយគត់ប្រកបដោយបុគ្គលភាពគតិយុត្តទទួលការងាររៀបចំ និងអភិវឌ្ឍទេសចរណ៍នៃតំបន់ទាំងបួន នៅរមណីយដ្ឋានប្រាសាទព្រះវិហារឱ្យមានប្រសិទ្ធភាពស្របតាមទិសដៅរបស់រាជរដ្ឋាភិបាល។ អាជ្ញាធរជាតិព្រះវិហារមានសិទ្ធិចាត់ចែងការងាររដ្ឋបាលទូទៅ រួមទាំងការអភិវឌ្ឍទេសចរណ៍ ការកំណត់ទីតាំងអភិវឌ្ឍន៍ ការអភិរក្សតំបន់ប្រាសាទការស្រាវជ្រាវផ្នែកបុរាណវិទ្យា នរវិទ្យា ឬប្រវិត្តិវិទ្យាចំនែករមណីយដ្ឋានមានប្រាសាទ

[22] មាត្រា១ វាក្យខ័ណ្ឌទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

[23] មាត្រា២ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមាត្រា៤ នៃអនុក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

[24] មាត្រា២ វាក្យខ័ណ្ឌទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

[25] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

[26] មាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

និងពត៌មានទូទៅ ដែលពាក់ព័ន្ធដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ និងអនុក្រឹត្យលេខ១១៨ អនក្រ.បក.ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៦។ ចំពោះការរៀបចំចាត់ចែង និងគ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានជាតិនៃ ប្រាសាទព្រះវិហារ ដោយមានកិច្ចសហការជិតស្និទ្ធ និងជា ប្រចាំជាមួយអាជ្ញាធរដែនដី។ មិនតែប៉ុណ្ណោះអាជ្ញាធរនេះត្រូវ ធ្វើសកម្មភាពឱ្យស្របតាមបទបញ្ញត្តិដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារព្រមទាំងកាតព្វកិច្ចអន្តរជាតិ[27]។

អាជ្ញាធរជាតិនេះមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ។ ការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេង ក្រៅពីអាជ្ញាធរជាតិនេះ ទាក់ទងទៅនិងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវចាត់ទុកជាមោឃៈ។ ចំពោះសំណង់កសាងរួចហើយក្នុងតំបន់ការងារ ដែលគ្មានច្បាប់អនុញ្ញាត ត្រូវរុះរើចេញដោយម្ចាស់សំណង់ ដោយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃជូនដំណឹង[28]។

អាជ្ញាធរជាតិព្រះវិហារ ត្រូវទទួលភារកិច្ចផ្តាច់មុខ ជាអ្នកចាត់ចែងគ្រប់ការងារទាំងអស់ក្នុងបរិវេណរមណីយដ្ឋាននេះ លើកលែងកិច្ចការណាដែលទាក់ទងនិងបញ្ហាព្រំដែន។ អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារនៅមានសិទ្ធិមួយចំនួនទៀត ក្នុងការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់ប្រាសាទព្រះវិហារដូចជា ចុះកិច្ចសន្យាអំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការជាតិ និងអន្តរជាតិនានា និងចុះកិច្ចសន្យាជាមួយអាជ្ញាធរខេត្ត ដែលមានបំណងធ្វើការរៀបចំនគររូបនីយកម្ម និងអភិវឌ្ឍន៍ជន រួមទាំងផ្តល់សេវាកម្មផ្សេងៗទៀត ហើយថែមទាំងសហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗគ្រប់មូលនិធិ សហគមន៍ជាតិ និងអន្តរជាតិ ដែលដើរតាមទិសដៅឆ្លើយតបនិងសមត្ថកិច្ចអាជ្ញាធរជាតិ។[29]

[27] មាត្រា១២ វាក្យខ័ណ្ឌទី១នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

[28] មាត្រា១២ វាក្យខ័ណ្ឌទី២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

[29] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

# ជំពូកទី២

# តួនាទី និងបេសកកម្មរបស់អាជ្ញាធរជាតិព្រះវិហារ

នៅក្នុងអាជ្ញាធរជាតិព្រះវិហារ ពិតជាមានតួនាទី និងបេសកកម្មច្រើនណាស់ដែលអាជ្ញាធរនេះត្រូវបំពេញ។ ដោយយោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍនៃរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារលេខ ១១.អនក្រ.បក តួនាទីនិងភារកិច្ច បានចែងយ៉ាងច្បាស់អំពី បេសកកម្មនៃអាជ្ញាធរព្រះវិហារគឺការពារអភិរក្ស និងលើកតម្លៃឧទ្យានបុរាណ បរិស្ថាន វប្បធម៌ និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងគិតគូរ និងអោយបានសម្រេចនូវផែនការសកម្មភាពនិងការរៀបចំអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព ថែមទាំងស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗដើម្បីអោយបានសម្រេចការងារក្នុងផែនការដែលបានកំណត់ នៅក្នុងផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ ហើយនិងរួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលឱ្យបាននៅក្នុងតំបន់ប្រាសាទព្រះវិហារ មិនតែប៉ុណ្ណោះអាជ្ញាធរជាតិព្រះវិហារត្រូវសហការជាមួយក្រុមអភិវឌ្ឍន៍កម្ពុជាដើម្បីផ្តល់ការអនុញ្ញាតក្នុងការវិនិយោគនូវគំរោងទាំងឡាយដែលពាកព័ន្ធបេសកកម្មរបស់នាយកដ្ឋានអាជ្ញាធរព្រះវិហារ លើសពីនេះទៅទៀត ត្រូវសហការជាមួយក្រសួងសមាគមជាតិព្រមទាំងអង្គការមូលនិធិស្ថាប័នរដ្ឋាភិបាល ដែលមានគោលបំណងស្របនិងទិសដៅរបស់អគ្គនាយក នៃអាជ្ញាធរជាតិព្រះវិហារមុខងារ គិតគូរ និងចាត់ចែងអនុវត្តនៅផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងលើការថែរក្សា និងការពារប្រាសាទព្រះវិហារ ព្រមទាំងតំបន់ពាក់ព័ន្ធផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់អោយ ធ្វើអន្តរាគមន៍ជាចាំបាច់និងបន្ទាន់ដើម្បីធានាកិច្ចការពារ និងស្រោចស្រង់រមណីយដ្ឋានប្រាសាទព្រះវិហារ ។ល។

ដូចនេះដើម្បីឱ្យដំណើរការនៃការបំពេញតួនាទី និងបេសកកម្មប្រកបទៅដោយប្រសិទ្ធិភាព អាជ្ញាធរនេះត្រូវមាននាយកដ្ឋាន និងអគ្គនាយកដ្ឋានជាច្រើនក្នុងការជួយជ្រោមជ្រែង និងសម្រួលដល់ការងាររបស់ខ្លួន ហើយនាយកដ្ឋាន និងអគ្គនាយកដ្ឋាននីមួយៗមានតួនាទី និងបេសកកម្មរៀងៗខ្លួន។ ដូចនេះតើនាយកដ្ឋាន និងអគ្គនាយកដ្ឋាននៃអាជ្ញាធរនេះមានអ្វីខ្លះ ហើយមានតួនាទីនិងបេសកកម្មអ្វីខ្លះនៅក្នុងអាជ្ញាធរជាតិព្រះវិហារ? មិនតែប៉ុណ្ណោះយើង និងកាន់តែចង់ដឹងពីធនធានរបស់អាជ្ញានេះមកពីណា ព្រមទាំងសម្រេចបានសមិទ្ធិផលអ្វីខ្លះ? យើងនិងសិក្សានៅចំនុច ២.១ តួនាទីនិងបេសកម្មទូទៅរបស់អាជ្ញាធរព្រះវិហារ និងចំនុច ២.២ ធនធាន និងសមិទ្ធផលរបស់អាជ្ញាធរព្រះវិហារដូចតទៅៈ

## ២.១ តួនាទីនិងបេសកកម្មទូទៅរបស់ស្ថាប័នអាជ្ញាធរជាតិព្រះវិហារ

ដើម្បីជាទុននៅក្នុងការស្រាយបំភ្លឺនូវតួនាទី និងបេសសកកម្មទូទៅរបស់ស្ថាប័នអាជ្ញាធរជាតិព្រះវិហារ យើងបានលើកឡើងនូវពីរចំនុចសំខាន់ពីរទៀតគឺ ( ២.១.១ ) តួនាទី និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាលនិងប្រធានអាជ្ញាធរព្រះវិហារ និង ( ២.១.២ ) តួនាទី និងបេសកកម្មរបស់នាយកដ្ឋាននានា។

### ២.១.១តួនាទីនិងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាលនិងប្រធានអាជ្ញាធរជាតិព្រះវិហារ

#### ក.តួនាទី និងបេសកកម្មរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដឹកនាំអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមានសិទ្ធិអនុម័តរាល់ការតម្រង់ទិសដៅសកម្មភាពរបស់អាជ្ញាធរជាតិព្រះវិហារ ហើយមានតួនាទី និងភារកិច្ចរៀបចំដឹកនាំអាជ្ញាធរជាតិព្រះវិហារ ក្នុងការអនុញ្ញាតឱ្យប្រធានអាជ្ញាធរជាតិ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចន្យាអន្តរជាតិទាំងឡាយ ស្របតាមនីតិវិធីជាធរមាន ហើយក៏មានតួនាទី និងភារកិច្ចក្នុងការអនុម័តលើកិច្ចយល់ព្រមចំពោះការតាក់តែង និងតម្លើងឋានន្តរស័ក្ក ភ្នាក់ងារ និងបុគ្គលិកអាជ្ញាធរជាតិព្រះវិហារផងដែរព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរ ជាតិ និងរួមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលប្រធានអាជ្ញាធរជាតិបានដាក់ជូន ព្រមទាំងកំណត់ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបយ៉ាងដែលអាជ្ញាធរជាតិប្រមូលបានក៏ស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលដែរ។ លើសពីនេះទៅទៀតចំនួនទឹកប្រាក់ និងល័ក្ខខ័ណ្ឌនៃការខ្ចីបុលក៏ជាតួនាទីរបស់ក្រុមប្រឹក្សានេះដែរ និង រាល់វិធានការដោះស្រាយបញ្ហាដែលប្រធានអាជ្ញាធរជាតិដាក់ជូនត្រួតពិនិត្យ[30]។

#### ខ.តួនាទី និងភារកិច្ចរបស់ប្រធានអាជ្ញាធរជាតិព្រះវិហារ

ប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារនិងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ គឺជាប្រធានអាជ្ញាធរជាតិដែលមានសិទ្ធិអំណាច តួនាទី និងភារកិច្ចដូចជារៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងទទួលបន្ទុកប្រតិបត្តិតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដាក់ឱ្យដំណើរការនូវនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។ ចំពោះការរៀបចំថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច ក៏ជាតួនាទី និងភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាភិបាលដែរ។ មួយវិញទៀត ការធ្វើរបាយការណ៍ការគ្រប់គ្រងប្រចាំឆ្នាំ

[30] មាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៨៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

និងត្រួតពិនិត្យលើបញ្ជីគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងធ្វើការបញ្ជាក់ក្នុងករណីចាំបាច់នូវភារកិច្ចរបស់អង្គភាពចម្រុះនានានៃគ្រឹះស្ថាន ដែលបំពេញមុខដំណែងរបស់គ្រឹះស្ថាន ក្នុងកម្រិតក្របខ័ណ្ឌចំនួនបុគ្គលដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងដោយគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិកក៏ជាតួនាទីរបស់គាត់ដែរ។ ប្រធានក្រុមប្រឹក្សាបំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលរបស់គ្រឹះស្ថាន។ ប្រធានក្រុមប្រឹក្សាភិបាល ក៏ធ្វើសម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតដែលស្តីពីបញ្ហានេះជារួមគឺបំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទៅលើការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យខ្លួនតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ តួនាទីសំខាន់មួយទៀតគឺ ជាតំណាងឱ្យរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធីការ និងការចរចារដែល ពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានព្រះវិហារ និងទទួលរាប់រងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការក្នុងដំណើរការរបស់អាជ្ញាធរជាតិ មិនតែប៉ុណ្ណោះប្រធានក្រុមប្រឹក្សាភិបាល ជាអាណាប័កដើមខ្សែនៃអាជ្ញាធរជាតិ ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ តែងតាំង និងតម្លើងតំណែងឋានន្តរស័ក្តិថ្នាក់ងារ និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និងដឹកនាំ គ្រប់គ្រងជាប្រចាំលើសកម្មភាពការងាររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ[31]។

ប្រធានអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានអគ្គនាយកដ្ឋានមួយជាសេនាធិការ ដែលត្រូវបានដឹកនាំគ្រប់គ្រងដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។ អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ត្រូវតែតាំងដោយព្រះរាជក្រឹត្យ។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍ រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារត្រូវកំណត់ដោយអនុក្រឹត្យ[32]។ អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារស្ថិតក្រោមការគ្រប់គ្រង របស់ប្រធានអាជ្ញាធរជាតិព្រះវិហារ និងក្រុមប្រឹក្សាភិបាលមួយដែលមានអគ្គនាយក

[31] មាត្រា១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៩៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមាត្រា១២ នៃព្រះរាជក្រឹត្យ នស/រកត/១២៩៧ ៩១ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

[32] មាត្រា១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៩៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

មួយរូប ទទួលខុសត្រូវរួមក្នុងការដឹកនាំការងាររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ។ អគ្គនាយកនៃអគ្គនាយកដ្ឋាអាជ្ញាធរជាតិព្រះវិហារ មានអគ្គនាយករងមួយចំនួនជាជំនួយការ។ ការកំណត់ និងការបែងចែកភារកិច្ចរបស់អគ្គនាយក និងអគ្គនាយករងរបស់អគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរនេះ ។ អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារមានសិទ្ធិប្រើប្រាស់ត្រាដោយឡែក និងមានកញ្ចប់ថវិកាបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ មានបេសកកម្មដូចជា ការពារ ថែរក្សា អភិរក្ស និងលើតម្លៃឧទ្យានបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងគិតគូរ និងអនុវត្តន៍ឱ្យបានសម្រេចនូវផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ទាំងបួន ដែលបានកំណត់ដោយបទបញ្ញត្តិនៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការកំណត់រមណីយដ្ឋានតំបន់ព្រះវិហារ និងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីដ្ឋានប្រាសាទព្រះវិហារ និងយោងទៅតាមអនុក្រឹត្យថ្មីលេខ ៥២ អន.ក្របក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងទប់ស្កាត់បទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងមានតួនាទីនិងភារកិច្ចស្វែងរកប្រភពហិរញ្ញប្បទានទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមតំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវការងារដែលបានកំណត់ក្នុងផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ដូចបានរៀបរាប់ខាងលើ។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានអាជ្ញាធរជាតិប្រាសាទព្រះវិហារបានរួមចំណែក ក្នុងការអនុម័តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល នៅក្នុងតំបន់ប្រាសាទព្រះវិហារផងដែរ។

មួយវិញទៀត អគ្គនាយកដ្ឋាននេះបានសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយ ដែលទាក់ទងនឹងបេសកកម្មរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ និងសហការជាមួយក្រសួង ស្ថាប័ន មូលនិធិ អង្គការ សមាគមជាតិ និងអន្តរជាតិព្រមទាំងស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានគោលបំណងស្របនឹងទិសដៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ។

អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារមានមុខងារ និងភារកិច្ចដូចជាគិតគូរ និងចាត់ចែងអនុវត្តនូវរាល់ផែនការសម្រាប់រយៈពេលធម្យម និងរយៈពេលវែងលើការថែរក្សា ព្រមទាំងការពារប្រាសាទនានាក្នុង តំបន់ប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ព្រមទាំងធ្វើអន្តរាគមន៍ចាំបាច់ និងបន្ទាប់បន្សំដើម្បីជានាកិច្ចការពារ និងស្រោចស្រង់

រមណីយដ្ឋានប្រាសាទព្រះវិហារ និងបង្កើតឱ្យមានអង្គភាពឆ្មាំប្រាសាទ ដើម្បីបង្ការ ថែរក្សា ការពារ ឬគ្រប់គ្រងប្រាសាទនានារួមទាំងទេសភាព និងបរិស្ថានដែលនៅជុំវិញប្រាសាទទាំងនោះ ហើយធ្វើការស្ទង់មើល និងធ្វើកំណាយបុរាណវិទ្យា។ ម្យ៉ាងទៀតក៏បានរួមចំណែកបង្កើនចំណេះដឹង និងការស្រាវជ្រាវ ដើម្បីចងក្រងឯកសារពីវប្បធម៌ខ្មែរនៅតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងគិតគូរ និងចាត់ចែងអនុវត្តនូវរាល់ផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងក្នុង គោលបំណងលើកតម្លៃជម្រុញផ្សព្វផ្សាយ និងគ្រប់គ្រងការធ្វើសកម្មភាពពាណិជ្ជកម្ម លើតំបន់ឧទ្យានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ហើយក៏ធ្វើការសហការជាមួយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ និងផ្តល់ព័ត៌មានដល់ភ្នាក់ងារ និងអ្នកប្រកបរបរទេសចរណ៍ ហើយក៏មានភារកិច្ចធានាការគ្រប់គ្រង និងការប្រើប្រាស់កម្រៃបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ បទប្បញ្ញត្តិជាធរមាន និងវិធានអន្តរជាតិនានា និងរៀបចំណតរថយន្តមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ តូបស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍ លក់ ភេសជ្ជៈ ស្ថានីយ៍ប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌ និងឆ្មាំប្រាសាទ បង្គន់ បន្ទប់ទឹក និង រថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ។ មិនតែប៉ុណ្ណោះក៏បានសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធដើម្បីរៀបចំតំបន់រណប (តំបន់បី) ឱ្យបានល្អប្រសើរ និងមានភាពសមរម្យដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងបទបញ្ញត្តិជាធរមាន ព្រមទាំងយកចិត្តទុកដាក់លើផលប៉ះពាល់ទៅលើបរិស្ថាន ដែលបណ្តាលមកពីកំណើនពលរដ្ឋ និងវិធានអន្តរជាតិស្តីពីការអភិវឌ្ឍទេសចរណ៍ប្រកប ដោយនិរន្តរភាព ព្រមទាំងចេញលិខិតអនុញ្ញាតរុះរើ និងសាងសងសំណងនានា ព្រមទាំងលិខិតបញ្ជាឱ្យរុះរើចំពោះសំណង់គ្មានច្បាប់អនុញ្ញាត ដែលប៉ះពាល់ធ្ងន់ធ្ងរក្នុងតំបន់ការពារដែលបានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ និងដោយយោងអនុក្រឹត្យថ្មីលេខនស/រកត/០៨១១/៨៥២ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហាចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ហើយសិក្សាពីផលប៉ះពាល់ និងវាយតម្លៃលើគម្រោង វិនិយោគវិស័យទេសចរណ៍ ធ្វើការតាមដានឃ្លាំមើលតាមរយៈការរៀបចំព្យាករណ៍ជាប្រចាំ សម្រាប់រយៈពេលកំណត់នីមួយនិងកំណត់ជ្រើសរើស និងចាត់ចែងអនុវត្តន៍គម្រោងវិនិយោគវិស័យទេសចរណ៍ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ព្រមទាំងបទបញ្ញត្តិ និងវិធាននានាជាធរមាន ធ្វើការរៀបចំកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិកព្រមទាំងធ្វើការដោះស្រាយរាល់កិច្ចការវិវាទទាំងឡាយ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ បទបញ្ញត្តិ និងវិធាននានាជាធរមាន និងវិធានអន្តរជាតិ លើស

ពីនេះថែមទាំងបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ខេត្តព្រះវិហារដោយបង្កើនការងារ ជម្រុញឱ្យមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងពង្រឹងសមត្ថភាពបម្រើការងាររបស់ប្រជាជននៅតាមតំបន់នេះ និងតំបន់ផ្សេងទៀតដែលពាក់ព័ន្ធ ព្រមទាំងជួយពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យាដែលផ្តល់ការរីកចម្រើនដល់រមណីដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងបរិស្ថានអនុលោមតាម គោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល និងរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យគុណភាពលើការធ្វើអាជីវកម្ម និងសេវាកម្មនានាក្នុងគោលដៅការពារបរិស្ថាន និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងតំបន់ខេត្តព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត ព្រមទាំងទទួលការងារពិធីការ និងការរៀបចំមគ្គុទេសក៍សម្រាប់ទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិដែលចូលមក ទស្សនាតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ហើយមានភារកិច្ចបង្ក្រាបបទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់ប្រាសាទព្រះវិហារ និងកសាងសំណុំរឿងបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ថែមទាំងធ្វើរបាយការណ៍តាមរយៈប្រធានអាជ្ញាធរជាតិព្រះវិហារ ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាសឆមាស ៩ខែ និងប្រចាំឆ្នាំ ព្រមទាំងវិធានការនានាដែលអាជ្ញាធរជាតិប្រកាន់យក ផ្ញើជូនរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងធ្វើរបាយការណ៍តាមរយៈប្រធានអាជ្ញាធរជាតិព្រះវិហារ ស្តីពីស្ថានភាពចំណូលនិងចំណាយរបស់អាជ្ញាធរជាតិជូនរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ[33]។

### ២.១.២ តួនាទី និងបេសកកម្មរបស់នាយកដ្ឋាននានា

នៅក្នុងតួនាទី និងបេសកកម្មរបស់នាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ គឺនាយកដ្ឋានទាំងអស់មានតួនាទី ក៏ដូចជាបេសកកម្មផ្សេងៗគ្នា ក្នុងការសម្រួលដល់ដំណើរការកិច្ចការទាំងមូលនៅក្នុងអាជ្ញាធរជាតិព្រះវិហារ ដូចនេះដើម្បីដឹងថានាយកដ្ឋាននានានោះមានអ្វីខ្លះ យើងនិងសិក្សាទាំងអស់គ្នានៅចំនុចនិមួយៗជាបន្តបន្ទាប់។

#### ក.នាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុទំនាក់ទំនងសាធារណៈ ផែនការ និងនីតិកម្ម

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចក្នុងការធ្វើទំនាក់ទំនង និងសហការជាមួយសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិព្រះវិហារ ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន ព្រមទាំងទទួលលិខិតចូលពិនិត្យបែងចែកលិខិតតាមខ្លឹមសារជូនអគ្គនាយក អគ្គនាយករង នាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋាន

[33] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១២៧ ដល់ទំព័រទី១៣១

នៃអាជ្ញាធរជាតិព្រះវិហារ និងផ្ញើចេញនូវលិខិត របស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ ជូនក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធក្រោយពី មានការសម្រេចពីប្រធាន អាជ្ញាធរជាតិព្រះវិហារនេះ ធ្វើការគ្រប់គ្រង និងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រមលើបុគ្គលិកទាំងអស់របស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិព្រះវិហារ រៀបចំស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកព្រមទាំងធ្វើតារាងការងារដែលអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារកន្លងមក និងត្រូវអនុវត្តបន្តនា ពេលអនាគត អនុវត្តតម្លៃតាមតារាងកំណត់ប្រាក់បៀវត្សរ៍ ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ការងារនីមួយៗរបស់មន្ត្រីរាជការ និងបុគ្គលិកនៅអគ្គនាយដ្ឋាន នៃអាជ្ញាធរជាតិព្រះវិហារ រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានានូវកម្មវិធី ស្តីពីការកំណត់តំណែងឯកទេស និងការបែងចែងធនធានមនុស្សរៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធស្តីពីតម្រូវការសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការ និងបុគ្គលិករៀបចំគម្រោងជាមួយ នាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនូវសំណើសុំថវិកា ឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់ ព្រមទាំងពិនិត្យ និងតាក់តែងកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិក និងធ្វើការតាមដាន និងឃ្លាំមើលការអនុវត្តកិច្ចសន្យាដែលទាក់ទងនឹងកិច្ចការវិនិយោគ និងសម្បទាន ព្រមទាំងគ្រប់គ្រងផ្ទាល់ការធ្វើអាជីវកម្មនានា ឬតាមដានឃ្លាំមើលជា អចិន្ត្រៃយ៍លើការងារអាជីវកម្ម របស់ក្រុមហ៊ុនសម្បទាននានាដើម្បីធានាការគ្រប់គ្រង ឱ្យមានប្រសិទ្ធិភាព។ ហើយក៏ប្រមូលប្រាក់ចំណូល និងចាត់ចែងចំណាយផ្សេងៗ ព្រមទាំងរក្សាទុក និងចាត់ចែងការប្រើប្រាស់មូលនិធិ និងរូបិយវត្ថុ និងកាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកនូវលិខិតយុត្តិការ ព្រមមទាំងរៀបចំគណនីហិរញ្ញវត្ថុប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់អគ្គនាយដ្ឋាន នៃអាជ្ញាធរជាតិព្រះវិហារ និងរៀបចំផែនការមេ ក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានព្រះវិហារ ដើម្បីធ្វើការផ្សព្វផ្សាយ ទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគនៅក្នុងតំបន់អភិវឌ្ឍ (តំបន់៣) និងក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ រៀបចំផែនការកសាងច្បាប់ និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងតំបន់រមណីយដ្ឋានព្រះវិហារ។ មួយវិញទៀតក៏បានសហការសម្របសម្រួលក្នុងការរៀបចំព័ត៌មាន ស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការណ៍ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនប្រធានអាជ្ញាធរ[34]។

[34] សៀវភៅ នីតិនតរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៣២ ដល់ទំព័រទី១៣៤

## ខ. នាយកដ្ឋានរមណីយដ្ឋាននិងបុរាណវិទ្យា

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចធ្វើផែនការ និងដាក់ឱ្យអនុវត្តនូវការងាររៀបចំផ្សេងៗ នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារដែលទាក់ទងនឹងប្រាសាទ និងទេសភាពនានាដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងធ្វើផែនការមេ សម្រាប់ការពារ និងថែរក្សា បរិស្ថានប្រវិត្តិសាស្ត្រក្នុងតំបន់ឧទ្យានប្រាសាទព្រះវិហារ ដោយរួមបញ្ចូលទាំងឯកសារស្ថានភាពប្រាសាទនានា និងផែនទីបង្ហាញកន្លែងគ្រោះថ្នាក់ ការថែរក្សា ការពារជាប្រចាំយ៉ាងទៀងទាត់ និងយូរអង្វែងចំពោះរមណីយដ្ឋានដែលបានទទួលចំណាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោកដោយមានការសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ ប្រាសាទព្រះវិហារ ដោយផ្អែកទៅលើសមត្ថកិច្ចនាយកដ្ឋានជំនាញនីមួយៗដោយយកចិត្តទុកដាក់លើការថែទាំការដាក់ផ្លាកសញ្ញាធ្វើចរាចរណ៍ការដាក់ផ្លាកសញ្ញាផ្សេងៗដែលចាំបាច់ ការរៀបចំ ចំណតរថយន្ត មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ ការកំណត់តូប ស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍ និងភេសជ្ជៈ ស្នាក់ការប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌ បង្គន់ និងបន្ទប់ទឹកជាដើម ដើម្បីធានាឱ្យមានសោភ័ណភាពល្អប្រសើរដល់តំបន់ខេត្តព្រះវិហារនិងបរិវេណនានានៃតំបន់នោះ។ នាយកដ្ឋាននេះ ធ្វើការស្រាវជ្រាវ រៀបចំសេចក្តីព្រាងឯកសារ ស្តីពីដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍន៍តំបន់ខេត្តព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យគម្រោងអាចអនុវត្តបាន និងរៀបចំផែនការ ការស្ទង់ពិនិត្យមើល និងកំណាយបុរាណវិទ្យា ព្រមទាំងចាត់វិធានការសម្រាប់បង្ការ ឬសង្គ្រោះតាមការចាំបាច់ ព្រមទាំងបង្កើតក្រុមចល័តដែលមានសមត្ថភាព និងមានឧបករណ៍សម្ភារៈសមស្របដើម្បីរៀបចំថែទាំ និងតាមដានផ្នែកបុរាណវិទ្យា និងការគ្រប់គ្រងរមណីយដ្ឋាន និងទទួលបណ្តុះបណ្តាលបុរាណវិទូ ស្ថាបត្យករ និងក្រុមអភិរក្សដែលទទួលបន្ទុកការងារនៅតំបន់ឧទ្យានប្រាសាទព្រះវិហារ គ្រប់គ្រង និងដឹកនាំឆ្មាំប្រាសាទ កម្លាំងកម្មករសំអាតឧទ្យាន និងកម្មករជំនាញនានាក្នុងតំបន់រមណីយដ្ឋាន ប្រាសាទព្រះវិហារ ហើយក៏កំណត់ និងប្រគល់ទីតាំងរៀបចំពិធីផ្សេងៗ ក្នុងតំបន់ប្រាសាទព្រះវិហារ និងតាមដានការប្រព្រឹត្តទៅនៃពិធីនោះ។ លើសពីនេះទៅទៀតក៏មានភារកិច្ចធ្វើការសិក្សាវិស្វកម្មវិទ្យាស្រាវជ្រាវកុលាលភាជន៍ រៀបចំប្លង់ប្រើប្រាស់ដីធ្លីក្នុងតំបន់ប្រាសាទព្រះវិហារ និងចុះបញ្ជីសារពើភណ្ឌប្រាសាទទាំងអស់ក្នុងតំបន់ប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌស្រាវជ្រាវបេតិកភណ្ឌរូបិយ និងអរូបិយ គ្រប់គ្រងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ជីអាយអេស និងដឹកនាំ គ្រប់គ្រងកិច្ចដំណើរការរបស់មណ្ឌលអន្តរជាតិតម្កល់ឯកសារប្រាសាទព្រះវិហារ ព្រមទាំងមានតួនាទី ស្តារ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាអាទិ៍ ផ្លូវ ស្ពាន លូ និងប្រឡាយក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីដ្ឋានផ្សេងៗទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារ ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន

អាជ្ញាធរជាតិព្រះវិហារស្តីពីសកម្មភាព ការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនប្រធានអាជ្ញាធរជាតិព្រះវិហារ [35]។

### គ.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ តំបន់ប្រាសាទព្រះវិហារ

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចជារៀបចំទិសដៅអភិវឌ្ឍន៍ទេសចរណ៍សម្រាប់រយៈពេលមធ្យម និងរយៈពេលវែងតំបន់ប្រាសាទព្រះវិហារ ដោយសហការជាមួយអាជ្ញាធរ ពាក់ព័ន្ធឱ្យស្របទៅនឹងគោលនយោបាយ ទេសចរណ៍របស់រាជរដ្ឋាភិបាល រួមចំណែកក្នុងការលើកតម្លៃរមណីយដ្ឋាននិងប្រាង្គប្រាសាទនានាក្នុងតំបន់ខេត្តព្រះវិហារ រៀបចំវិធានស្តីពីការគ្រប់គ្រងទេសចរណ៍នៅក្នុងតំបន់ឧទ្យានប្រាសាទព្រះវិហារគ្រប់គ្រងពិធីនានាដែលរៀបចំ ក្នុងតំបន់ប្រាសាទព្រះវិហារព្រមទាំងរកចំណូលផ្សេងៗទៀតដែលបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការលក់ផលិតផលបន្ទាប់បន្សំទាក់ទងទៅនឹងរូបភាពប្រាសាទព្រះវិហារឃោសនាផ្សព្វផ្សាយនិងសិក្សាទីផ្សារ និងផ្តល់ព័ត៌មានសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ ទាក់ទងទៅនឹងប្រាង្គប្រាសាទ បរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងទទួលបណ្តុះបណ្តាលបំប៉នវិជ្ជាបន្ថែមដល់មគ្គុទេសទេសចរណ៍សម្រាប់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិប្រាសាទព្រះវិហារស្តីពី សកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនប្រធានអាជ្ញាធរជាតិព្រះវិហារ [36]។

### ឃ. នាយកដ្ឋាននគរូបនីយកម្មអភិវឌ្ឍន៍តំបន់ប្រាសាទព្រះវិហារ និងប្រជារាស្ត្រ

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចជាចូលរួមសហការជាមួយអាជ្ញាធរគ្រប់គ្រងលំដាប់ថ្នាក់ ដែលពាក់ព័ន្ធដើម្បីគិតគូរ និងលើកផែនការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព តុល្យភាព និងសមាហរណភាពក្នុងតំបន់ប្រាសាទព្រះវិហារព្រមទាំងតំបន់ពាក់ព័ន្ធផ្សេងទៀត និងរៀបចំគម្រោងប្លង់មេ សម្រាប់នគរូបនីយកម្មនៃតំបន់អភិវឌ្ឍន៍ (តំបន់៣) និងកំណត់ទិសដៅសម្រាប់បែបបទប្រើប្រាស់ដីធ្លី និងបទដ្ឋានសម្រាប់សាងសង់នៅតំបន់ប្រាសាទព្រះវិហារ ដោយសហការជាមួយអាជ្ញាធរដែនដី មន្ទីរជំនាញពាក់ព័ន្ធរួចដាក់ជូនប្រធានអាជ្ញាធរជាតិព្រះវិហារ ពិនិត្យ និងសម្រេចតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ។ ហើយពិនិត្យ និងផ្តល់

[35] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១៣៤ ដល់ទំព័រទី១៣៦

[36] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១៣៦ ដល់ទំព័រទី១៣៧

យោបល់លើការចេញលិខិតអនុញ្ញាតឱ្យរុះរើ និងសាងសង់សំណង់នានាសម្រាប់តំបន់ការពារដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ និងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ឆ្នាំ ២០០៦និង ដោយយោងតាមអនុក្រឹត្យថ្មីនៃអនុក្រឹត្យចាស់ទាំងពីរ រួមដាក់ជូនប្រធាន តាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍លើការស្តាបនាដោយយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ជាធរមាន វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគ និងអភិវឌ្ឍន៍ទាំងឡាយក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងរួមចំណែកក្នុងការកំណត់មុខសញ្ញានៃគម្រោងវិនិយោគ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការអនុវត្តគម្រោងទាំងនោះសម្រាប់តំបន់ប្រាសាទព្រះវិហារ។ ហើយធ្វើការខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងតំបន់ខេត្តព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត តាមដានការប្រែប្រួលនៃកំណើន និងកម្រិតជីវភាពរស់នៅរបស់ប្រជាជនដើម្បីបង្កើនការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជននៅក្នុងតំបន់ខេត្តព្រះវិហារ និងធ្វើសមាហរណកម្មវិស័យ កសិទេសចរណ៍ ដោយផ្តួចផ្តើម ឱ្យមានកសិកម្មបែបជីវសាស្ត្រ និងរៀបចំឱ្យមានខ្សែចង្វាក់ទីផ្សារសម្រាប់ផលិតផលកសិកម្ម ព្រមទាំងធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារស្តីពី សកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនប្រធានអាជ្ញាធរជាតិព្រះវិហារ។[37]

### ខ. នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចជាធ្វើការគ្រប់គ្រងទឹកទាំងបរិមាណ និងគុណភាពនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត សិក្សាអំពីរុក្ខជាតិ និងជីវិតសត្វនៅក្នុងតំបន់ប្រាសាទព្រះវិហារ និងនៅខេត្តព្រះវិហារ និងធ្វើការគ្រប់គ្រងព្រៃឈើនៅក្នុងឧទ្យានប្រាសាទព្រះវិហារ និងឧទ្យានផ្សេងៗទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហាររួមមានការអភិរក្ស ថែទាំ និងការដាំកូនឈើឡើងវិញ ព្រមទាំងធ្វើការសិក្សាអំពីបរិស្ថានបរិយាកាស និងអាកាសធាតុដោយរៀបចំឱ្យមានសំណង់ ឧតុនិយម អាកាសធាតុ ប្រមែប្រមូលរាល់ទិន្នន័យដែលមានស្រាប់នៅក្នុងតំបន់តាមដានការប្រែប្រួលអាកាសធាតុ ឥទ្ធិពលដែលមានទៅលើជលសាស្ត្រ និងកសិកម្ម និងការបំពុលបរិស្ថាន ការបំពុលខ្យល់ ព្រមទាំងការរំខានដោយសំឡេង ហើយក៏ធ្វើការសិក្សាដីសម្រាប់កសិកម្ម និងព្រៃឈើ ដើម្បីប្រើប្រាស់ឱ្យសមស្របតាមគុណភាពប្រភេទដីនីមួយៗក្នុងតំបន់ប្រាសាទព្រះវិហារ និងធ្វើការសិក្សាអំពីការអភិវឌ្ឍប្រកប

[37] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១៣៧ ដល់ទំព័រទី១៣៨

ដោយ និរន្តរភាព ដោយសហការសិក្សារួមគ្នាជាមួយនាយកដ្ឋានជំនាញនានា ទៅលើផ្ទៃកខាងលើដី និងក្រោមដី អាកាសធាតុរុក្ខជាតិ និងប្រាសាទនានា។[38]

## ច.នាយកដ្ឋានសណ្ដាប់ធ្នាប់និងសហប្រតិបត្តិការ

នាយកដ្ឋាននេះមានតួនាទី និងភារកិច្ចដូចជាការពារ និងថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយអាជ្ញាធរជាតិព្រះវិហារ។ មួយវិញទៀតនាយកដ្ឋានក្ដាប់បានផែនទីប្លង់មេនៃតំបន់ទាំង៤ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិព្រះវិហារលើផែនការ និងវិធានការក្នុងការចាត់ចែងកងកម្លាំងឱ្យការពារនៅតាមគោលដៅនានាដែលបានកំណត់ និងមានភារកិច្ចក្ដាប់សភាពការណ៍ និងស្រាវជ្រាវរកឱ្យឃើញនូវបទល្មើសផ្សេងៗ និងធ្វើជាស្ទូលផ្ដល់ព័ត៌មានជូនដល់អាជ្ញាធរជាតិព្រះវិហាររៀបចំឯកសារ និងបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធនឹងបទល្មើសក្នុងតំបន់អភិរក្សជូនអាជ្ញាធរជាតិព្រះវិហារ ដើម្បីមានវិធានការតាមផ្លូវច្បាប់។ ហើយសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការទប់ស្កាត់ និងបំបាត់បទល្មើសដែលកើតមានក្នុងតំបន់អភិរក្ស ព្រមទាំងមានតួនាទីត្រួតពិនិត្យ ឃ្លាំមើល និងទប់ស្កាត់ជាប្រចាំលើការសាងសង់សំណង់ក្នុង រមណីយដ្ឋានប្រាសាទព្រះវិហារ និងដោយមានការសហការជាប្រចាំជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នគរបាល កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ច ដើម្បីធ្វើការទប់ស្កាត់ និងមានវិធានការចំពោះការកាប់បំផ្លាញព្រៃឈើ ការរំលោភបំពាន ការព័ទ្ធរបងយកដី ការសាងសង់លំនៅឋាន និងសំណង់អគារដែលគ្មានច្បាប់អនុញ្ញាត នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងសំណង់ដែលត្រូវការពារ ដោយអាជ្ញាធរជាតិព្រះវិហារ និងសហការជាមួយនគរបាលការពារបេតិកភណ្ឌដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើគាស់ រុករក និងលួចវត្ថុបុរាណក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត ហើយក៏បានសហការជាមួយអង្គភាពនគរបាលទេសចរណ៍ ក្នុងករណីមានការពាក់ព័ន្ធដល់កិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត និងទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការណែនាំរបស់អគ្គនាយក ឬអគ្គនាយករងទទួលបន្ទុក និងប្រធានអាជ្ញាធរជាតិព្រះវិហារ ព្រមទាំងធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាសឆមាស ៩ខែប្រចាំឆ្នាំ និងរបាយការណ៍ស្ដីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនប្រធាន អាជ្ញាធរជាតិព្រះវិហារ[39]។

[38] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១៣៩

[39] សៀវភៅ នីតិនគរូបនីយកម្ម បណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី ១៣៩ ដល់ទំព័រទី១៤១

## ២.២ ធនធាននិងសមិទ្ធផលរបស់អាជ្ញាធរជាតិព្រះវិហារ

នៅក្នុងសកម្មភាពក្នុងការការពារនិង ថែរក្សាប្រាសាទព្រះវិហាររបស់អាជ្ញាធរជាតិព្រះវិហារ គឺត្រូវការចំណាយនូវថវិកាជាច្រើន នៅជុំវិញបញ្ហានេះ យើងនឹងលើកយក ពីរចំនុចមកធ្វើការបកស្រាយគឺ ( ២.២.១ ) ធនធាន និង ( ២.២.២ ) សមិទ្ធផល។

### ២.២.១ ធនធាន

យោងតាមមាត្រា១៤ ជំពូកទី៥ នៃព្រះរាជក្រឹត្យស្ដីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារអាជ្ញាធរជាតិនេះមានធនធានដូចជា វិភាគទានពីរដ្ឋ និងពីឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុងអំណោយ និងវិភាគទានអន្តរជាតិដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិនេះ ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរជាតិ ដូចជាបំណុល ថ្លៃឈ្នួល បានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្តល់មកពីអង្គការសារធារណៈ ឬឯកជន កម្ចីដែលបានធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិនេះ ចលនវត្ថុ និងអចលនវត្ថុដែលសប្បុរសជនអង្គការជាតិ និងអង្គការអន្តរជាតិប្រគល់ឱ្យ ។ល។ ម្យ៉ាងវិញទៀតគំរោងចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ត្រូវដាក់ជូន ក្រុមប្រឹក្សាភិបាលយ៉ាងយូរបំផុតនៅថ្ងៃទី០១ ខែតុលា ។

ថវិកាបស់អាជ្ញាធរជាតិព្រះវិហារត្រូវរៀបចំឡើងដោយ ប្រធាននៃអាជ្ញាធរជាតិព្រះវិហារដោយមានភ្នាក់ងារគណនេយ្យជាជំនួយ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល។ ក្នុងអនុវត្តគម្រោងថវិកានេះប្រធានអាជ្ញាធរជាអាណាប័ក ហើយភ្នាក់ងារគណនេយ្យជាអ្នកទូទាត់។

#### ក. ការរៀបចំថវិកា

គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានធនធានផ្ទាល់ខ្លួន និងធនធានដែលរដ្ឋបាលផ្តល់ឱ្យនោះ ចាំបាច់ត្រូវមានការរៀបចំថវិកាធ្វើចំណូល និងចំណាយ។ ការរៀបចំថវិកានេះជាតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន ត្រូវចែងអំពីបែបបទនៃការរៀបចំថវិកាចំណូល និងចំណាយថវិកាលម្អិតសម្រាប់គ្រឹះស្ថានរដ្ឋបាលសាធារណៈ ដោយផ្អែកលើសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំថវិកា និងអាទិភាពគោលនយោបាយរបស់ខ្លួន។ គម្រោងថវិកានេះធ្វើឡើងដោយអាណាប័កដើមខ្សែដែលហៅថា ប្រធាននៃគ្រឹះស្ថានរដ្ឋបាលសាធារណៈ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលធ្វើការសម្រេច និងផ្ញើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរបំផុតនៅចុងខែ កញ្ញា រៀងរាល់ឆ្នាំនីមួយៗ។ ចំណែកការរៀបចំថវិកាបស់អាជ្ញាធរជាតិព្រះវិហារវិញ ត្រូវធ្វើឡើងដោយប្រធានអាជ្ញាធរជាតិនេះ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវត្រួតពិនិត្យ និងសម្រេចមុននឹងផ្ញើគម្រោងថវិកាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រធានក្រុមប្រឹក្សាភិបាល

នៃអាជ្ញាធរជាតិព្រះវិហារ ចាំបាច់ត្រូវចែងអំពីបែបបទ នៃការរៀបចំថវិកាដែលបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួនឱ្យ មានលំនឹងរវាងចំណូល និងចំណាយរបស់ខ្លួន។ រាល់សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលដែលទាក់ទង នឹងទម្រង់បែបបទនៃការរៀបចំថវិកាចាំបាច់ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិន។

**ខ.ការអនុវត្តថវិកា**

អាណាប័កប្រធានគ្រឹះស្ថានជាអាណាប័កដើមខ្សែ បានន័យថារាល់ការបញ្ជាចំណាយ លើគម្រោងថវិកាដែលបានអនុម័តរួចស្ថិតនៅលើការសម្រេចរបស់ប្រធានគ្រឹះស្ថាន។

យោងតាមអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ អាណាប័កត្រូវគោរពដំណាក់កាល៤ មានដូចជា កិច្ចសន្យា កិច្ចជំរះបញ្ជី និងការទូទាត់។ ភ្នាក់ងារគណនេយ្យ ជាអ្នកទទួលបន្ទុកក្នុងការងារទទួលខុសត្រូវនិងប្រមូលចំណាយដែលអាណាប័ក បានប្រគល់ឱ្យប្រមូលឥណទេយ្យ ដែលសង្កេតឃើញតាមកិច្ចសន្យាមូលប័ត្រកម្មសិទ្ធិ ឬមូលប័ត្រផ្សេងៗទៀតដែលគណនេយ្យករត្រូវធានាទុកដាក់ ព្រមទាំងបញ្ចូលក្នុងបេឡានូវប្រាក់ពន្ធដារបង់ដល់ដៃ និងចំណូលគ្រប់ប្រភេទទាំងអស់ដែលរដ្ឋមាន នីតិសម្បទាទទួលការទូទាត់ចំណាយតាមបញ្ជារបស់អាណាប័កដែលនៅអមជាមួយ។ ភ្នាក់ងារគណនេយ្យសាធារណៈក៏ជាអ្នកការពារនិងរក្សាទុកនូវមូលនិធិតម្លៃនានារបស់រដ្ឋនិងគ្រឹះស្ថានសាធារណៈផ្សេងៗទៀត កាន់កាប់មូលនិធិ និងចលនាគណនេយ្យប្រាក់ទំនេររក្សាទុកដាក់លិខិតយុត្តិកម្មនៃកិច្ចប្រតិបត្តិការនិងឯកសារគណនេយ្យព្រមទាំងកាន់កាប់គណនេយ្យតាមតំណែងដែលខ្លួនបានដឹកនាំ។

យោងតាមមាត្រា១៣ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈមានភារកិច្ចដូចជាៈ នៅក្នុងវិស័យចំណូល គឺត្រួតពិនិត្យភាពត្រឹមត្រូវ នៃដីការចំណូល។ នៅក្នុងវិស័យចំណាយ ត្រួតពិនិត្យលក្ខណៈសម្បត្តិរបស់អាណាប័ក ឬអាណាប័កតាមប្រទានសិទ្ធិ សំណល់ ទំនេរនៃឥណទាន ការកំណត់ត្រឹមត្រូវពិតប្រាកដខ្ទង់ចំណាយតាមជំពូកដែលពាក់ព័ន្ធ និងរូបធាតុ និងមុខសញ្ញារបស់វា ការបញ្ជាក់ភាពត្រឹមត្រូវអំពីសេវាដែលបានធ្វើហើយ និងភាពប្រាកដ នៃការគណនាជំម្រះឥណទេយ្យមានការបញ្ជាក់និន្នាការរបស់អភិបាលហិរញ្ញវត្ថុលើកិច្ចសន្យា និងអាណត្តិ ផលិតកម្មនៃយុត្តិកម្មឥណទេយ្យអនុវត្តន៍វិធានបទបញ្ញត្ត ស្តីពីអាជ្ញាយុកាល និងប្រាសចាកសិទ្ធិឥណទេយ្យ។ ក្នុងវិស័យបេតិកភណ្ឌត្រួតពិនិត្យការរក្សាសិទ្ធិបុព្វសិទ្ធិ និងនិក្ខេប ព្រមទាំងការរក្សាទុកដាក់ទ្រព្យសម្បត្តិដែលមានចែងក្នុងគណនេយ្យរូបធាតុ។

### ២.២.២ សមិទ្ធផល

អាជ្ញាធរជាតិព្រះវិហារ មានសកម្មភាពជាចម្បង គឺផ្តោតទៅលើការកសាងរបាយការណ៍ជឿនលឿន ឱ្យបានហើយជាស្ថាពរ ដើម្បីផ្ញើទៅអង្គការយូណេស្កូនៅទីក្រុងបារីស និងគណកម្មាធិការបេតិកភណ្ឌពិភពលោកប្រចាំទីក្រុង **កេបិច** ប្រទេសកាណាដា ឲ្យបានមុនថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០០៨។ នៅតំបន់ប្រាសាទព្រះវិហារសភាពការណ៍មានការស្ងប់ស្ងាត់ល្អនារដូវវស្សាភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិនៅតែបន្តទៅទស្សនាជារៀងរាល់ថ្ងៃមិនដាច់ នេះបើតាមការអះអាងរបស់មន្ត្រីអាជ្ញាធរជាតិព្រះវិហារ។ ជាក់ស្តែងពេលនេះថ្វីដ្បិតតែមានភ្លៀងធ្លាក់ក៏ពិតមែន ប៉ុន្តែនៅលើប្រាសាទព្រះវិហារមានចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅតែកើនឡើងទៅទស្សនាដដែល ដូចជានៅរមណីដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រ ប្រាសាទព្រះវិហារក្នុងមួយ ថ្ងៃៗមានពី១០០នាក់ ទៅ១៥០នាក់ ។ គេសង្កេតឃើញថា ភ្ញៀវទេសចរណ៍មិនត្រឹមតែទៅកម្សាន្តនោះទេ ថែមទាំងពួកគេឡើងទៅធ្វើពិធីបុណ្យទាននៅក្នុងវត្តកែវសិក្ខាគិរីស្វារៈ ហៅវត្តប្រាសាទព្រះវិហារ តាមគន្លងព្រះពុទ្ធសាសនាដែលជាសាសនារបស់ជនជាតិខ្មែរយើងជារៀងរាល់ថ្ងៃផងដែរ ។ បើយោងតាមប្រសាសន៍របស់លោក គង់ ពុទ្ធិកា(អគ្គនាយកនៃអាជ្ញាធរជាតិព្រះវិហារ) លោកមានប្រសាសន៍ថា គោលនយោបាយរបស់រាជរដ្ឋាភិបាលបានផ្សារភ្ជាប់ផ្លូវគមនាគមន៍ផ្លូវគោកពីខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង និងពីខេត្តសៀមរាបឆ្ពោះទៅកាន់ប្រាសាទព្រះវិហាររួចរាល់អស់ហើយ ចំណែកឯផ្លូវអាកាសថ្វីត្បិតតែខេត្តព្រះវិហារមិនមានយន្តហោះចុះចតជាអចិន្ត្រៃក៏ដោយ ក៏ភ្ញៀវទេសចរណ៍ខ្លះដែលមានលុយកាក់ អាចជួលឧទ្ធម្ភាគចក្រធុនតូចពីក្រុមហ៊ុនចុះចតក្បែរជើងភ្នំហើយឡើងទៅទស្សនាប្រាសាទបាន ហើយអាជ្ញាធរព្រះវិហារក៏មានបំណងបើកវគ្គបណ្តុះបណ្តាលមួយសំរាប់បណ្តុះបណ្តាលមគ្គុទេសទេសចរណ៍ផ្ទាល់នៅតំបន់ប្រាសាទព្រះវិហារផ្ទាល់តែម្តងមិនតែប៉ុណ្ណោះនៅក្នុងរយៈពេល១១ខែ នៃឆ្នាំ២០១៥ មានភ្ញៀវទេសចរណ៍ជាតិ ជិត ៩ ម៉ឺននាក់ ចំណែកឯភ្ញៀវទេសចរណ៍អន្តជាតិប្រហែលជា ១ម៉ឺននាក់[40]។ ហើយនៅក្នុងខែមេសា ឆ្នាំ២០១៦ (ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦) ចំនួនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិដែលបានចូលទស្សនារមណីយដ្ឋានប្រាសាទព្រះវិហារមានដូចជាភ្ញៀវជាតិចំនួន ១៤,៣៩៩នាក់ ក្នុងនោះស្រី ៧,៤៦៨នាក់ និង ប្រុស ៦,៩៣១នាក់ និងភ្ញៀវទេសចរណ៍អន្តរជាតិមានចំនួនសរុប ១,១២៩នាក់ ក្នុងនោះមានស្រី ៥៣០នាក់ និងប្រុស ចំនួន ៥៩៩នាក់ ដូចនេះចំនួនសរុបប្រចាំខែមេសា មានចំនួន ១៥,៥២៨នាក់ ក្នុងនោះស្រី ៧,៩៩៨នាក់ និងប្រុសចំនួន៧.៥៣០នាក់[41]។ មិនតែប៉ុណ្ណោះអាជ្ញាធរជាតិព្រះវិហារក៏បានចុះកិច្ចព្រមព្រៀងមួយនៅថ្ងៃទី០៣ ខែមិថុនា

[40] វិទ្យុអាស៊ីសេរី ផ្សាយនៅម៉ោង ៧:៥៥ នាទីយប់ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

[41] សេចក្តីប្រកាសពត៌មានរបស់អាជ្ញាធរជាតិព្រះវិហារ (www.preahvihearauthority.gov.kh/trourist-statistic)

ឆ្នាំ២០០៩ រវាង ICCROM និងអាជ្ញាធរជាតិព្រះវិហារ ដែលត្រូវបានចុះហត្ថលេខាដោយនាយក ICCROM (International Centre for Study of the Preservation and Restoration of Cultural Property) លោក Mounir Bouchenaki) និងអគ្គនាយកអាជ្ញាធរព្រះវិហារគឺលោកហង់ សុទ្ធ ដែលកិច្ចព្រមព្រៀងនេះ និងអនុញ្ញាតអោយឲ្យមានការរៀបចំនៃកម្មវិធី បណ្តុះបណ្តាលយ៉ាងច្បាស់លាស់មួយ ក្នុងគោលបំណងបង្កើនសមត្ថភាពដល់អ្នកជំនាញផ្នែកបេតិកភណ្ឌដល់អាជ្ញាធរព្រះវិហារ។ លើសពីនេះទៅទៀតការអនុវត្តការអនុវត្តកម្មវិធីនេះគឺស្ថិតនៅក្នុងគោលបំណង ក៏ដូចជាការសម្រេចចិត្តរបស់គណកម្មាធិការបេតិកភណ្ឌពិភពលោកនៅទីក្រុងកេបិចឆ្នាំ២០០៨។[42] លើសពីនេះទៅទៀតអាជ្ញាជាតិព្រះវិហារបានសហការណ៍ជាមួយអាយស៊ីស៊ី-ព្រះវិហារ (ICC-Preah Vihear)ដែលជាពាក្យកាត់មកពីភាសាអង់គ្លេសថាInternational Coordinating Committee for the Conservation and Enhancement of the Temple of Preah Vihear ដែលមានន័យជាភាសាខ្មែរថា គណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការអភិរក្ស និងការអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រប្រាសាទព្រះវិហារ។ គណកម្មាធិការនេះត្រូវបានបង្កើតឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់អង្គការយូណេស្កូនាសម័យប្រជុំនៅទីក្រុងប៉ារីសប្រទេសបារាំងក្នុងឆ្នាំ២០១៤ ដែលមានប្រទេសចិន និងប្រទេសឥណ្ឌាជាសហប្រធាន និងមានសមាជិក ៧ ប្រទេសផ្សេងទៀតមាន ប្រទេសជប៉ុន បារាំង សហរដ្ឋអាមេរិច ប៊ែលហ្សិក ថៃ កូរ៉េខាងត្បូង និងកម្ពុជា។ អាយស៊ីស៊ី-ព្រះវិហារ (ICC-Preah Vihear) ជាយន្តការអន្តរជាតិមួយក្នុងការអភិរក្ស និងអភិវឌ្ឍប្រាសាទព្រះវិហារ ដែលគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងអ្នកជំនាញមកពីគ្រប់ប្រទេសពាក់ព័ន្ធដើម្បីលើកតម្លៃជាសាកល និងស្នាដៃឯកនៃសិល្បៈស្ថាបត្យកម្មខ្មែរដ៏លេចធ្លោឲ្យស្ថិតនៅគង់វង្សជាអមតៈ។ អាយស៊ីស៊ី-ព្រះវិហារ (ICC-Preah Vihear) ជាយន្តការអន្តរជាតិមួយដើម្បីសម្របសម្រួលរាល់ជំនួយទាំងអស់ដែលផ្តល់ឲ្យដោយប្រទេសនិងអង្គការនានាដើម្បីការការពារអភិរក្ស និងស្តារឡើងវិញនូវប្រាង្គប្រាសាទនានាដែលបានបាក់បែក ខូចខាត ដោយសារកត្តាមនុស្ស និងធម្មជាតិ។ អាយស៊ីស៊ី-ព្រះវិហារ (ICC-Preah Vihear) នឹងក្លាយជាវេទិកាមួយដែលស្ថាបត្យករ វិស្វករ បុរាណវិទូ អ្នកស្រាវជ្រាវ និងអ្នកជំនាញបច្ចេកទេសខាងវិស័យផ្សេងៗអាចផ្លាស់ប្តូរបទពិសោធន៍របស់ខ្លួន ក៏ដូចជាចែករំលែក និងផ្តល់ជាពុទ្ធិ និងទស្សនៈចំពោះការអភិរក្ស និងអភិវឌ្ឍនៅតំបន់ប្រាសាទព្រះវិហារ[43]។

[42]ការផ្សាយរបស់ International Centre for the study of the preservation and restoration of cultural property នៅថ្ងៃទី ២៤ មិថុនា ឆ្នាំ២០០៩

[43] ដកស្រង់ចេញពី www.preahvihearauthority.gv.kh/international-cooperation/icc-preahvihear

**ក. ការងាររៀបចំរបាយការណ៍ជឿនលឿន**

របាយការជឿនលឿន ជាកិច្ចការសំខាន់ចាំបាច់ និងបន្ទាន់បំផុតដែលរាជរដ្ឋាភិបាលត្រូវបញ្ជូនទៅ អង្គការយូណេស្កូអន្តរជាតិ ។ ដើម្បីសម្រេចបានអាជ្ញាធរជាតិព្រះវិហារ បានធ្វើកិច្ចការនេះ រួមមាន ការធ្វើទំនាក់ទំនង ធ្វើដំណើររួមជាមួយអ្នកជំនាញការនៃប្រទេសនីមួយៗដូចជា ប្រទេសបារាំង បែលហ្សិក ឥណ្ឌា សហរដ្ឋអាមេរិក ចិន ជប៉ុន ធ្វើដំណើរចុះឡើងពីភ្នំពេញទៅលើភ្នំប្រាសាទព្រះវិហារ ជាមួយកិច្ចការអន្តរាគមន៍ពីអង្គការស៊ីម៉ាក់ ហេឡូត្រាស់ និងកងកម្លាំងវិស្វកម្ម ។ ស្របពេលនោះអាជ្ញាធរជាតិព្រះវិហារបានរៀបចំទទួលថ្នាក់ដឹកនាំរាជរដ្ឋាភិបាលមានដូចជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណរដ្ឋមន្ត្រីទេសរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទេសរដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងប្រធានស្ថាប័ន រួមជាមួយអង្គភាពមួយចំនួនទៀត ហើយព្រមទាំងអង្គទូត និងអង្គការអន្តរជាតិនានា ដើម្បីទៅទស្សនាប្រាសាទព្រះវិហារ ស្វែងយល់ពី **លក្ខណៈសកល និងអច្ឆរិយៈ ជាទីសក្ការៈ** របស់ប្រាសាទព្រះវិហារ ។

ជាពិសេស អាជ្ញាធរជាតិព្រះវិហារ បានចូលរួមពិភាក្សា និងផ្តល់យោបល់ជាមួយអ្នកឯកទេសជំនាញបរទេសដើម្បីកសាងរបាយការណ៍ជឿនលឿនល្អមួយនិងឯកសារបំពេញបន្ថែមផ្សេងៗទៀតផ្ញើជូនអង្គការយូណេស្កូអន្តរជាតិប្រចាំទីក្រុងបារីស ប្រទេសបារាំង និងគណកម្មាការបេតិកភណ្ឌពិភពលើក ទីក្រុងកេបិច ប្រទេសកាណាដា ឲ្យបានមុនពេលកំណត់ ។

ជាងនេះទៅទៀត អាជ្ញាធរជាតិព្រះវិហារបានរៀបចំទទួល និងជូនដំណើរអ្នកជំនាញបច្ចេកទេសថៃ ចុះពិនិត្យដល់កន្លែងជាច្រើនលើក រួមទាំងប្រជុំពិភាក្សា ដើម្បីរកដំណោះស្រាយបច្ចេកទេសជាមួយភាគីថៃ។ អាជ្ញាធរធ្វើបែបនេះ ដើម្បីបញ្ចៀសកុំឲ្យប៉ះពាល់ដល់ការដាក់ប្រាសាទព្រះវិហារ ចូលជាបេតិកភណ្ឌពិភពលោកផង និងចង់រក្សាទំនាក់ទំនងល្អជាមួយប្រទេសថៃ ចៀសវាងការចាប់កំហុស ឬប្តឹងអំពីសំណាក់ភាគីថៃ ដោយរង់ចាំរហូតដល់ថ្ងៃប្រកាសសម្រេចចុះប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកជាផ្លូវការ ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងបានខិតខំបង្កើតទំនាក់ទំនងល្អជាមួយប្រទេសថៃ ដើម្បីគោរពនូវសេចក្តីសម្រេចរបស់កិច្ចប្រជុំលើកទី២១ នៃគណកម្មាធិការបេតិកភណ្ឌពិភពលោកនៅទីក្រុង **ក្រាយឌឺក** ទីក្រុងនៃប្រទេសញូហ្សេឡែន។

**ខ.ការងារដែលបំពេញក្នុងដំណាក់ការរៀបចំរបាយការណ៍ជឿនលឿន**

ទន្ទឹមនិងការខិតខំប្រឹងប្រែងធ្វើឲ្យសម្រេចនូវ របាយការណ៍ជឿនលឿន អាជ្ញាធរជាតិព្រះវិហារបានធ្វើការងារមួយចំនួនផងដែរ ដូចជា ការងារដំបូងដែលត្រូវធ្វើគឺនៅលើកំពូលភ្នំប្រាសាទព្រះវិហារ ប៉ុន្តែដោយនៅលើកំពូលភ្នំប្រាសាទព្រះវិហារ អាជ្ញាធរពុំមានកន្លែងស្នាក់នៅ ដូចនេះត្រូវធ្វើការជួសជុល អាគារចាស់ៗដែលទ្រុឌទ្រោម និងបង្កន់អនាម័យ សំរាប់ទទួកអ្នកជំនាញបច្ចេកទេស

បរទេសស្នាក់នៅ ប្រើប្រាស់ និងធ្វើការងារបណ្តោះអាសន្ន ។ នេះគឺជាការកសាងមូលដ្ឋានដំបូងនៅលើភ្នំប្រាសាទព្រះវិហារ។ ចំពោះការងារបន្ទាប់គឺ ការគ្រប់គ្រងតំបន់រមណីដ្ឋានប្រាសាទព្រះវិហារ អាជ្ញាធរជាតិព្រះវិហារបានលើកស្លាកសញ្ញា **តំបន់ការពារ** លើកប៉ាណូរូបផែនទីធំៗ និងសញ្ញា **កំណត់តំបន់នីមួយៗ** ដោយមានការចូលរួមពីអាជ្ញាធរភូមិ ឃុំ និងស្រុក ជាំក្សាន្ត ហើយធ្វើការផ្សព្វផ្សាយដល់សហគមន៍ ទប់ស្កាត់ការកាន់កាប់ដីធ្លីខុសច្បាប់ និងការកាប់ព្រៃឈើដោយអនាធិបតេយ្យ។ ទាក់ទងទៅនឹងការគ្រប់គ្រងបរិស្ថាន អាជ្ញាធរជាតិព្រះវិហារបានរៀបចំ ជួសជុលធុងសំរាមចាស់ៗ ដាក់ស្លាកសញ្ញាតូច ធំ នៅលើភ្នំ ធ្វើការកាត់ស្មៅ ដកស្មៅ ហើយសម្អាតទីធ្លាជាប្រចាំ កាប់រំលំដើមឈើធំៗ ដែល នឹងឈានទៅដល់ការដួលរលំលើប្រាសាទ ហើយការងារបន្ទាប់ពីការគ្រប់គ្រងគឺ កិច្ចការអន្តរាគមន៍ ដែលកិច្ចអន្តរាគមន៍នេះជាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញការបរទេស ដែលមានបទពិសោធន៍ខ្ពស់ៗ មកពីប្រទេសជាសមាជិកអង្គការយូណេស្កូអន្តរជាតិ រួមទាំងប្រទេសបារាំង ហើយបានផ្តល់អនុសាសន៍សំខាន់ៗ មួយចំនួនក្នុងក្របខណ្ឌ **អភិរក្ស និងគ្រប់គ្រង** ដល់អាជ្ញាធរជាតិព្រះវិហារ ។

គម្រោង និងផែនការអនុវត្តត្រូវបានលើក Michel Verrot និងលោក Elopis រៀបចំកសាងឡើង ហើយដែលមានអ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិព្រះវិហារជាអ្នក អនុវត្តផ្ទាល់ ក្រោមការណែនាំពីអ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ក្នុងការអនុវត្ត តែងតែមានការតាមដានពិនិត្យនៅការដ្ឋានផ្ទាល់ពីថ្នាក់ដឹកនាំអាជ្ញាធរជាតិព្រះវិហារ ដោយលោក Michel Verrot និងលោក Elopis ។ ម្យ៉ាងវិញទៀតប្រធានអាជ្ញាធរជាតិព្រះវិហារ ក៏បានធ្វើការងារសិក្សាស្រាវជ្រាវក្នុងការរៀបចំរមណីដ្ឋានប្រាសាទព្រះវិហារ អាជ្ញាធរជាតិព្រះវិហារបានសិក្សាស្រាវជ្រាវ អំពីគម្រោងចំណត រថយន្តនៅលើភ្នំ ដោយមានកិច្ចសហប្រតិបត្តិការពីអ្នកជំនាញបុរាណវិទ្យាមកពីស្ថាប័នអាជ្ញាធរជាតិអប្សរា ស្រង់ទិន្នន័យផ្ទះប្រជាជន និងស្រង់ទិន្នន័យអំពីស្លាកស្នាមផ្នែកបុរាណវិទ្យា ដែលមាននៅក្នុងបរិវេណគម្រោងបង្កើតចំណតរថយន្ត ហើយបានបំបាត់នូវខ្ទមតូចៗតូបលក់ដូរ នៅលើប្រាសាទព្រះវិហារ ឲ្យទៅធ្វើការលក់ដូរនៅផ្សារខាងក្រោមប្រាសាទវិញ ព្រមទាំងបានសិក្សា និងលើកគម្រោងទល់ប្រាសាទទី៥ រហូតដល់ប្រាសាទទី១ ដើម្បីឲ្យរចនាសម្ព័ន្ធប្រាសាទរឹងមាំ និងផ្តល់សុវត្ថិភាព ដោយសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញស្ថាបត្យករមកពីអាជ្ញាធរជាតិអប្សរា ។ ហើយការងារស្នូលដែលសំរេចបានទៀតនោះគឺការថែរក្សាប្រាសាទព្រះវិហារ អាជ្ញាធរជាតិព្រះវិហារ បានថែរក្សាប្រាសាទដោយ ការរៀបចំចាត់ចែងតាំងកម្លាំងថែរក្សាការពារជាប្រចាំនៅលើប្រាសាទ ហើយមានពលករជម្រះស្មៅ ដកកូនឈើដែលដុះតាមថ្មប្រាសាទ សម្អាតទីធ្លា ប្រមូលកាកសំណល់ផ្សេងៗ តាំង

ពីច្រកចេញចូលពីព្រំដែនកម្ពុជា-ថៃ ហើយបន្តសម្អាតពីកាំជណ្តើរខាងក្រោមឡើងដល់លើប្រាសាទ និងយាមដោយក្រុមផ្កាំព្រមទាំងស្លៀកសម្លៀកបំពាក់ឯកសណ្ឋានផងដែរ។ ជាងនេះទៅទៀត ដោយសង្កេតឃើញ ថាផ្ទៃកមួយចំនួននៃថ្មមានលក្ខណៈរប៉ាត់រប៉ាយ និងគ្មានសណ្តាប់ធ្នាប់ ទើប បណ្តាលឲ្យជាមូលហេតុប៉ះពាល់ដល់ចរាចររបស់ភ្ញៀវទេសចរណ៍ ដូចនេះ ដើម្បីឲ្យថ្មទាំងនោះមានសណ្តាប់ធ្នាប់ និងដើម្បីសុវត្ថិភាពនៃការធ្វើចរាចរណ៍ អាជ្ញាធរជាតិព្រះវិហារ បានរៀបចំវាឡើងវិញ ដោយរំកិលថ្មចេញ និងយកបំណែកថ្មមានក្បាច់ បំណែកថ្មគ្មានក្បាច់ ចេញពីខាងមុខជណ្តើរឡើងរបស់ក្លោងទ្វារទី៥ ហើយដាក់លើកំណល់ឈើដើម្បីបើកផ្លូវច្រកជណ្តើរឡើងឲ្យភ្ញៀវទេសចរណ៍មានការងាយស្រួលធ្វើដំណើរ។ លើសពីនេះទៅទៀត អាជ្ញាធរជាតិព្រះវិហារ បានធ្វើការផ្លាស់ប្តូរជណ្តើរឈើចាស់ដែលមានការពុកផុយចេញ ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ភ្ញៀវទេសចរណ៍ ។

**គ.សកម្មភាពការងារ**

ក្រៅពីការងារធំៗខាងលើការងាររៀបចំរមណីយដ្ឋានក៏សំខាន់ផងដែរ ហើយការងារនេះទទួលបានចូលរួមពីអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់និងពីប្រជាពលរដ្ឋមូលដ្ឋានអាជ្ញាធរជាតិព្រះវិហារបានសម្រេចធ្វើការចុះកិច្ចសន្យារវាងភាគីអាជ្ញាធរព្រះវិហារ និងប្រជាពលរដ្ឋដែលកំពុងរស់នៅលើផ្ទៃដី មួយម៉ឺនហិកតា (១០គ.ម x ១០គ.ម) ចាប់ពីភូមិសាឯម រហូតដល់ភូមិ "គ១" ដែលដីធ្លីទាំងនោះជាទ្រព្យសាធារណៈរបស់រដ្ឋ និងជាទ្រព្យសាធារណៈ ឯកជន ហើយដែលគ្រប់គ្រងដោយអាជ្ញាធរជាតិព្រះវិហារ ដោយឲ្យ រក្សាភាពដដែលមិនឲ្យមានការទិញលក់ ដូរ ផ្ទេរ ឬសង់តាមទំនើងចិត្ត។

ដើម្បីការពារបរិស្ថាន នៅតាមតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ អាជ្ញាធរជាតិព្រះវិហារបានអំពាវនាវឲ្យបងប្អូនដែលកំពុងលក់ដូរនៅមុខទីលាន ជណ្តើរនាគទាំងអស់ សូមបងប្អូនចូលលក់ដូរក្នុងផ្សារមុខទីលានជណ្តើរនាគនៅតាមលេងរៀងតូបដែលក្រុមការងារជាពិសេសថ្នាក់ជាតិបានប្រគល់ជូន។ ចំពោះបងប្អូនមិនទាន់ទទួលបានតូបលក់ដូរបងប្អូនអាចទាក់ទងជាមួយក្រុមការងារសាងសង់ ដើម្បីជួយសាងសង់ជូនទៅតាមប្លង់គំរូក្នុងតម្លៃអគារមាន ៦ខ្ទុះដោយមួយខ្ទុះមានតំម្លៃ ៤២៦ ដុល្លា និងអគារមាន ១០ខ្ទុះ ក្នុងមួយខ្ទុះមានតំម្លៃ ៤៤៩ ដុល្លា។ នៅក្នុងនោះផងដែរអាជ្ញាធរជាតិព្រះវិហារ បានរៀបចំតុបតែងលំអរសួនច្បារសំរាប់ទទួលភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ និងគោរពតាមគោលការណ៍អង្គការយូណេស្កូ ហើយបានសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ សន្តិសុខ អនាម័យ និងសេវាកម្មលក់ដូរក្នុងផ្សារមុខទីលានជណ្តើនាគ។ ចំពោះការងារគោលនយោបាយ និងផ្សព្វផ្សាញវិញ ដោយយោងតាមសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៥៩០ សជណ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីស្ថានភាពការគ្រប់គ្រងតំបន់ប្រាសាទព្រះវិហារ និងការរៀបចំបែងចែកដី សម្បទានសង្គមកិច្ចជូនប្រជាជននៅតាមតំបន់

ប្រាសាទព្រះវិហារ ដែលរងគ្រោះដោយការវាយប្រហារពីភាគីសៀម កាលពីថ្ងៃទី២៣ ខែ មេសា ឆ្នាំ២០០៩ និងយោងតាមសេចក្តីសម្រេចលេខ៤៨ សសរ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមការងារពិសេសថ្នាក់ជាតិបានរៀបចំការប្រជុំមួយ នៅថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០០៩ នៅទីបញ្ជាការស្រោលអគ្គបញ្ជាការសមរភូមិមុខ កងយោធពលខេមរភូមិន្ទនៅប្រាសាទព្រះវិហារ ដែលមានការចូលរួមពីសំណាក់តំណាង ក្រសួងស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាញសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៩៥០ សជណ កំណត់ផែនការ និងភារកិច្ចអនុវត្តតាមអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បង្កើតលេខាធិការដ្ឋាន ជាយន្តការបម្រើឲ្យក្រុមការងារពិសេសថ្នាក់ជាតិ។

នៅក្នុងអង្គប្រជុំបានពិភាក្សា និងសម្រេចលទ្ធផលដូចតទៅ ៖ បានបែងចែកថវិកាជំហានទី១ របស់ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនប្រជាជននៅផ្សាជើងប្រាសាទ ចំនួន៣១៩ គ្រួសារ និងសម្ភារៈមួយចំនួន។ ហើយបានស្នើរសុំថវិកាជំហានទី២ សម្រាប់ប្រជាជនភូមិ គ១ ចំនួន ៤៧៣ គ្រួសារ។ ហើយបានកំណត់ទីតាំងប្លង់មេសាងសង់ភូមិតេជោ កំណត់អាងស្តុកទឹក ជីកអណ្តូង និងអាងស្តុកទឹកនៅផ្សារជើងប្រាសាទ កំណត់តំបន់អតិភាពដែលត្រូវដោះមីនជាបន្ទាន់ កំណត់ទីតាំងផ្សារជើងប្រាសាទ និងបន្ទប់អនាម័យ សាធារណៈ សំរាប់ភ្ញៀវទេសចរណ៍។ ក្នុងនោះផងដែរ អង្គប្រជុំបានឯកភាពលើប្លង់មេ សម្រាប់តំបន់ប្រាសាទព្រះវិហារ និងឯកភាពលើប្លង់មេសម្រាប់សាងសង់លំនៅឋាន លើសពីនេះទៅទៀតអង្គប្រជុំបានផ្តល់បច្ចេកទេស ជូនមូលនិធិបាយ័នលើការចាក់កៅស៊ូផ្លូវពីចំណុច T និងស្ថាបត្យកម្មអគារបដិសណ្ឋាកិច្ច ហើយបានវាយតម្លៃ និងប្រគល់ការងារជូនក្រុមសាងសង់សាលាបឋមសិក្សាសម្តេចតេជោ និងមន្ទីពេទ្យសម្តេចជាស៊ីម។ម្យ៉ាងវិញទៀត ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទៀតសោតលទ្ធផលទាំងឡាយដែលសម្រេចបានសុទ្ធតែបានមកដោយសារកិច្ចសហប្រតិបត្តិការ យ៉ាងស្អិតរមួត ដោយមិនអាចកាត់ផ្តាច់បានពីការជួយឧបត្ថម្ភពីអាជ្ញាធរខេត្ត ស្រុក ឃុំ ភូមិ និងប្រជាពលរដ្ឋ ព្រមទាំងកងកម្លាំងប្រដាប់អាវុធឈរជើងនៅតំបន់គ្រប់ប្រភេទ ពិសេសជាមួយថ្នាក់ដឹកនាំខេត្តព្រះវិហារ ដែលគ្រាដំបូងបានជួយឧបត្ថម្ភខាងផ្នែកហិរញ្ញកិច្ច សង្គមកិច្ច សន្តិសុខ សុវត្ថិភាពដល់ការគ្រប់គ្រងរមណីដ្ឋានកន្លងមក។

ក្រៅពីនេះអាជ្ញាធរជាតិព្រះវិហារ បានសហប្រតិបត្តិការយ៉ាងល្អប្រសើជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការផ្សព្វផ្សាញពីភារកិច្ចរបស់អាជ្ញាធរជាតិព្រះវិហារ ក្នុង ការហាមឃាត់ការកាប់ព្រៃឈើ ការទន្ទ្រានដី និង រំលោភចាប់យកដីខុសច្បាប់ ការចុះហត្ថលេខាលើប័ណ្ណបញ្ជាក់ការទិញលក់ដី ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ ដែរលជាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សិទ្ធិចេញលិខិតអនុញ្ញាតសាងសង់ក្នុងតំបន់ការពារ។ លើសពីនេះទៅទៀត

ធ្វើការផ្សព្វផ្សាយ និងបំផុសឲ្យមានការចាប់អារម្មណ៍ស្នេហាជាតិ ស្នេហាដី និងប្រាសាទបុរាណ ប្រវត្តិសាស្ត្រ ពីសំណាក់យុវជន សិស្ស និស្សិត។

មិនតែប៉ុណ្ណោះដោយយោងតាមរបាយការណ៍សង្ខេប របស់ ឯកឧត្តម ជុច ភឿន ដែលជាអតីតប្រធានអាជ្ញាធរជាតិព្រះវិហារ ក្នុងពីធីប្រកាស និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំអាជ្ញាធជាតិរព្រះវិហារ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រីបាន អោយដឹងថាចាប់តាំងពីឯកឧត្តម ត្រូវបានរាជរដ្ឋាភិបាលតែងតាំងជាប្រធានអាជ្ញាធរជាតិព្រះវិហារមកដល់បច្ចុប្បន្ន អាជ្ញាធរនេះបានសំរេចនៅលទ្ធផលជាផ្លែផ្កាមានដូចជា ដោយយោងតាមព្រះរាជក្រឹត្យចាស់ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០០៦ និង ព្រះរាជក្រឹត្យថ្មីចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ស្តីពី ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ គឺបានពង្រីកតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារពី ៥៦២៥ កណ្តក់សញ្ញា ៨០ ហិកតា ទៅ ៩៥៨០១៨ ហិកតា និងដោយយោងតាមអនុក្រឹត្យចាស់ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ និងអនុក្រឹត្យថ្មីចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ស្តីពី ការរៀបចំ និងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ បានសម្រេចលទ្ធផលមួយទៀតគឺ បន្តរៀបចំ និងជំរុញផែនការផ្តល់ដី និងប្រគល់ប័ណ្ណកម្មសិទ្ធិប្រើប្រាស់ដីធ្លីជូនប្រជាជនតាមមូលដ្ឋាន និងគ្រួសារយោធិនស្ម័គ្រចិត្ត ដោយបានផ្លាស់ប្តូរលំនៅដ្ឋាន ពួកគាត់ចេញពីតំបន់ដែល មានសារៈប្រយោជន៍ក្នុងការអភិរក្សមិនតែប៉ុណ្ណោះអាជ្ញាធរជាតិព្រះវិហារក៏បានលើកស្ទួយតម្លៃសិក្សាលើបុរាណវិទ្យា បរិស្ថាន ធម្មជាតិ។ ម្យ៉ាងវិញទៀតអាជ្ញាធរនេះក៏បានរៀបចំ និងគ្រប់គ្រងតំបន់រមណីយដ្ឋាននៅក្នុងតំបន់ប្រាសាទព្រះវិហារ ឲ្យមានសុខដុមរមនាកម្មរវាង ប្រាសាទ ធម្មជាតិ និងប្រជាជនតាមរយៈការងារអភិរក្ស និងអភិវឌ្ឍស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបង្កើតអោយមានបទដ្ឋានគតិយុត្តនានាដើម្បីបម្រើអោយមានការគ្រប់គ្រង និងអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារប្រកបដោយចីរភាពក្នុងការគ្រប់គ្រងធនធានមនុស្ស បង្កើនជីវភាពរស់នៅ របស់ប្រជាជន និងគ្រួសារយោធិននៅក្នុងតំបន់ឲ្យមានប្រសិទ្ធិភាពខ្ពស់។

ចំពោះកិច្ចអភិរក្សវិញ បើយោងតាមរបាយការណ៍សង្ខេបដដែលរបស់ ឯកឧត្តម ជុច ភឿន អាជ្ញាធរជាតិព្រះវិហារបានត្រួតពិនិត្យ វាយតម្លៃការខូចខាតនៅតំបន់ប្រាសាទព្រះវិហារជាប្រចាំក្រោយការបាញ់ប្រហារពីកងទ័ពសៀមមកលើប្រាសាទព្រះវិហារ ចាប់ពីឆ្នាំ២០០៨ និង ២០១១ និងបានរាយការណ៍ជូនគណៈរដ្ឋមន្ត្រី។ លទ្ធផលដែលសម្រេចបានជាបន្តនោះគឺ ការងារសង្គ្រោះបន្ទាន់ចំពោះទីតាំងដែលអាចដួលរលំ ធ្វើការកាប់មែកឈើ ដើមឈើដែលអាជប៉ះពាល់ដល់ប្រាសាទ និងធ្វើកំណាយបុរាណសង្គ្រោះនៅតាមទីតាំងសំខាន់ៗ មួយចំនួនរបស់ប្រាសាទ ព្រមទាំងប្រមូលវត្ថុបុរាណដោយបានមកពីការជីកលានដ្ឋានសាងសង់ផ្លូវ បានមកពីប្រជាពលរដ្ឋ យកទៅរក្សាទុកនៅសារមន្ទីជាតិសាកលសម្តេចតេជោ ហ៊ុន សែន នៃប្រាសាទព្រះវិហារ និងធ្វើការ

សំអាត ថែទាំជាប្រចាំនៅបរិវេនប្រាសាទព្រះវិហារ ព្រមទាំងនៅសំអាតនៅតាមជណ្តើរបុរាណខាងកើត ហើយធ្វើការអភិរក្ស ការពារភ្លើងព្រៃ នៅក្នុងតំបន់អភិរក្សទាំងមូល។ មិនតែប៉ុណ្ណោះអាជ្ញាធរជាតិព្រះវិហារបានសហការគ្នាជាមួយក្រុមពិសេសថ្នាក់ជាតិក្នុង ការចុះបោះបង្គោលអភិរក្សសំរាប់កំណត់តំបន់ទាំងបួន នៃរមណីយដ្ឋានប្រាសាទព្រះវិហារ ហើយក៏បានស្តារបារាយណ៍ កសាងជណ្តើរឈើស្របតាមជណ្តើរថ្មបុរាណ និងរៀបចំសារជើងប្រាសាទដែលត្រូវបានបំផ្លាយដោយទាហាន សៀម-ល-។

បើយើងក្រលែកមកមើលការអភិវឌ្ឍដែលជាសមិទ្ធិផលរបស់អាជ្ញាជាតិព្រះវិហារ និងដោយយោងតាមប្រសាសន៍របស់ ឯកឧត្តម ជុច ភឿន ដដែលបានអោយដឹងថា អាជ្ញាធរជាតិព្រះវិហារបានសហការគ្នាយ៉ាងជិតស្និទជាមួយក្រុមការងារពិសេសថ្នាក់ជាតិតំបន់ប្រាសាទព្រះវិហារលើការរៀបរយប្រជាជន និងគ្រួសារកងទ័ពពីតំបន់អភិរក្សមកក្នុងភូមិធម្មជាតិសម្តេចតេជោ ហើយបានធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមានដូចជា ផ្លូវ ស្ពាន ឡូរំដោះទឹក សាលារៀន មណ្ឌលសុខភាព សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ វត្តអារាមដែលវត្តនោះមានឈ្មោះថា វត្តមរតកតេជោបុរីស្វារៈ និងហេដ្ឋារចនាសម្ព័នមួយចំនួន នៅក្រៅភូមិធម្មជាតិសម្តេចតេជោ រួមនាមកសាងសារមន្ទីជាតិសាកលសម្តេចតេជោហ៊ុនសែន និងបានសហការបច្ចេកទេសជាមួយកងវិស្វកម្មលើការងារសាងសង់ផ្លូវនៅក្នុងតំបន់ផ្លូវឡើងភ្នំប្រាសាទព្រះវិហារ ផ្លូវឡើងភ្នំទ្រព្យ ផ្លូវឡើងភ្នំចាក់ច្រែង -ល-។ មួយវិញទៀតអាជ្ញាធរនេះក៏បានរៀបចំច្បាប់សាងសង់ផ្ទះជូនប្រជាពលរដ្ឋ តាមស្តង់ដាដែលព្រះរាជក្រឹត្យបានចែងដោយផ្ទះនីមួយៗគឺសាងសង់ដោយគិតពីអ័ក្សនៃផ្ទៃដីផ្ទះ ដល់របងផ្ទះប្រវែង ២៥m និងពីរបងផ្ទះដល់តួផ្ទះ ៦m ហើយរៀបចំផែនការអភិវឌ្ឍន៍ចំពោះតំបន់ដែលមានចំងាយ ២គ.ម ពីរង្វង់មូល ដើម្បីរក្សាសណ្តាប់ធ្នាប់សាធាណៈអោយប្រសើឡើង ព្រមទាំងរៀបចំបដិសណ្ឋារកិច្ចភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិនៅចំណុច គ១ និងចំណុចលើប្រាសាទ និងបានរៀបចំយន្តការណ៍គ្រប់គ្រងភ្ញៀវទេសចរណ៍ចូលទស្សនានៅប្រាសាទព្រះវិហារ និងបានសិក្សារៀបចំកន្លែងទស្សនានៅប្រាសាទព្រះវិហារ និងជុំវិញតំបន់ប្រាសាទព្រះវិហារព្រមទាំងបានផ្សាភ្ជាប់ទៅនិងតំបន់រមណីយដ្ឋានផ្សេងៗទៀត នៅក្នុងប្រទេស និងនៅក្នុងតំបន់។

ចំពោះការងារដ៏ចំម្បងរបស់អាជ្ញាធរជាតិព្រះវិហារគឺ អាជ្ញាធរនេះត្រូវទទួលបន្ទុករៀបចំរបាយការណ៍ផ្សេងៗទាក់ទងនិងប្រាសាទព្រះខណ្ឌកំពង់ស្វាយ ដើម្បីត្រៀមដាក់បញ្ចូលប្រាសាទនេះចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលភារកិច្ចនេះត្រូវបន្តទៅអោយ ឯកឧត្តម គឹម សេតារាដែលជាប្រធានរបស់អាជ្ញាធរព្រះវិហារ បន្ទាប់ពី ឯកឧត្តម ជុច ភឿន[44]។

[44] ក្នុងពីធីប្រកាស និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំអាជ្ញាធជាតិរព្រះវិហារនាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី(www.preahvihearauthority.gov.kh/media-center/video-gallery/)

មុននិងទទួលបានសមិទ្ធិផលដូចខាងលើនេះ គឺចៀសមិនផុតពីបញ្ហាប្រឈមនោះទេដូចយើងដឹងរួចមកហើយថាអាជ្ញាធរជាតិព្រះវិហារទើបត្រូវបានបង្កើតថ្មី បានជួបប្រទះនូវបញ្ហាលំបាកជាច្រើន ពិសេសបញ្ហាធនធានមនុស្ស កង្វះមធ្យោបាយធ្វើដំណើរ ផ្លូវគមនាគមន៍មានការលំបាកជាមួយនឹងទីតាំងរមណីយដ្ឋានប្រាសាទព្រះវិហារ ស្ថិតនៅឆ្ងាយពីរាជធានីភ្នំពេញ។ នៅក្នុងតំបន់ការពាររមណីយដ្ឋានប្រាសាទព្រះវិហារ ទោះជាមានការហាមឃាត់ពីអាជ្ញាធរក៏ដោយ ការចាប់យកដី ការសង់លំនៅឋានថ្មី ក៏ដូចជាការកាប់ព្រៃឈើ នៅតែមានជាបន្តបន្ទាប់ ចំនួនប្រជាពលរដ្ឋកើនឡើងជាលំដាប់ ជាពិសេសក្នុងឱកាសថៃចូលឈ្លានពានប្រាសាទព្រះវិហារ។ សំណង់តូចធំធុនស្រាលក្តី ធ្ងន់ក្តី ធ្វើអំពីថ្មក្តី មានការកើនឡើងជាលំដាប់ជាបន្តបន្ទាប់ដោយចំហ នៅតាមដងផ្លូវដោយគ្មានលិខិតអនុញ្ញាតសាងសង់ឡើយ។បញ្ហាកាប់ដើមឈើនៅក្នុងតំបន់ប្រាសាទព្រះវិហារនៅតែមានបន្តបន្ទាប់នៅឡើយ ហើយបញ្ហានេះពិបាកធ្វើការទប់ស្កាត់ណាស់។

ក្រៅពីនេះមានសិប្បកម្មកែច្នៃឈើជាច្រើនដែលគ្មានច្បាប់អនុញ្ញាតបានបោះទីតាំងធ្វើអាជីវកម្មនៅតំបន់គ្រប់គ្រងដោយអាជ្ញាធរជាតិព្រះវិហារតាំងពីយូរណាស់ មកហើយដោយគ្មានស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធណាមួយមានលទ្ធភាពបង្ក្រាបហាមឃាត់ គ្រប់គ្រងដោះស្រាយឲ្យមានប្រសិទ្ធិភាពឡើយ។ ចំណុចខ្វះខាតនេះមកពីស្ថាប័នមានសមត្ថកិច្ច ពុំមានការប្តេជ្ញាចិត្តក្នុងការអនុវត្តហើយអាជ្ញាធរជាតិព្រះវិហារក៏ពុំទាន់មានលិខិតបទដ្ឋាន ច្បាប់ ជាមូលដ្ឋានគ្រប់គ្រងនៅ ឡើយ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវអំពីស្ថាប័នអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិនៃប្រាសាទព្រះវិហារ យើងសង្កេតឃើញថាអាជ្ញាធរនេះពិតជាដើរតួយ៉ាងសំខាន់មែនក្នុងការគ្រប់គ្រងថែរក្សាការពារ នៅប្រាសាទព្រះវិហារដែលជាប្រាសាទមួយយ៉ាងប្រណីតរបស់កម្ពុជាយើង។ ហើយអាជ្ញាធរនេះ ក៏ជាគ្រឹះស្ថានសាធារណៈមួយ ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ដែលបច្ចេកទេស នៅក្នុការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារជាបច្ចេកទេសមួយដែលបានជួយសម្រួលបន្ទុកដ៏ធ្ងន់របស់រដ្ឋ។ នៅក្នុងតួនាទី និងភារកិច្ច ក៏ដូចជា គោលដៅ អភិរក្ស និងការពារ អាជ្ញាធរនេះបានធ្វើសហប្រតិបត្តិការណ៍ យ៉ាងជិតស្និតជាមួយស្ថាប័នមួយចំនួន ដូចជាអង្គការយូណេស្កូ អង្គភាពពិសេសការពារបេតិកភណ្ឌ និងស្ថាប័នរដ្ឋាភិបាលមួយចំនួន។មិនតែប៉ុណ្ណោះ អាជ្ញាធរព្រះវិហារបានធ្វើការជួសជុលប្រាសាទ ក៏ដូចជាផ្លូវមួយចំនួនផងដែរ ហើយព្រមទាំងធ្វើការសិក្សាស្រាវជ្រាវដោយមានការជួយពីអ្នកជំនាញបច្ចេកទេសពីអាជ្ញាធរអប្សរាផងដែរ។

យ៉ាងណាមិញយើងក៏បានសង្កេតឃើញថា តំបន់ប្រាសាទព្រះវិហារមានភ្ញៀវទេសចរណ៍ទៅកំសាន្តជាច្រើន ដែលធ្វើឲ្យប្រជាពលរដ្ឋដែលរស់នៅទីនោះមានជីវភាពធូរធារជាងមុន និងមានសុវត្ថិភាពផងដែរ ទាំងអស់នេះ គឺជាការខិតខំប្រឹងប្រែងពីអាជ្ញាធរព្រះវិហារ។ ដូចនេះនៅក្នុងការខិតខំប្រឹងប្រែង ការពារ ថែរក្សា នូវប្រាសាទព្រះវិហារដែលជាតំបន់វប្បធម៌ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង គឺមានបំណង ចង់ថែរក្សានូវប្រាសាទព្រះវិហារបន្តពីបុព្វបុរសខ្មែរយើង នាសម័យបុរាណដើម្បីបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយបានដឹង និងបានស្គាល់ពីស្នាដៃដ៏ប្រណីតរបស់បុព្វបុរសខ្មែរយើង ព្រមទាំងចង់បណ្តុះនូវគំនិតក្នុងការអភិរក្ស និងអភិវឌ្ឍន៍ នូវតំបន់នេះឲ្យបានល្អជាងនេះទៅទៀត។ មិនតែប៉ុណ្ណោះ អាជ្ញាធរជាតិព្រះវិហារបានរៀបចំប្រព័ន្ធដឹកនាំ និងប្រឹងប្រែងកែលំអរបៀបធ្វើការ ក្នុងន័យដើម្បីធានាឲ្យមានការអភិវឌ្ឍដោយនិរន្តរភាព និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព សំដៅពង្រឹងសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន ដោយឈរលើមូលដ្ឋានក្នុងការធានាឲ្យប្រជាពលរដ្ឋគ្រប់ៗរូប មានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំ និងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ក៏ដូចជាការបង្កើតឡើងនូវបរិយាកាសប្រកបដោយប្រសិទ្ធិភាពសម្រាប់ ការគ្រប់គ្រងធនធានធម្មជាតិ និងការទទួលបាននូវផលប្រយោជន៍មិនចេះរីងស្ងួតរបស់រមណីយដ្ឋានប្រាសាទព្រះវិហារ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពរដ្ឋក្នុងការកាត់បន្ថយភាពក្រីក្រដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រ ក្រុមជនងាយរងគ្រោះ ក្រុមជនជាតិភាគតិច ជាពិសេសស្ត្រី និងកុមារជាដើម។ លើសពីនេះទៅទៀតក្នុងដំណើរការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងស្អិត រមួតដែលមិនអានកាត់ផ្តាច់បាន ពីការជួយឧបត្ថម្ភរបស់អាជ្ញាធរ ខេត្ត ស្រុក ឃុំ ភូមិ

និងប្រជាពលរដ្ឋ និងកងកម្លាំង ប្រដាប់អាវុធឈរជើងនៅក្នុងតំបន់គ្រប់ប្រភេទ ពិសេសជាមួយថ្នាក់ដឹកនាំខេត្តព្រះវិហារ ដែលបានផ្តល់ការជួយ ឧបត្ថម្ភខាងផ្នែកហិរញ្ញវត្ថុ សង្គមកិច្ច សន្តិសុខ សុវត្ថិភាព ដល់ការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ។

ទន្ទឹមនឹងចំនុចខ្លាំងទាំងនេះ ក៏នៅមានចំនុចអវិជ្ជមានមួយចំនួនដែរ គឺអាជ្ញាធរនេះមានការខ្វះខាតថវិកាមួយចំនួនក្នុងការជួយអភិវឌ្ឍន៍តំបន់ព្រះវិហារ និងខ្វះបណ្តាលិខិតបទដ្ឋានគតិយុត្ត និងការគ្រប់គ្រងរមណីយដ្ឋាន។ មិនតែប៉ុណ្ណោះអាជ្ញាធរនេះខ្វះនូវសម្ភារៈមួយចំនួន ដូចជារថយន្តដែលមានកម្លាំងខ្លាំងអាចប្រើការបាននៅគ្រប់ស្ថានភាពផ្លូវ និងអាកាសធាតុ ដើម្បីងាយស្រួលនៅពេលចុះអន្តរាគមន៍។ លើសពីនេះទៅទៀតអាជ្ញាធរជាតិព្រះវិហារនេះមិនទាន់មានស្វ័យភាពខាងអំណាច នៅពេលចុះអន្តរាគមន៍នៅឡើយជាហេតុធ្វើឲ្យមានការលំបាកនៅពេលមានបទល្មើសជាក់ស្តែងមួយចំនួនបានកើតឡើង។ អាជ្ញាធរនេះទទួលគំនាបពីអ្នកមានអំណាចមួយចំនួនដែលធ្វើការកាប់ព្រៃឈើ នៅក្នុងតំបន់ការពារ ហើយអាជ្ញាធរនេះមិនទាន់មានសមត្ថភាពដោះស្រាយបញ្ហាទាំងអស់នេះបាននៅឡើយទេ។

ដើម្បីធ្វើឲ្យអាជ្ញាធរជាតិព្រះវិហារ មានភាពងាយស្រួលក្នុងការគ្រប់គ្រងទៅលើតំបន់ប្រាសាទព្រះវិហារឲ្យបានល្អ គេត្រូវបំពេញបន្ថែមនូវអ្វីដែលអាជ្ញាធរជាតិព្រះវិហារខ្វះខាត ដូចជាបង្កើតក្រុមសណ្តាប់ធ្នាប់សាធារណៈមួយដើម្បីអនុវត្តន៍ច្បាប់ឲ្យបានល្អ ហើយរាជរដ្ឋាភិបាលត្រូវសម្រួលឲ្យអាជ្ញាធរនេះ មានស្វ័យភាពខាងអំណាចផ្ទាល់ខ្លួន នៅពេលចុះធ្វើអន្តរាគមន៍។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលគួរតែផ្តល់ជំនួយជាសម្ភារៈក្តី ជាថវិកាក្តីដល់អាជ្ញាធរជាតិព្រះវិហារ។

# អនុសាសន៍

ការបង្កើតអាជ្ញាធរជាតិព្រះវិហារ ពិតជាមានសារៈសំខាន់ណាស់ ព្រោះអាជ្ញាធរនេះបង្កើតឡើងក្នុងគោលបំណងដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងជាគ្រឹះស្ថានសាធារណៈប្រកបដោយបុគ្គលភាពគតិយុត្ត ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុថែមទៀតផង ដូចនេះអាជ្ញាធរនេះមានតួនាទី និងភារកិច្ចជាច្រើនក្នុងការការពារសម្បត្តិបេតិកភណ្ឌមួយនេះ។

ប៉ុន្តែយ៉ាងណាមិញ ការយល់ដឹងពី តួនាទី និងភារកិច្ចនៃអាជ្ញាធរនេះមិនទាន់ទូលំទូលាយនៅឡើយ ចំពោះយុវជន ក៏ដូចជាប្រជាជនខ្មែរទាំងមូលដែលជា ហេតុធ្វើអោយអាជ្ញាធរនេះធ្វើការងាររបស់ខ្លួនយ៉ាងស្ងប់ស្ងាត់ និងមិនមានការចាប់អារម្មណ៍ពីមហាជននោះទេ។ ជាក់ស្តែងនៅពេលដែលសួរទៅនិស្សិតមួយចំនួនថាស្គាល់អាជ្ញាជាតិព្រះវិហារដែរ រឺទេ ចំលើយបានបកវិញគឺមិនដែលលឺសូម្បីតែឈ្មោះ មាននិស្សិតតិចតួចណាស់ដែលយល់ដឹងពីអាជ្ញាធរនេះ ក៏ដូចជាប្រជាជនខ្មែរទាំងមូលស្ទើតែមិនស្គាល់អាជ្ញាធរនេះផង ទាំងដែលអាជ្ញាធរនេះមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការកាពារ សម្បត្តិបេតិកភណ្ឌរបស់យើងទាំងអស់គ្នា។ ហេតុអ្វីបានជាយើងទាំងអស់គ្នាហាក់ព្រងើយកន្តើយនឹងអាជ្ញាធរនេះ ហេតុអ្វីមិននាំគ្នាតាមដាន ការធ្វើការ ក៏ដូចជាដំណើរការនៃការប្រព្រឹត្តទៅរបស់អាជ្ញាធរនេះ ថាតើបានគោរពតួនាទី និងកាតព្វកិច្ចរបស់ខ្លួនដែលឬទេ ទាំងដែលខ្លួនគឺជាអាជ្ញាធរជាតិមួយដែលតំណាងអោយរាជរដ្ឋាភិបាល។

ជាសារ័ន្ត ក្នុងនាមយើងជាបញ្ញវន្តជំនាន់ក្រោយនេះ ដែលកំពុងតែរស់នៅក្នុងបរិបទសង្គមមួយដែលពោរពេញទៅដោយសន្តិភាព និងផ្តល់តម្លៃទៅលើចំណេះដឹង និងការអភិវឌ្ឍគប្បីសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់លាស់ពីព្រឹត្តិការណ៍របស់សង្គម និងដំណើរការរបស់សង្គមជាពិសេសគួរតែសិក្សាអំពីអាជ្ញាធរទាំងឡាយដែលត្រូវបានរដ្ឋាភិបាលបង្កើតឡើង និងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការតាមដានការងាររបស់អាជ្ញាធរទាំងនោះ អ្វីដែលសំខាន់គឺត្រូវសិក្សាស្វែងយល់ពីអាជ្ញាធរដែលធ្វើការលើការការពារសម្បត្តិបេតិកភណ្ឌរបស់យើង ដើម្បីជាយន្តការមួយក្នុងការជួយអភិរក្ស ក៏ដូចជាសរបញ្ជាក់អោយឃើញថាយើងបានឲ្យតម្លៃទៅលើសម្បត្តិវប្បធម៌របស់យើង និងចូលរួមចំនែកជាមួយអាជ្ញាធរក្នុងការជួយ ការពារ ថែរក្សា សម្បត្តិវប្បធម៌របស់យើង។ នៅពេលដែលយើងបានយល់ដឹងពីអាជ្ញាធរព្រះវិហារហើយ ប្រាកដណាស់ថា យើងនឹងចៀសផុតពីការរំលោភបំពាន ពីសំណាក់ជនខិលខូចមួយចំនួនដែលតែងតែមានបំណងក្នុងការឈ្លានពានប្រាសាទព្រះវិហាររបស់យើងឥតឈប់ឈរ ហើយយើងនឹងកាន់តែបង្កើនមនសិការស្នេហាជាតិទៀតផង។

ជាចុងក្រោយ ក្នុងនាមយើងទាំងអស់គ្នាជាយុវជនខ្មែរទាំងអស់ព្យាយាមសិក្សារៀនសូត្រ និងរួបរួមគ្នា ជាមួយអាជ្ញាធរជាតិព្រះវិហារក្នុងការ ការពារ អភិរក្ស រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្ររបស់យើងអោយបានគង់វង្សយូរអង្វែង ជាពិសេសការពារឲ្យបានពីការឈ្លានពាននានាមកលើប្រាសាទរបស់យើង ហើយយើងខ្ញុំក៏សូមធ្វើការសំណូមពរទៅដល់ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាប្រធានអាជ្ញាធរជាតិព្រះវិហារ មេត្តាបន្តសកម្មភាពរបស់ខ្លួន ដើម្បីលើកស្ទួយកេរដំណែលវប្បធម៌ជាតិរបស់យើងឲ្យកាន់តែល្បីទាំងក្នុងជាតិ និងនៅលើឆាកអន្តរជាតិ ព្រមទាំងបន្តផ្សព្វផ្សាយសម្បត្តិបេតិកភណ្ឌមួយនេះ អោយពិភពលោកទាំងមូលកាន់តែស្គាល់ពីប្រាង្គប្រាសាទដ៏ល្បីរបស់យើង និងជាពិសេសបញ្ជាក់អោយឃើញថា យើងក៏មានអាជ្ញាធរមួយពោរពេញទៅដោយសមត្ថភាពក្នុងការថែរក្សាសម្បត្តិបេតិកភណ្ឌរបស់យើង មិនចាញ់បរទេសនោះទេ។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- **ព្រះរាជក្រឹត្យ**
  - ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧ ៩១ ស្តីពី លក្ខន្តិកៈគតិយុត្តនៃគ្រឹស្ថានសាធារណៈរដ្ឋបាល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧
  - ព្រះរាជក្រឹត្យចាស់លេខ នស/រកត/០៤០៦/១៨៣ស្តីពី ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៦
  - ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៦
  - ព្រះរាជក្រឹត្យថ្មីលេខ នស/រកត/០៨១១/៧៥២ស្តីពី ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១
- **អនុក្រឹត្យ**
  - អនុក្រឹត្យចាស់លេខ ១១៨ អនក្រ.បក ស្តីពី ការរៀបចំ និងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦
  - អនុក្រឹត្យលេខ ១១.អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ ដើម្បីអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨
  - អនុក្រឹត្យថ្មីលេខ ៤២ អនក្រ.បក ស្តីពី ការរៀបចំ និងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤
- **សេចក្តីសម្រេច**
  - សេចក្តីសម្រេចលេខ ១០៩/០៩ ស.ស.រ របស់ក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិព្រះវិហារ ស្តីពី លក្ខន្តិកៈដោយឡែករបស់បុគ្គលិកនៃអាជ្ញាធរជាតិព្រះវិហារចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩

- **សៀវភៅនិពន្ធ និងឯកសារពាក់ព័ន្ធ**
  - វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ
  - សៀវភៅនីតិនគររូបនីយរបស់សាស្ត្រាចារ្យ បណ្ឌិត **អ៊ុន សកក្ខដា**
  - សៀវភៅរឿងក្តីប្រាសាទព្រះវិហារ
  - សៀវភៅ ទំនាស់ព្រំដែនរវាងប្រទេសថៃ និងប្រទេសជិតខាង
- **គេហទំព័រ និងទស្សនាវដ្តី និងផ្សេងៗ**
  - ទស្សនាវដ្តីវិទ្យាសាស្ត្រ មហិច្ឆិតាចង់បានប្រាសាទព្រះវិហារ, ឆ្នាំទី១ លេខ១ ចុះខែ តុលា-ធ្នូ ឆ្នាំ២០០៨ ទំព័រទី១០
  - សន្និសិទ្ធិកាសែតដែលចាក់ផ្សាយតាមរយៈទូរស្សន៍បាយ័ន ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១
  - វិទ្យុអាស៊ីសេរី ផ្សាយនៅម៉ោង ៧:៥៥ នាទីយប់ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥
  - សេចក្តីប្រកាសពត៌មានរបស់អាជ្ញាធរជាតិព្រះវិហារ (www.preahvihearauthority.gov.kh/trourist-statistic)
  - ការផ្សាយរបស់ International Centre for the study of the preservation and restoration of cultural property នៅថ្ងៃទី២៤ មិថុនា ឆ្នាំ២០០៩
  - ដកស្រង់ចេញពី www.preahvihearauthority.gv.kh/international-cooperation/icc-preahvihear
  - ក្នុងពីធីប្រកាស និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំអាជ្ញាធជាតិរព្រះវិហារនាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី (www.preahvihearauthority.gov.kh/media-center/video-gallery/)

## បញ្ជីឧបសម្ព័ន្ធ

- និមិត្តសញ្ញានៃស្ថាប័នអាជ្ញាធរជាតិព្រះវិហារ
- ផែនទីកំណត់ព្រំប្រទល់ និងបែងចែកតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិព្រះវិហារ ( អ.ជ.ព.វ )
- **ឧបសម្ព័ន្ធ១** : ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧ ៩១ ស្តីពី លក្ខន្តិក:គតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- **ឧបសម្ព័ន្ធ២** : ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៩៨ ស្តីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- **ឧបសម្ព័ន្ធ៣** : ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ស្តីពី ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- **ឧបសម្ព័ន្ធ៤** : អនុក្រឹត្យលេខ ១១.អនក្រ.បក ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- **ឧបសម្ព័ន្ធ៥ :** អនុក្រឹត្យលេខ ៩២.អនក្រ.បក ស្តីពី ការរៀបចំ និងការគ្រប់គ្រង តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- **ឧបសម្ព័ន្ធ៦** : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិព្រះវិហារលេខ ១០៦/០៩ សសរ ស្តីពី លក្ខន្តិក:ដោយឡែករបស់បុគ្គលិកនៃអាជ្ញាធរជាតិព្រះវិហារ